# គោលការណ៍ណែនាំស្តីពី
# ការអនុវត្តន៍ជាក់ស្តែងក្នុងការផ្តល់ថ្នាំបង្ការ
## សំរាប់បុគ្គលិកសុខាភិបាល




## កម្មវិធីជាតិផ្តល់ថ្នាំបង្ការ

ពិនិត្យឡើងវិញ ឆ្នាំ២០១៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# គោលការណ៍ណែនាំស្តីពី
# ការអនុវត្តន៍ជាក់ស្តែងក្នុងការផ្តល់ថ្នាំបង្ការ
## សំរាប់បុគ្គលិកសុខាភិបាល

កម្មវិធីជាតិផ្តល់ថ្នាំបង្ការ

ពិនិត្យឡើងវិញ ឆ្នាំ២០១៧

# អារម្ភកថា

**កម្មវិធីជាតិផ្តល់ថ្នាំបង្ការ** នៃមជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារកបាននិងកំពុងបញ្ចូលវ៉ាក់សាំងថ្មីៗជាបន្តបន្ទាប់រហូតមកដល់ពេលនេះ មានវ៉ាក់សាំងការពារជំងឺចំនួន១១មុខ ដែលបានបញ្ចូលទៅក្នុងសកម្មភាពផ្តល់ថ្នាំបង្ការជាប្រចាំ រួមមាន៖ វ៉ាក់សាំងការពារជំងឺរបេង រលាកថ្លើមប្រភេទបេ ក្អកមាន់ ខាន់ស្លាក់ តេតាណូស រលាកសួត-រលាកស្រោមខួរក្បាលដែលបង្កដោយមេរោគហ៊ីប រលាកសួត-រលាកស្រោមខួរក្បាលដែលបង្កដោយមេរោគភ្នឺម៉ូកុក គ្រុនស្វិតដៃជើងប្រភេទបន្តក់ គ្រុនស្វិតដៃជើងប្រភេទចាក់ កញ្ជ្រឹល-ស្អូច និង រលាកខួរក្បាលជេអ៊ី ។ ក្រៅពីសកម្មភាពបញ្ចូលវ៉ាក់សាំងថ្មីនិងបង្កើនអត្រាគ្របដណ្តប់គ្រប់មុខវ៉ាក់សាំង កម្មវិធីជាតិផ្តល់ថ្នាំបង្ការក៏បានពង្រឹង នូវគុណភាពនៃការគ្រប់គ្រងប្រព័ន្ធត្រជាក់/វ៉ាក់សាំង និង ការតាមដានស្រាវជ្រាវជំងឺដែលអាចការពារបានដោយវ៉ាក់សាំងផងដែរ ។

ដោយមានតម្រូវការចាំបាច់របស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការនាពេលបច្ចុប្បន្ននេះ កម្មវិធីជាតិបានធ្វើបច្ចុប្បន្នភាពឡើងវិញនូវ **គោលការណ៍ណែនាំស្តីពីការអនុវត្តជាក់ស្តែងក្នុងការផ្តល់ថ្នាំបង្ការ** ឲ្យស្របតាមឯកសារគោលរបស់អង្គការសុខភាពពិភពលោកឆ្នាំ២០១៥ ទៅតាមស្ថានភាពជាក់ស្តែង និង ការរីកចំរើនរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ ។ គោលការណ៍ណែនាំនេះនឹងផ្តល់នូវចំណេះដឹងថ្មីៗបន្ថែមទៀតដល់មន្ត្រី និង បុគ្គលិកផ្តល់ថ្នាំបង្ការនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ដើម្បីអោយការអនុវត្តសេវាផ្តល់ថ្នាំបង្ការ ទទួលបានគុណភាពខ្ពស់ និង មានការចូលរួមយ៉ាងសកម្មពីសហគមន៍ ព្រមទាំងផ្នែកពាក់ពន្ធ័នានា ធានានិរន្តភាពនៃសកម្មភាពផ្តល់ថ្នាំបង្ការជាប្រចាំ សំដៅការពារសុខមាលភាពដល់ទារក កុមារ និង ស្ត្រី នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ក្រសួងសុខាភិបាល** សូមថ្លែងអំណរគុណចំពោះ អង្គការសុខភាពពិភពលោក មូលនិធិសម្រាប់កុមារនៃអង្គការសហប្រជាជាតិ(យូនីសេហ្វ) អង្គការ Gavi និង ដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត ដែលបានគាំទ្រ ផ្តល់ថវិកា និង បច្ចេកទេសដល់កម្មវិធីជាតិផ្តល់ថ្នាំបង្ការឲ្យទទួលបានជោគជ័យ និង បានចូលរួមជាមួយកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ក្នុងការធ្វើបច្ចុប្បន្នភាពឡើងវិញនូវ **គោលការណ៍ណែនាំស្តីពីការអនុវត្តជាក់ស្តែងក្នុងការផ្តល់ថ្នាំបង្ការ** សំរាប់បុគ្គលិកសុខាភិបាលនាពេលនេះ ។

**ក្រសួងសុខាភិបាល** សង្ឃឹមថា **គោលការណ៍ណែនាំស្តីពីការអនុវត្តជាក់ស្តែងក្នុងការផ្តល់ថ្នាំបង្ការ** នឹងក្លាយជាឯកសារសំខាន់មួយសំរាប់បុគ្គលិកសុខាភិបាលយកទៅអនុវត្តតាម ប្រកបដោយប្រសិទ្ធភាព ។

រាជធានីភ្នំពេញ ថ្ងៃទី..០៥..ខែ..មេសា..ឆ្នាំ ២០១៧

**ឋ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

សាស្ត្រាចារ្យ **អេង ហួត**

# ពាក្យបំព្រួញ

| | |
|---|---|
| °C | degrees centigrade |
| AD | Auto-disable (syringe) |
| AEFI | Adverse Event Following Immunization |
| BCG | Bacille Calmette-Guérin (tuberculoses vaccine) |
| CC | Cold Chain |
| CMS | Central Medical Store |
| DTP | Diphtheria, Tetanus and Pertussis vaccine |
| DTP-Hep | Diphtheria, Tetanus , Pertussis and Hep B vaccine |
| DTP-Hep-Hib | Diphtheria, Tetanus Pertussis , Hep B and Hib vaccine |
| EEFO | Earliest-Expiry-First-Out |
| EPI | Expanded Programme on Immunisation |
| EVM | Effective Vaccine Management |
| FIC | Fully Immunized Child |
| GAVI | Global Alliance for Vaccines and Immunization |
| HepB | Hepatitis B vaccine |
| Hib | Haemophilus influenza type b |
| ILR | Ice-lined refrigerator |
| ICC | Immunization Coordinating Committee |
| JE | Japanese encephalitis vaccine |
| LD | Lowest delivery level store |
| MoH | Ministry of Health |
| MR | Measles and Rubella vaccine |
| OPV | Oral Polio Vaccine |
| PAR | Product Arrival Report |
| PR | Primary store |
| RTM | Remote Temperature Monitoring |
| SN | Sub-national store |
| SOP | Standard Operating Procedure |
| SP | Service point (health facility) |
| UNICEF | United Nations Children's Fund |
| VAR | Vaccine Arrival Report |
| VVM | Vaccine Vial Monitor |
| WHO | World Health Organization |

# មាតិកា


**អារម្ភកថា**

**ពាក្យបំព្រួញ**

**សេចក្តីផ្តើម**

**ជំពូកទី១ ៖ ជំងឺដែលអាចការពារបានដោយវ៉ាក់សាំង**

១. ជំងឺខាន់ស្លាក់

២. ជំងឺក្អកមាន់

៣. ជំងឺគ្រុនស្វិតដៃជើង

៤. ជំងឺកញ្ច្រឹល

៥. ជំងឺស្អូច និង ជំងឺស្អូចពីកំណើត

៦. ជំងឺតេតាណូស

៧. ជំងឺរបេង

៨. ជំងឺរលាកខួរក្បាលជេអ៊ី

៩. ជំងឺរលាកស្រួតនិងស្រោមខួក្បាលដោយសារមេរោគហ៊ីប

១០. ជំងឺរលាកស្រួតនិងស្រោមខួក្បាលដោយមេរោគភ្នឺម៉ូកុក

១១. ជំងឺរលាកថ្លើមប្រភេទ បេ

**ជំពូកទី ២ ៖ ការរៀបចំទិវាផ្តល់ថ្នាំបង្ការ**

១ ប្រជាជនចំណុច

២ កំណត់តារាង ៣ ក

៣ កំណត់តារាង ៣ ខ

**ជំពូកទី ៣ ៖ វ៉ាក់សាំងរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ និង ប្រព័ន្ធត្រជាក់**

១. សេចក្តីផ្តើម

២. វ៉ាក់សាំង DPT-HepB-Hib

៣. វ៉ាក់សាំង OPV

៤. វ៉ាក់សាំង IPV

៥. វ៉ាក់សាំងMR

៦. វ៉ាក់សាំងជេអ៊ី (SA 14-14-2 JE)

៧. វ៉ាក់សាំង PCV13

៨. កត្តាដែលនាំអោយវ៉ាក់សាំងខូច

៩. ចំណុចសំខាន់ៗក្នុងការថែរក្សាវ៉ាក់សាំង

១០. តារាងប្រតិទិននៃការផ្តល់ថ្នាំបង្ការ និង ប្រតិកម្មបន្ទាប់បន្សំ
១១. ការបំពេញតារាងរបាយការណ៍ប្រព័ន្ធត្រជាក់
១២. ការគណនាការស្នើសុំវ៉ាក់សាំង
១៣. ការបំពេញតារាងរបាយការណ៍ស្ថានភាពវ៉ាក់សាំងនិងសំភារៈប្រចាំខែសំរាប់ថ្នាក់មណ្ឌលសុខភាព
១៤. ការបំពេញតារាងតាមដានសីតុណ្ហភាពទូទឹកកក
១៥. ការបំពេញតារាងតាមដានស្ថានភាព ការប្រើប្រាស់ និង អត្រាខាតបង់វ៉ាក់សាំង–ស៊ីរ៉ាំង
១៦. ការធ្វើអង្កេតឃ្លាំងវ៉ាក់សាំងនិងសំភារៈ
១៧. ការថែរក្សាទូទឹកកកនិងការជួសជុលតូចតាច

## ជំពូកទី ៤ ៖ ការផ្តល់ថ្នាំបង្ការប្រកបដោយសុវត្ថិភាព និងហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ( AEFI )

១. ស្ថានភាពទូទៅនៃការផ្តល់ថ្នាំបង្ការប្រកបដោយសុវត្ថិភាព
២. ក្រុមប្រឈមមុខនឹងផលវិបាកនៃការចាក់ថ្នាំគ្មានសុវត្ថិភាព
៣. ដូចម្តេចដែលហៅថាការផ្តល់ថ្នាំប្រកបដោយសុវត្ថិភាព ?
៤. ការផ្តល់ថ្នាំបង្ការប្រកបដោយសុវត្ថិភាពដោយប្រើសីរ៉ាំងអូតូឌីសេបឹល (AD)
៥. ប្រអប់សុវត្ថិភាព "Safety box"
៦. ការផ្គត់ផ្គង់សីរ៉ាំងអូតូឌីសេបឹល ប្រអប់សុវត្ថិភាពនិងការប្រមូលមកវិញដើម្បីដុតកំទេច
៧. ការដុតកំទេចប្រកបដោយសុវត្ថិភាព
៨. ការត្រួតពិនិត្យតាមដាន និង វាយតំលៃ
៩. ចំណុចសំខាន់ៗ អំពីការផ្តល់ថ្នាំប្រកបដោយសុវត្ថិភាព

## ហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ( AEFI )

១០. និយមន័យអំពីហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ(AEFI)
១១. ចំណាត់ថ្នាក់នៃហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ(AEFI)
១២. ប្រភេទនៃហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ(AEFI)
១៣. តើត្រូវធ្វើរបាយការណ៍ករណីហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ(AEFI)យ៉ាងដូចម្តេច?
១៤. ប្រពន្ធ័វាយការណ៍ និង ការឆ្លើយតបករណីហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ(AEFI)

## ជំពូកទី ៥ ៖ការណែនាំអំពីរបៀបកត់ត្រា

១. ការបំពេញបណ្ណ័លឿង(បណ្ណ័សុខភាពកុមារ)
២. ការគូសរបាយការក្បាលម្ទូល(របាយការប្រចាំខែ)
៣. ការកត់ត្រាលើបញ្ជីផ្តល់ថ្នាំបង្ការ

## ជំពូកទី ៦ ៖តាមដាន-វាយតំលៃអត្រាគ្របណ្តប់នៃការផ្តល់ថ្នាំបង្ការនិងការតាមដានស្រាវជ្រាវជំងឺដែលអាចការពារបានដោយវ៉ាក់សាំង

១. គោលបំណងនៃការវាយតំលៃ

២. ទំរង់នៃការត្រួតពិនិត្យវាយតំលៃ

៣. ជំហាននៃការត្រួតពិនិត្យវាយតំលៃ

៤. គណនាអត្រាគ្របដណ្តប់ និង អត្រាបោះបង់នៃវ៉ាក់សាំងរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ

**ការតាមដានស្រាវជ្រាវជំងឺដែលអាចការពារបានដោយវ៉ាក់សាំង**

៥. គោលបំណងនៃការតាមដានស្រាវជ្រាវជំងឺដែលអាចការពារបានដោយវ៉ាក់សាំង

៦. និយមន័យនៃជំងឺដែលអាចការពារបានដោយវ៉ាក់សាំង

៧. ការរាយការណ៍ជំងឺដែលអាចការពារបានដោយវ៉ាក់សាំង

៨. ការបំពេញតារាងតារាងតាមដានសកម្មភាពតាមដានស្រាវជ្រាវជំងឺដែលអាចការពារបានដោយវ៉ាក់សាំង និង ហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ(AEFI)

៩. ប្រព័ន្ធរាយការណ៍ និង អង្កេតករណីសង្ស័យជំងឺជំងឺដែលអាចការពារបានដោយវ៉ាក់សាំង

**ជំពូកទី ៧ ៖ ការចូលរួមអប់រំសុខភាពសហគមន៍**

១ -គោលបំណងនៃយុទ្ធសាស្រ្តទំនាក់ទំនងនិងការផ្លាស់ប្តូរឥរិយាបទ:

២ -ប្រជាជនចំណុច និងក្រុមចូលរួម:

៣ -សមាសភាគនៃយុទ្ធសាស្រ្តទំនាក់ទំនងនិងការផ្លាស់ប្តូរឥរិយាបទ:

៤ -សារអប់រំសុខភាព និង

៥-ខាងក្រោមនេះគឺជាវេទិកាកិច្ចប្រជុំដែលមានស្រាប់ដែលត្រូវបានរៀបចំឡើងនៅក្នុងស្ថាប័នរដ្ឋបាល និង ស្ថាប័នសុខាភិបាល

# សេចក្តីផ្តើម

**កម្មវិធីជាតិផ្តល់ថ្នាំបង្ការ** បានអនុវត្តសកម្មភាពផ្តល់ថ្នាំបង្ការដល់ទារកកុមារ និង ស្រ្តីទូទាំងព្រះរាជាណាចក្រកម្ពុជាចាប់តាំងពីឆ្នាំ១៩៨៦មកម្ល៉េះក្នុងនោះមានការផ្តល់វ៉ាក់សាំងការពារជំងឺរបេង គ្រុនស្វិតដៃជើង ក្អកមាន់ ខាន់ស្លាក់ តេតាណូស និង កញ្ជ្រឹលចំពោះកុមារ ព្រមទាំងផ្តល់វ៉ាក់សាំងបង្ការជំងឺតេតាណូសដល់ស្រ្តីដែលមានផ្ទៃពោះ និង ស្រ្តីក្នុងវ័យបន្តពូជអាយុ១៥ដល់៤៥ឆ្នាំផងដែរដោយមានការគាំទ្រពីមូលនិធិសម្រាប់កុមារនៃអង្គការយូនីសេហ្វ ។ ដោយមានការគាំទ្រពីអង្គការ Gavi និងអង្គការដៃគូអភិវឌ្ឍន៍នានារួមមានអង្គការសុខភាពពិភពលោក អង្គការយូនីសេហ្វ អង្គការ PATH ក្រសួងសុខាភិបាលបានសំរេចបញ្ចូលវ៉ាក់សាំង៖

- ❖ ឆ្នាំ២០០១ ដាក់អោយប្រើប្រាស់ AD ស៊ីរ៉ាំង និងប្រអប់សុវត្ថិភាព
- ❖ ឆ្នាំ២០០១ បញ្ចូលវ៉ាក់សាំងរលាកថ្លើមប្រភេទបេគឺរួមបញ្ចូលគ្នាបួនមុខគឺវ៉ាក់សាំង DPT-HepB និង បញ្ចូលវ៉ាក់សាំងរលាកថ្លើមប្រភេទបេដូសពេលកើត នៅឆ្នាំ២០០៦។
- ❖ ឆ្នាំ២០០៩ បញ្ចូលវ៉ាក់សាំងរលាកខួរក្បាលជីអ៊ី (JE) នៅខេត្តចំនួន៣គឺ ខេត្តស្វាយរៀង ខេត្តតាកែវ និង ខេត្តកំពង់ចាម និង បញ្ចូលបន្ថែមចំនួនពីខេត្តទៀតគឺ ខេត្តបាត់ដំបង និង បន្ទាយមានជ័យនៅឆ្នាំ ២០១៥ ។
- ❖ ឆ្នាំ២០១០បញ្ចូលវ៉ាក់សាំងវ៉ាក់សាំងការពារជំងឺរលាកសួតនិងស្រោមខួក្បាលដោយសារមេរោគហ៊ីប(Hib)គឺរួមបញ្ចូលគ្នាប្រាំមុខគឺវ៉ាក់សាំង DPT-HepB-Hib ។
- ❖ ឆ្នាំ២០១២បញ្ចូលវ៉ាក់សាំងកញ្ជ្រឹលដូសទី២ ។
- ❖ ឆ្នាំ២០១៣បញ្ចូលវ៉ាក់សាំងកញ្ជ្រឹល-ស្អូច ។
- ❖ ឆ្នាំ២០១៥បញ្ចូលវ៉ាក់សាំងការពារជំងឺរលាកសួត-រលាកស្រោមខួរក្បាលដែលបង្កដោយមេរោគភ្នើម៉ូកូក។
- ❖ នៅខែធ្នូ២០១៥បញ្ចូលថ្នាំបង្ការវ៉ាក់សាំងប៉ូលីយ៉ូប្រភេទចាក់(IPV)មួយមុខទៀតទៅក្នុងកម្មវិធីជាតិផ្តល់ថ្នាំបង្ការជាប្រចាំនៅទូទាំងប្រទេសកម្ពុជា។
- ❖ នៅថ្ងៃទី១៩ខែមេសាឆ្នាំ២០១៦ប្រទេសកម្ពុជាក៏ដូចជាប្រទេសនៅក្នុងពិភពលោកដែរបានធ្វើការផ្លាស់ប្តូរវ៉ាក់សាំងប៉ូលីយ៉ូប្រភេទបីវ៉ាឡង់ (Trivalent OPV) ទៅពីរវ៉ាឡង់ (Bivalent OPV) នៅក្នុងកម្មវិធីផ្តល់ថ្នាំបង្ការ។

ចាប់ពីឆ្នាំ១៩៨៦ មកដល់ពេលបច្ចុប្បន្ននេះកម្មវិធីជាតិផ្តល់ថ្នាំបង្ការ បានបញ្ចូលវ៉ាក់សាំងចំនួន១២មុខទៅក្នុងសកម្មភាពផ្តល់ថ្នាំបង្ការជាប្រចាំ វ៉ាក់សាំងទាំងនោះរួមមាន៖វ៉ាក់សាំងការពារជំងឺរបេង រលាកថ្លើមប្រភេទបេ ក្អកមាន់ ខាន់ស្លាក់ តេតាណូស រលាកសួត-រលាកស្រោមខួរក្បាលដែលបង្កដោយមេរោគហ៊ីប រលាកសួត-រលាកស្រោមខួរក្បាលដែលបង្កដោយមេរោគភ្នើម៉ូកូក គ្រុនស្វិតដៃជើងប្រភេទបន្តក់ គ្រុនស្វិតដៃជើងប្រភេទចាក់ កញ្ជ្រឹល ស្អូច និងរលាកខួរក្បាលជេអ៊ី ដើម្បីកាត់បន្ថយអត្រាឈឺ ពិការ និង ស្លាប់ដោយជំងឺ១១មុខដែលអាចការពារបានដោយវ៉ាក់សាំងគឺ របេង ខាន់ស្លាក់ ក្អកមាន់ គ្រុនស្វិតដៃជើង តេតាណូស កញ្ជ្រឹល រលាកថ្លើមប្រភេទ បេ រលាកសួត-រលាកស្រោមខួរក្បាលដែលបង្កដោយមេរោគហ៊ីប រលាកសួត-រលាកស្រោមខួរក្បាលដែលបង្កដោយមេរោគភ្នើម៉ូកូក រលាកខួរក្បាលជេអ៊ីនិងជំងឺស្អូច។

## គោលដៅចម្បងរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ

គោលដៅចម្បងៗរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការគឺដើម្បីធានាឱ្យបាននូវប្រជាជនមានសុខភាពល្អ និង ការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនទាំងអស់ តាមរយៈកាត់បន្ថយអត្រាឈឺ ពិការ ស្លាប់ ប្រយុទ្ធប្រឆាំង ការបំបាត់ ឬ ការលុបបំបាត់ជម្ងឺទាំងឡាយណាដែលអាចការពារបានដោយសារវ៉ាក់សាំងដូចជា៖ របេង រលាកថ្លើមប្រភេទ បេ ខាន់ស្លាក់ ក្អកមាន់ គ្រុនស្វិតដៃជើង តេតាណូស កញ្ជ្រឹល រលាកសួត-រលាកស្រោមខួរក្បាលដែលបង្កដោយមេរោគហ៊ីប រលាកសួត-រលាកស្រោមខួរក្បាលដែលបង្កដោយមេរោគភ្នឺម៉ូកូក រលាកខួរក្បាលជេអ៊ី និង ជម្ងឺស្អូចជាដើម។

## ទិសដៅរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការនាពេលបច្ចុប្បន្ន

- ថែរក្សានិរន្តរភាពនៃការលុបបំបាត់ជម្ងឺប៉ូលីយ៉ូ
- ថែរក្សានិរន្តរភាពនៃលុបបំបាត់ជម្ងឺកញ្ជ្រឹល
- ថែរក្សានិរន្តរភាពនៃលុបបំបាត់ជម្ងឺតេតាណូសទារក
- សំរេចអោយបានកាត់បន្ថយអត្រាប្រេវ៉ាឡង់នៃជម្ងឺរលាកថ្លើមប្រភេទបេ អោយនៅក្រោម១%នៅឆ្នាំ២០១៧
- សំរេចអោយបានលុបបំបាត់ជម្ងឺស្អូចនៅឆ្នាំ២០២០
- បន្លឿននៃការប្រយុទ្ធប្រឆាំងនឹងជម្ងឺ រលាកខួរក្បាលជេអ៊ី (JE)
- បញ្ចូលវ៉ាក់សាំងថ្មីៗ ផ្អែកទៅលើភស្តុតាងវិសាស្រ្តជាមូលដ្ឋាន
- សំរេចអោយបានអត្រាគ្របដណ្តប់ DPT-Hep-B-Hib3 លើសពី៩៥ នៅនៅគ្រប់ស្រុកប្រតិបត្តិទាំងអស់ %

សៀវភៅនេះបកប្រែឡើងចេញពី Immunization in Practice, a practical guide for health staff 2015 updated របស់អង្គការសុខភាពពិភពលោក និង ធ្វើបច្ចុប្បន្នភាពតំរូវតម្រូវទៅតាមស្ថានភាពជាក់ស្តែង និងការរីកចំរើនកម្មវិធីជាតិផ្តល់ថ្នាំបង្ការ។គោលការណ៍ណែនាំនេះនឹងផ្តល់នូវចំណេះដឹងថ្មីៗបន្ថែមទៀតដល់មន្ត្រី និង បុគ្គលិកផ្តល់ថ្នាំបង្ការនៅគ្រប់លំដាប់ថ្នាក់ ព្រមទាំងមន្ត្រីនិងបុគ្គលិកសុខាភិបាលដែលពាក់ពន្ធ័ទាំងអស់ ដើម្បីធ្វើយ៉ាងណាអោយការអនុវត្តន៍សេវាផ្តល់ថ្នាំបង្ការរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការអោយមានប្រសិទ្ធិភាព ទទួលបាននូវគុណភាពខ្ពស់ ព្រមទាំងធ្វើអោយមាននិរន្តភាពចំពោះសកម្មភាពផ្តល់ថ្នាំបង្ការជាប្រចាំ ។ សៀវភៅដែលធ្វើបច្ចុប្បន្នភាពឡើងវិញនេះមាន៩ជំពូក៖

ជំពូកទី១ ៖ ជំងឺដែលអាចការពារបានដោយវ៉ាក់សាំង

ជំពូកទី ២ ៖ ការរៀបចំទិវាផ្តល់ថ្នាំបង្ការ

ជំពូកទី ៣ ៖ វ៉ាក់សាំងរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ និង ប្រព័ន្ធត្រជាក់

ជំពូកទី ៤ ៖ ការផ្តល់ថ្នាំបង្ការប្រកបដោយសុវត្ថិភាព និង ហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ

ជំពូកទី ៥ ៖ ការណែនាំអំពីរបៀបកត់ត្រា

ជំពូកទី ៦ ៖ តាមដានវាយតំលៃអត្រាគ្របណ្តប់នៃការផ្តល់ថ្នាំបង្ការ-និង ការតាមដានស្រាវជ្រាវជំងឺដែលអាចការពារបានដោយវ៉ាក់សាំង

ជំពូកទី ៧ ៖ ការអប់រំសុខភាពសហគមន៍

# ជំពូកទី១៖

# ជំងឺដែលអាចការពារបាន ដោយវ៉ាក់សាំង

# ១. ជំងឺខាន់ស្លាក់ ( Diphtheria )

## ១.១. តើ ជំងឺខាន់ស្លាក់ គឺជាអ្វី ?

ជំងឺខាន់ស្លាក់ គឺបណ្តាលមកពីមេរោគបាក់តេរី Corynebacterium diphtheria មេរោគនេះគឺវាធ្វើអោយមានការឈឺចាប់ហើយនិងបង្កើតជាតិពុលនៅក្នុងរាងកាយ ជាលិកា ហើយនិងសរីរាង្គដ៏ទៃទៀត ។ ប្រភេទទីមួយនៃជំងឺខាន់ស្លាក់នេះគឺវាមានឥទ្ធិពលទៅលើបំពង់ក ហើយជួនកាលទៅលើអាមីដាល ។ ប្រភេទជំងឺខាន់ស្លាក់មួយប្រភេទទៀតច្រើនតែកើតនៅតំបន់ក្តៅគឺវាធ្វើអោយស្បែកមានដំបៅ ។

ជំងឺខាន់ស្លាក់វាមានឥទ្ធិពលទៅលើមនុស្សគ្រប់អាយុទាំងអស់ប៉ុន្តែភាគច្រើនវាច្រើនតែកើតទៅលើកុមារណាដែលមិនបានទទួលថ្នាំបង្ការ ។ ទាក់ទងទៅនិងធាតុអាកាស ជំងឺខាន់ស្លាក់ច្រើនតែកើតនៅខែត្រជាក់ ។

## ១.២. តើជំងឺខាន់ស្លាក់ឆ្លងដូចម្តេច ?

**ជំងឺខាន់ស្លាក់** ឆ្លងពីរមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយៈការដកដង្ហើមហើយ និង ការប៉ះពាល់ផ្ទាល់។ វាធ្វើការបង្ករោគនៅពីខាងក្រោយនៃរន្ធច្រមុះ ហើយនិងធ្វើអោយមានការពិបាកក្នុងការដកដង្ហើម និងអាចបណ្តាល អោយស្លាប់ ។

## ១.៣. តើរោគសញ្ញានិងអាការៈរោគរបស់ជំងឺខាន់ស្លាក់គឺជាអ្វី ?

នៅពេលជំងឺខាន់ស្លាក់កើតទៅលើបំពង់កហើយនិងអាមីដាល រោគសញ្ញាដំបូងរបស់វាគឺ ធ្វើអោយឈឺបំពង់ក បាយមិនបាន និង មានគ្រុនតិចតួច ។ ក្នុងរយៈពេលពី ពីរទៅបីថ្ងៃគឺ មានភ្នាសពណ៌ខៀវ-ស ឬក៏ប្រផេះ នៅក្នុងបំពង់កហើយ និង អាមីដាល ។ ភ្នាសនេះស្អិតជាប់ទៅនិងផ្ទៃកទន់ៗនៃក្រអូមមាត់ខាងលើហើយអាចធ្វើអោយចេញឈាម ។ ប្រសិនបើមានឈាមភ្នាសនោះនិង អាចប្រែទៅជាពណ៌ខៀវប្រផេះឬក៏ខ្មៅ ។ អ្នកជំងឺដែលមានរោគសញ្ញាដូចចំណុចខាងលើនេះគឺមានអាការៈចុះខ្សោយ ហើយអ្នកជំងឺនោះនឹងអាចស្លាប់ក្នុងរយៈពី៦ទៅ១០ថ្ងៃ ។ អ្នកជំងឺដែលមានអាការៈរោគធ្ងន់ធ្ងរ នេះសំរាប់ការគ្រុនគឺមិនសូវខ្លាំងទេ ប៉ុន្តែអាចធ្វើអោយមានការហើមបំពង់ករួចហើយធ្វើអោយស្ទះផ្លូវដង្ហើម ។

## ១.៤. តើផលវិបាកនៃជំងឺខាន់ស្លាក់គឺជាអ្វី ?

**នៅក្នុងដំណាក់ការចាប់ផ្តើមឈឺដំបូង** ឬ ក៏បន្ទាប់ពីឈឺបានមួយសប្តាហ៏មក បេះដូងអ្នកជំងឺមានចលនាចង្វាក់ដើរខុសធម្មតាហើយនៅពេលដែលចង្វាក់បេះដូងដើរខុសធម្មតា ពេលនោះគឺវាអាចនឹងធ្វើអោយបេះដូងរីក ។ អ្នកជំងឺខ្លះដែលធ្លាប់មានជំងឺខាន់ស្លាក់ ផលវិបាករបស់វា គឺធ្វើអោយរលាកសាច់ដុំបេះដូងហើយនិង សន្ទះចលនានៃបេះដូង ប្រសិនបើជំងឺនេះក្លាយទៅជាជំងឺរ៉ាំរ៉ៃ ជំងឺនេះនឹងវិវត្តទៅជាជំងឺបេះដូងរីកហើយផលវិបាកធ្ងន់ធ្ងរបំផុតរបស់ជំងឺខាន់ស្លាក់គឺធ្វើអោយស្ទះផ្លូវដកដង្ហើមហើយ ស្លាប់។

## ១.៥. តើជំងឺខាន់ស្លាក់ត្រូវការអ្វីសំរាប់ព្យាបាល ?

**កុមារដែលមានជំងឺខាន់ស្លាក់** ត្រូវតែផ្តល់ថ្នាំសំរាប់ប្រឆាំងនិងមេរោគជំងឺខាន់ស្លាក់ ដោយប្រើឱសថអង់ទីបីយ៉ូទីកដូចជាErytromycine ឬ Penicilline ។ ត្រូវរក្សាអ្នកជំងឺអោយនៅឆ្ងាយពីគេ ជៀសវាងការចំលងរោគពីអ្នកជំងឺទៅអ្នកដទៃទៀត ។ ប្រហែលជា២ថ្ងៃបន្ទាប់ពីបានព្យាបាលជាមួយឱសថអង់ទីបីយ៉ូទីករួចមក អ្នកជំងឺមិនមានការបង្ករោគទៀតទេ សំរាប់ការបញ្ជាក់រោគវិនិច្ឆ័យវិញ បុគ្គលិកសុខាភិបាលត្រូវតែយកវត្ថុវិភាគពីបំពង់កអ្នកជំងឺដែលសង្ស័យថាជាជំងឺខាន់ស្លាក់ដើម្បីបញ្ជាក់អោយបានច្បាស់ ថាតើមានវត្តមានមេរោគខាន់ស្លាក់ដែរឬអត់។ ទោះបីជាយ៉ាងណាការព្យាបាលត្រូវតែចាប់ផ្តើមដោយមិនត្រូវរង់ចាំនូវលទ្ធផលពីវត្ថុវិភាគទេ។

## ១. ៦. តើជំងឺខាន់ស្លាក់ត្រូវការអ្វីដើម្បីការពារ ?

**មធ្យោបាយដ៏ល្អបំផុតសំរាប់ការពារជំងឺខាន់ស្លាក់** គឺការផ្តល់ថ្នាំបង្ការជាមធ្យោបាយមួយដ៏ពិសេសបំផុតសំរាប់ការពារកុំអោយកើតជំងឺនេះ ដូចនេះត្រូវការអត្រាគ្របដណ្តប់វ៉ាក់សាំងការពារជំងឺខាន់ស្លាក់អោយបានគ្រប់ដូស (៣ដូស) និង ខ្ពស់បំផុត (លើសពី៩៥%) ទៅដល់សហគមន៍ ។

នៅគ្រប់ប្រទេសកម្ពុជានៅក្នុងពេលបច្ចុប្បន្ននេះប្រទេសប្រើវ៉ាក់សាំងដែលមានរួមបញ្ចូលគ្នាសំរាប់ការពារជំងឺខាន់ស្លាក់ តេតាណូស ក្អកមាន់ រលាកថ្លើម ប្រភេទបេ និង ហ៊ីប (DPT-Hep B-Hib) ។

### ចំណុចសំខាន់នៃជំងឺខាន់ស្លាក់ ៖

- ជំងឺខាន់ស្លាក់គឺឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយៈដំណក់ទឹកទៅក្នុងលំហរអាកាស។
- រោគសញ្ញាគឺឈឺបំពង់ក បាយមិនបាន ហើយនិង មានគ្រុនតិចៗ។
- អ្នកជំងឺខ្លះ ដែលធ្លាប់មានជំងឺខាន់ស្លាក់ផលវិបាករបស់វាគឺរលាកសាច់ដុំបេះដូង និងសន្ទះបេះដូង។
- កុមារដែលកើតជំងឺខាន់ស្លាក់ត្រូវតែព្យាបាលឱសថប្រឆាំងនិងមេរោគខាន់ស្លាក់ ហើយនិងឱសថអង់ទីបីយ៉ូទីក (Antbiotic) ។
- មធ្យោបាយដ៏ល្អបំផុតសំរាប់ការពារជំងឺខាន់ស្លាក់ គឺការផ្តល់ថ្នាំបង្ការជាមធ្យោបាយមួយដ៏ពិសេសបំផុតសំរាប់ការពារកុំអោយកើតជំងឺនេះ ដូចនេះត្រូវការអត្រាគ្របដណ្តប់វ៉ាក់សាំងការពារជំងឺខាន់ស្លាក់អោយបានគ្រប់ដូស (៣ដូស) និង ខ្ពស់បំផុត (លើសពី៩៥%) ទៅដល់សហគមន៍ ។ នៅគ្រប់ប្រទេសកម្ពុជានៅក្នុងពេលបច្ចុប្បន្ននេះប្រទេសប្រើវ៉ាក់សាំងដែលមានរួមបញ្ចូលគ្នាសំរាប់ ការពារជំងឺខាន់ស្លាក់ តេតាណូស ក្អកមាន់ រលាកថ្លើម ប្រភេទបេ និង ហ៊ីប (DPT-Hep B-Hib) ។

# ២. ជំងឺក្អកមាន់(Pertussis)

## ២.១. តើ ជំងឺក្អកមាន់ គឺជាអ្វី?

**ជំងឺក្អកមាន់** គឺជាជំងឺប្រព័ន្ធផ្លូវដកដង្ហើម ហើយនិងបណ្តាលមកពីមេរោគបាក់តេរី(Bordella pertussis bacteria) ដែលរស់នៅក្នុងមាត់ ច្រមុះហើយនិង បំពង់ក ។ ពិព្រោះជំងឺនេះវាមានការឆ្លងខ្លាំង និងមានគ្រោះថ្នាក់ណាស់ចំពោះទារកដែលមិនបានទទួលថ្នាំបង្ការ ។ ជំងឺនេះនៅតែជាបញ្ហាសុខភាពសាធារណៈនៅក្នុងពិភពលោកនៅក្នុងនោះរាប់បញ្ចូលទាំងប្រទេសដែលមានអត្រាគ្របដណ្តប់វ៉ាក់សាំងខ្ពស់ផងដែរ។

## ២.២. តើជំងឺក្អកមាន់ឆ្លងដូចម្តេច?

**ជំងឺក្អកមាន់** គឺវាមានភាពងាយស្រួលណាស់ក្នុងការចំលងពីកុមារម្នាក់ទៅកុមារម្នាក់ទៀតតាមរយៈដំណក់ទឹកមាត់ដែលក្អកឬក្រដាស។ ចំពោះអ្នកជំងឺណាដែលមិនបានព្យាបាល វាអាចឆ្លងរាតត្បាតទៅមនុស្សផ្សេងទៀតយ៉ាងឆាប់រហ័ស និង មានរយះពេលនៃការចម្លងយូរ ធម្មតាវាអាចចម្លងរហូតទៅដល់បីសប្តាហ៍បន្ទាប់ពីចាប់ផ្តើមក្អក។ នៅក្នុងប្រទេសជាច្រើនជំងឺនេះផ្ទុះរាតត្បាតជារៀងរាល់៣ឆ្នាំទៅ៥ឆ្នាំម្តង។

## ២.៣. តើរោគសញ្ញានិងអាការៈរោគរបស់ជំងឺក្អកមាន់គឺជាអ្វី?

**រយៈពេលបង្ករោគ** គឺប្រហែល១០ថ្ងៃបន្ទាប់ឆ្លងជំងឺនេះ សញ្ញាដំបូងរបស់វាគឺធ្វើអោយកុមារមានជំងឺផ្តាសសាយហើយ និង ហៀរសំបោ ហៀរទឹកភ្នែក ក្រដាស គ្រុន ហើយមានក្អកតិចតួច ។ ក្អកចាប់ផ្តើមបន្តិចម្តងៗ ហើយនិងចាប់ផ្តើមក្អកញាប់ជាប់បន្ត ។ នៅពេលឈប់ក្អកម្តងៗ កុមារត្រូវដក់ដង្ហើមចូលពេលនោះនិងមានសម្លេងឮដូចជាដកចង្ការមាន់ ។ នៅពេលកំពង់ក្អកខ្លួនកុមារអាចប្រែពណ៌ទៅជាពណ៌ខៀវពីព្រោះគេមិនបានទទួលនូវខ្យល់ឧស៊ីហ្សែនគ្រប់គ្រាន់ក្នុងពេលដែលគេកំពង់ក្អក ។ ការក្អួតហើយនិងអស់កំលាំងគឺយោងទៅតាមការក្អក ជាពិសេសការក្អកខ្លាំងគឺនៅពេលយប់ ។

## ៣.៤.តើផលវិបាកនៃជំងឺក្អកមាន់គឺជាអ្វី?

**ជំងឺរលាកសួត** គឺជាផលវិបាកសំខាន់ជាងគេនៃជំងឺក្អកមាន់ ។ វាត្រូវបានរកឃើញករណីនេះកើតមានប្រមាណ៦%នៃករណីជំងឺនេះនៅក្នុងប្រទេសឧស្សាហកម្ម ។ ហានិភ័យនៃជំងឺរលាកសួតគឺកើតមានចំពោះទារកដែលមានអាយុក្រោម៦ខែហើយអាចមានរហូតដល់ទៅបួនដងខ្ពស់ជាងកុមារដែលមានវ័យចំណាស់។ កុមារដែលធ្លាប់មានផលវិបាកដូចជា បាត់បង់ស្មារតី ហើយនិងប្រកាច់ ដោយសារគ្រុនក្តៅ ឬក៏គ្មានអ៊ុកស៊ីហ្សែនគ្រប់គ្រាន់ដើម្បីផ្តល់ទៅអោយខួរក្បាល នេះគឺជាមូលហេតុដែលបណ្តាល មកពីការក្អក ។

## ៣.៥. តើជំងឺក្អកមាន់ត្រូវការអ្វីសំរាប់ព្យាបាល?

**ជំងឺក្អកមាន់** គឺត្រូវការព្យាបាលដោយឱសថអង់ទីបីយ៉ូទីក ជាធម្មតាប្រើឱសថអ៊ីរីត្រូមីស៊ីនដើម្បីកាត់បន្ថយនូវការឈឺធ្ងន់ធ្ងរ ។ ពីព្រោះថ្នាំអង់ទីបីយ៉ូទីកសំលាប់មេរោគបាក់តេរីដែលមាននៅក្នុងច្រមុះហើយនិងបំពង់ក ហើយការប្រើថ្នាំអង់ទីបីយ៉ូទីកនេះគឺចងកាត់បន្ថយនូវការចំលងមេរោគជំងឺក្អកមាន់ពីអ្នកជំងឺទៅដល់អ្នកដ៏ទៃទៀត ។

## ៣.៦. តើជំងឺក្អកមាន់ត្រូវការអ្វីដើម្បីការពារ ?

ការការពារគឺត្រូវផ្តល់វ៉ាក់សាំងការពារជំងឺក្អកមាន់ដែលជាធម្មតាវ៉ាក់សាំងនេះគឺគេដាក់បញ្ចូលជាមួយវ៉ាក់សាំងការពារជំងឺខាន់ស្លាក់និងតេតាណូស (DPT)។ នៅពេលបច្ចុប្បននេះមានប្រទេសកម្ពុជា ប្រើវ៉ាក់សាំងដែលបញ្ចូលគ្នាសំរាប់ការពារជំងឺ ខាន់ស្លាក់ តេតាណូស ក្អកមាន់, រលាកថ្លើមប្រភេទបេ ហើយមានវ៉ាក់សាំងការពារជំងឺហ៊ីបប្រភេទបេ ( DPT-Hep B-Hib) សំរាប់ការពារជំងឺក្អកមាន់ ។

### ចំណុចសំខាន់នៃជំងឺក្អកមាន់៖

- ជំងឺក្អកមាន់គឺជាជំងឺប្រព័ន្ធផ្លូវដកដង្ហើម ។
- ជំងឺក្អកមាន់គឺវាបណ្តាលមកពីមេរោគបាក់តេរីដែលវាអាចចំលងពីមនុស្ស ម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយៈក្អកឬក្រដាស។
- ទារកហើយនិងកុមារគឺងាយឆ្លងជំងឺនេះណាស់ហើយ ព្រមទាំងធ្វើអោយ មានផលវិបាកធ្ងន់ធ្ងរ ហើយនិងអាចស្លាប់ដោយសារជំងឺនេះ។
- មធ្យោបាយដែលមាន ប្រសិទ្ធិភាពសំរាប់ការពារជំងឺក្អកមាន់គឺត្រូវយកកុមារទាំអស់ចាក់វ៉ាក់សាំងការពារជំងឺក្អកមាន់( DPT-Hep B-Hib) ។

# ៣. ជំងឺគ្រុនស្វិតដៃជើង (ប៉ូលីយ៉ូ)
# (Poliomyelitis, Acute Placid Paralysis -AFP)

## ៣.១. តើជំងឺគ្រុនស្វិតដៃជើង(ប៉ូលីយ៉ូ) គឺជាអ្វី ?

**ជំងឺគ្រុនស្វិតដៃជើង** គឺជាជំងឺឆ្លងមួយប្រភេទដែលបង្កឡើងដោយមេរោគប៉ូលីយ៉ូ ។ ជំងឺនេះបណ្តាលមកពីវីរុសដែលមាន៣ ប្រភេទហើយក្នុងចំណោមវីរុស៣ប្រភេទ ប្រភេទទី១ (WPV1) ប្រភេទទី២ (WPV2) និង ប្រភេទទី៣ (WPV3) ។ មេរោគទាំងនេះគេហៅមេរោគប៉ូលីយ៉ូ (WPVs) ចាប់តាំងពីវាកើតឡើងដោយធម្មជាតិវាឆ្លងនិងបង្ករជាជំងឺចំពោះមនុស្សគ្រប់រូប ។ ភាគច្រើននៃជំងឺគ្រុនស្វិតដៃជើងវាកើតមានចំពោះកុមារដែលមានអាយុតិចជាងប្រាំឆ្នាំ ។ មួយក្នុងចំណោម២០០ករណីដែលបានឆ្លងមេរោគប៉ូលីយ៉ូនេះវាបង្ករអោយខ្វិន ហើយការខ្វិននេះវាបណ្តាលមកពីមេរោគប៉ូលីយ៉ូលុកលុយ ឬវាយប្រហារទៅលើកោសិកាសំខាន់ៗនៃសរសៃពួរនៃប្រសាទខួរឆ្អឹងខ្នង ដែលសរសៃពួរនៃប្រសាទខួរឆ្អឹងខ្នងទាំងនេះវាជាអ្នកគ្រប់គ្រង ឬ បញ្ជារាល់ចលនាទាំងឡាយនៃសាច់ដុំ។

**គំនិតផ្តួចផ្តើមយុទ្ធនាការជាសកលស្តីការលុបបំបាត់ជំងឺគ្រុនស្វិតដៃជើង**មួយត្រូវបានសម្ពោធ និង ដាក់អោយដំណើរការនៅឆ្នាំ១៩៨៨មក ចំនួនករណីនៃជំងឺគ្រុនស្វិតដៃជើងនៅបណ្តាប្រទេសនានានៅក្នុងពិភពលោកមានការចុះថយយ៉ាងខ្លាំង ជាអាទថយចុះពី១២៥ករណីទៅ៣ករណីនៅឆ្នាំ២០១៥ ។

## ៣.២. តើជំងឺគ្រុនស្វិតដៃជើងឆ្លងដូចម្តេច?

**ជំងឺគ្រុនស្វិតដៃជើង** ឆ្លងតាមរយៈលាមកចូលតាមមាត់ (វីរុសឆ្លងចូលទៅក្នុងរាង្គកាយតាមមាត់នៅពេលដែលមនុស្សយើងបរិភោគឬ ក៏ផឹកទឹកដែលមានមេរោគប៉ូលីយ៉ូនោះវាត្រូវបានចំលងមកពីលាមក)។ វីរុសនេះវាធ្វើការបំលែងខ្លួននៅក្នុងពោះវៀនហើយចូលទៅក្នុងសរសៃឈាម វាក៏អាចចូលទៅក្នុងកោសិកាសរសៃប្រសាទ នៅពេលនោះវាធ្វើអោយខូចសរសៃប្រសាទ។ វីរុសប៉ូលីយ៉ូនេះវាមានការងាយស្រួលក្នុងការចំលងណាស់ ជាពិសេសនៅក្នុងដំបន់ដែលគ្មានអនាម័យ។ អ្នកជំងឺគ្រុនស្វិតដៃជើងភាគច្រើនមិនមានចេញរោគសញ្ញា ទេប៉ុន្តែពួកគេអាចចំលងនូវជំងឺនេះបាន។

## ៣.៣. តើរោគសញ្ញានិងអាការៈរោគរបស់ ជំងឺគ្រុនស្វិតដៃជើងគឺជាអ្វី?

បន្ទាប់ពីការឆ្លងវីរុសប៉ូលីយ៉ូ (poliovirus) ប្រមាណជា៧៥%នៃអ្នកជំងឺដែលឆ្លងវីរុសប៉ូលីយ៉ូនេះមានការបង្ហាញនូវរោគសញ្ញាតិចតួចបំផុត(ឈឺតិចតួច) ជាធម្មតារោគសញ្ញាបង្ហាញនូវការក្តៅខ្លួន ឈឺក្បាល និងឈឺក។ អត្រាខ្វិនកើតឡើងប្រមាណជា១%នៃអ្នកដែលឆ្លងវីរុសប៉ូលីយ៉ូនេះ រីឯអត្រាស្លាប់មានប្រមាណ៥-១០%នៃអ្នកជំងឺដែលខ្វិន។

## ៣.៤. តើផលវិបាកនៃ ជំងឺគ្រុនស្វិតដៃជើង គឺជាអ្វី ?

**អ្នកជំងឺគ្រុនស្វិដៃជើង** អាចស្លាប់បានប្រសិនបើសាច់ដុំទ្រូងឆ្លងជំងឺនេះ និង ប្រសិនបើគ្មានប្រដាប់ដកដង្ហើមជំនួយទេ។ ប្រសិនជាគ្មានការធ្វើចលនាបានគ្រប់គ្រាន់ទេ អវៈយវៈ មិនអាចកំរើកបានទេហើយ កុមារនិងអាចពិការអស់មួយជីវិត។

## ៣.៥. តើជំងឺគ្រុនស្វិតដៃជើងត្រូវការអ្វីសំរាប់ព្យាបាល ?

**គ្មានថ្នាំព្យាបាលជំងឺគ្រុនស្វិតដៃជើងទេ** គឺមានព្យាបាលតាមរោគសញ្ញាដូចជាឈឺសាច់ដុំ ហើយ និង គ្រុនគឺការឈឺចាប់ជាដើម ប្រើប្រាស់ប្រដាប់សំរាប់ជួយដកដង្ហើមទេដែលអាចជួយអ្នកជំងឺបាននៅពេលណាដែលអ្នកជំងឺមានការពិបាកដកដង្ហើម។ ជាធម្មតាការព្យាបាលជំងឺគ្រុនស្វិដៃជើងដោយការធ្វើចលនា ដោយការវះកាត់យកដែកអបដើម្បីជួយកាត់បន្ថយនូវភាពពិការក្នុងរយៈពេលយូរដោយសារជំងឺគ្រុនស្វិតដៃជើង។

## ៣.៦. តើជំងឺគ្រុនស្វិតដៃជើងត្រូវការអ្វីដើម្បីការពារ

ជំងឺគ្រុនស្វិតដៃជើងគឺអាចការពារបានតាមរយៈការផ្តល់ថ្នាំបង្ការគឺវ៉ាក់សាំងប៉ូលីយ៉ូបណ្តក់(OPV)បីដងនិងបន្ថែមវ៉ាក់សាំងប៉ូលីយ៉ូចាក់(IPV)មួយដង ។ វ៉ាក់សាំងប៉ូលីយ៉ូគឺត្រូវបានផ្តល់អនុសាសន៍អោយប្រើសំរាប់ការផ្តល់ថ្នាំបង្ការជាប្រចាំនិងការផ្តល់បន្ថែមដោយយុទ្ធនាការលុបបំបាត់ជំងឺគ្រុនស្វិតដៃជើង។

### ចំណុចសំខាន់នៃជំងឺគ្រុនស្វិតដៃជើង (ប៉ូលីយ៉ូ) ៖

- ❖ ជំងឺគ្រុនស្វិតដៃជើងគឺជាជំងឺមួយដែលបណ្តាលមកពីមេរោគវីរុសហើយវីរុសនោះគឺមានបីប្រភេទ ប្រភេទទី១ ប្រភេទទី២ និងប្រភេទទី៣។
- ❖ ជំងឺគ្រុនស្វិតដៃជើង ឆ្លងតាមរយៈលាមកចូលតាមមាត់ (វីរុសឆ្លងចូលទៅក្នុងរាង្គកាយតាមមាត់នៅពេលដែលមនុស្សយើងបរិភោគឬ ក៏ផឹកទឹកដែលមានមេរោគប៉ូលីយ៉ូនោះវាត្រូវបានចំលងមកពីលាមក)។ វីរុសនេះវាធ្វើការបំផ្លែងខ្លួននៅក្នុងពោះវៀនហើយចូលទៅក្នុងសរសៃឈាម វាក៏អាចជ្រាតចូលទៅក្នុងកោសិកាសរសៃប្រសាទ នៅពេលនោះវាធ្វើអោយខូចសរសៃប្រសាទ។
- ❖ អ្នកជំងឺគ្រុនស្វិតដៃជើងភាគច្រើនមិនមានចេញរោគសញ្ញា ទេប៉ុន្តែពួកគេអាចចំលងនូវជំងឺនេះបាន។
- ❖ បន្ទាប់ពីការឆ្លងវីរុសប៉ូលីយ៉ូ(poliovirus)ប្រមាណជា២៥%នៃអ្នកជំងឺដែលឆ្លងវីរុសប៉ូលីយ៉ូនេះ មានការបង្ហាញនូវរោគសញ្ញាតិចតួចបំផុត(ឈឺតិចតួច) ជាធម្មតារោគសញ្ញាបង្ហាញនូវការក្តៅខ្លួន ឈឺក្បាល និងឈឺក។ អត្រាខ្វិនកើតឡើងប្រមាណជា១%នៃអ្នកដែលឆ្លងវីរុសប៉ូលីយ៉ូនេះ រីឯអត្រាស្លាប់មានប្រមាណ៥-១០%នៃអ្នកជំងឺដែលខ្វិន។
- ❖ តាមអនុសាសន៍របស់អង្គការសុខភាពពិភពលោក ជំងឺគ្រុនស្វិដៃជើងអាចការពារបានតាមរយៈការផ្តល់ថ្នាំបង្ការគឺវ៉ាក់សាំងប៉ូលីយ៉ូបណ្តក់(OPV)បីដងនិងបន្ថែមវ៉ាក់សាំងប៉ូលីយ៉ូចាក់(IPV)មួយដង។

# ៤. ជំងឺកញ្ជ្រឹល (Measles )

## ៤.១. តើជំងឺកញ្ជ្រឹលគឺជាអ្វី ?

**ជំងឺកញ្ជ្រឹល** គឺជាជំងឺមួយដែលមានអត្រាឆ្លងខ្ពស់ ដែលបង្កឡើងដោយវីរុស។ វានៅតែបុព្វហេតុសំខាន់ក្នុងការស្លាប់ចំពោះកុមារដែលមានវ័យក្មេងនៅទូទាំងពិភពលោក បើទោះបីជាអាចរកបាននូវវ៉ាក់សាំងដែលមានសុវត្ថិភាពនិងប្រសិទ្ធភាពក៏ដោយ ។ ជាង៩៥%នៃការស្លាប់ដោយសារជំងឺកញ្ជ្រឹលគឺកើតមាននៅលើប្រទេសដែលមានប្រាក់ចំណូលទាប និង ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលនៅទន់ខ្សោយ ។ ដោយសារតែជំងឺនេះគឺជាជំងឺឆ្លងរាតត្បាតខ្ពស់ ដូច្នេះវាច្រើនតែកើតមានឡើង និង ឆ្លងរីករាលដាលជាមួយនឹងអត្រាស្លាប់ខ្ពស់នៅក្នុងស្ថានភាពភូមិសាស្ត្រការកំណត់មួយដូចជានៅក្នុងជំរំជនភៀសខ្លួន ។ ចំពោះករណីធ្ងន់ធ្ងរនៃជំងឺកញ្ជ្រឹលគឺកើតមានចំពោះកុមារដែលកង្វះអាហារូបត្ថម្ភ ជាពិសេសអ្នកដែលមិនបានទទួលវីតាមីនអា គ្រប់គ្រាន់ដែលរស់នៅក្នុងលក្ខខណ្ឌដែលមានមនុស្សច្រើនរស់នៅ និង មនុស្សដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ ដូចជាអ្នកមានផ្ទុកមេរោគអេដស៍ / ជំងឺអេដស៍ ឬ ជំងឺផ្សេងទៀត។

នៅខែមីនាឆ្នាំ២០១៥គណៈកម្មាធិការវាយតម្លៃការលុបបំបាត់ជំងឺកញ្ជ្រឹលប្រចាំតំបន់បានបញ្ជាក់ថាប្រទេសចំនួន៧ក្នុងចំណោម៣៧ប្រទេស ក្នុងតំបន់អាស៊ីប៉ាស៊ី ហ្វិកខាងលិចបានសម្រេចលុបបំបាត់ជំងឺកញ្ជ្រឹលទាំងស្រុងដែលក្នុងនោះមានប្រទេសកម្ពុជាផងដែរ ។ ករណីជំងឺកញ្ជ្រឹលចុងក្រោយដែលបានរកឃើញនៅប្រទេសកម្ពុជាគឺនៅក្នុងខែ វិច្ឆិកាឆ្នាំ ២០១១ ។

## ៤.២. តើជំងឺកញ្ជ្រឹលឆ្លងដូចម្តេច ?

ជំងឺកញ្ជ្រឹលឆ្លងតាមលំហអាកាសនិងតាមរយៈកំទេចទឹកមាត់របស់អ្នកជំងឺកញ្ជ្រឹលដែលបានក្អកឬកណ្តាសហើយហើរចូលទៅតាមប្រព័ន្ធដកដង្ហើមឬក៏ប៉ះពាល់ផ្ទាល់ជាមួយសំបោរឬកំហាករបស់អ្នកជំងឺដែលមានផ្ទុកមេរោគកញ្ជ្រឹល។ទាំងមុនពេល ហើយនិងទាំងក្រោយពេលអ្នកជំងឺចេញរោគសញ្ញា អ្នកជំងឺកញ្ជ្រឹលអាចចំលងទៅអ្នកដ៏ទៃទៀតបាន។ ជំងឺនេះគឺមានការងាយស្រួលក្នុងការចំលងណាស់ជាពិសេសគឺកន្លែងណាដែលមានទារកហើយនិងកុមាររស់នៅជុំគ្នាច្រើន លេងជាមួយគ្នា ឧទាហរណ៍ ដូចជានៅគ្រឹះស្ថានសុខាភិបាល ហើយនិងសាលារៀនជាដើម។

## ៤.៣. តើរោគសញ្ញានិងអាការៈរោគរបស់ជំងឺកញ្ជ្រឹលគឺជាអ្វី?

**សញ្ញាដំបូងនៃជំងឺកញ្ជ្រឹល** គឺគ្រុនក្តៅខ្ពស់ដែលបានចាប់ផ្តើមប្រមាណ១០ ទៅ១២ ថ្ងៃបន្ទាប់ពីការការប៉ះពាល់ទៅនឹងជំងឺកញ្ជ្រឹលនិងគ្រុនក្តៅខ្ពស់នៃនេះបន្តរយៈពេលជាច្រើនថ្ងៃ ក្នុងអំឡុងពេលនេះអ្នកជំងឺអាចអភិវឌ្ឍន៍ ហៀរសំបោរ ក្អក ភ្នែកក្រហមនិងស្នាមអុជៗពណ៌សឬលាយខៀវ (Koplik's spots)ចេញនៅលើភ្នាសនៃក្រអូមមាត់ មួយថ្ងៃមុនចាប់ផ្តើមចេញកន្ទួលក្រហម។ ពី៧ ទៅ ១៨ថ្ងៃបន្ទាប់ពីការការប៉ះពាល់ទៅនឹងជំងឺ

កញ្ជ្រឹល រោគសញ្ញាកន្ទួលក្រហមក៏ចាប់ផ្តើមលិចចេញបន្តិចម្តងៗ បន្ទាប់មកចេះតែមានការរីករាលដាល ធម្មតាចេញនៅលើផ្ទៃមុខហើយនិងកញ្ចឹងក ។ ៣ថ្ងៃក្រោយមកកន្ទួលក្រហមក៏ចាប់ផ្តើមចេញទៅលើដងខ្លួននិងបន្ទាប់មកនៅលើដៃហើយនិងជើង បន្ទាប់នេះប្រមាណពីប្រាំទៅប្រាំមួយថ្ងៃកន្ទួលក្រហមក៏ចាប់ផ្តើមជាសះស្បើយ ។

## ៤.៤. តើផលវិបាកនៃជំងឺកញ្ជ្រឹលគឺជាអ្វី?

**កុមារដែលមានអាយុក្រោម៥ឆ្នាំ** ហើយមិនបានទទួលថ្នាំបង្ការ ជាពិសេសគឺទារកដែលត្រូវប្រឈមនិងគ្រោះថ្នាក់ខ្ពស់ជាងគេបំផុតដោយសារផលវិបាកនៃជំងឺកញ្ជ្រឹលនេះ រួមជាមួយការស្លាប់ផងដែរ ។ ទារកដែលមានជំងឺកញ្ជ្រឹលអាចបង្ករអោយមានជំងឺរាគធ្ងន់ធ្ងរដោយសារការបាត់បង់ជាតិទឹកច្រើន ក្រៅពីនេះគេសង្កេតឃើញមានជំងឺរលាកត្រចៀកកណ្តាល រលាកខួរក្បាល និងធ្វើអោយមានជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរទៀតផង។ជំងឺកញ្ជ្រឹលគឺជាមូលហេតុចម្បងមួយដែលធ្វើអោយកុមាររស់នៅក្នុងដំបន់អាហ្វ្រិក និង នៅក្នុងតំបន់មួយចំនួនទៀតលើពិភពលោកដែលមានការរាតត្បាតដោយជំងឺកញ្ជ្រឹលខ្លាំងក្លា កើតមានជំងឺខ្វាក់ភ្នែក ។ ជំងឺរលាកសួតគឺជាមូលហេតុមួយដែលបណ្តាលធ្វើអោយកុមារស្លាប់ពីព្រោះវាគឺជាផលវិបាករបស់ជំងឺកញ្ជ្រឹលឬក៏អាចបណ្តាលមកពីបាក់តេរីដែលជាអ្នកចម្លងទីពីរ។

## ៤.៥. តើជំងឺកញ្ជ្រឹលត្រូវការអ្វីសំរាប់ព្យាបាល?

**មិនមានឱសថជាក់លាក់សំរាប់ព្យាបាលប្រឆាំងនឹងវីរុសជំងឺកញ្ជ្រឹលទេ**។ ជាទូទៅត្រូវផ្តល់អាហារបន្ថែមហើយនិងធ្វើការព្យាបាលទៅលើការខ្វះជាតិទឹកដោយចាំបាច់ធ្វើការផ្តល់អោយទឹកអូរ៉ាលីតទៅអោយកុមារផឹកអោយបានច្រើន។ សំរាប់ថ្នាំអង់ទីប៊ីយ៉ូទីកគឺសំរាប់ព្យាបាលទៅលើជំងឺរលាកត្រចៀកហើយ និងជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ។ វាមានសារៈសំខាន់ណាស់ក្នុងការផ្តល់អោយកុមារទទួលទានអាហារ និងផឹកទឹកអោយបានច្រើន។គ្រប់កុមារទាំងអស់ដែលរស់នៅក្នុងប្រទេសកំពង់អភិវឌ្ឍន៍ហើយមានរោគវិនិច្ឆ័យបញ្ជាក់ថាជាជំងឺកញ្ជ្រឹលត្រូវផ្តល់អោយថ្នាំវីតាមីនអា២ដូសនៅក្នុងរយៈពេល២៤ម៉ោង ។ **ការផ្តល់ថ្នាំវីតាមីនអា** គឺអាចជួយការពារនូវការខូចភ្នែក ហើយនិងខ្វាក់ភ្នែក ។ ការផ្តល់វីតាមីនអាបន្ថែមគឺអាចជួយកាត់បន្ថយនៅការស្លាប់ដោយសារជំងឺកញ្ជ្រឹលបាន៥០%។

### តារាងព្យាបាលដោយថ្នាំវីតាមីន អា ( Vitamin a treatment dosage )

| អាយុ | ការព្យាបាលភ្លាមៗទៅតាមរោគវិនិច្ឆ័យ | ថ្ងៃបន្ទាប់ | ការតាមដាន |
|---|---|---|---|
| ទារកអាយុក្រោម៦ខែ | 50 000 IU | 50 000 IU | ដូសទី៣ត្រូវផ្ដល់អោយបន្ទាប់សប្ដាហ៍ទី២-ទៅ៤ ប្រសិន បើមានសញ្ញាភ្នែកស្ងួត |
| ទារកអាយុ៦ខែឡើងទៅដល់១១ខែ | 100 000 IU | 100 000 IU | |
| កុមារដែលមានអាយុចាប់ពី១២ខែឡើងទៅ | 200 000 IU | 200 000 IU | |

## ៤.៦. តើជំងឺកញ្ជ្រឹលត្រូវការអ្វីដើម្បីការពារ ?

**ជំងឺកញ្ជ្រឹល** គឺត្រូវការពារតាមរយៈការផ្ដល់ថ្នាំបង្ការជំងឺកញ្ជ្រឹល។ ជំងឺកញ្ជ្រឹលគឺមានការចំលងខ្ពស់ណាស់ ដើម្បីកាត់បន្ថយនូវអត្រាគ្រោះថ្នាក់ដោយសារជំងឺកញ្ជ្រឹលកុមារទាំងអស់ត្រូវតែទទួលវ៉ាក់សាំងការពារជំងឺកញ្ជ្រឹល២ដូស។ នៅក្នុងមន្ទីរពេទ្យគ្រប់កុមារទាំងអស់ដែលបានចូលសំរាក់ក្នុងមន្ទីរពេទ្យ ហើយមានអាយុចាប់ពី៩ខែដែលមិនទាន់បានទទួលវ៉ាក់សាំងការពារជំងឺកញ្ជ្រឹល ត្រូវតែផ្ដល់អោយវ៉ាក់សាំងការពារជំងឺកញ្ជ្រឹលអោយ ទោះបីជាឪពុកម្ដាយរបស់កុមារមិនដឹងថាកូនរបស់គាត់បានទទួលឬក៏មិនបានទទួលក៏ដោយ ។ ប្រសិនបើកុមារបានទទួលវ៉ាក់សាំងការពារជំងឺកញ្ជ្រឹលដូសទី១នៅអាយុ៩ខែគឺណែនាំអោយកុមារមកទទួលកញ្ជ្រឹលដូសទី២បន្ទៀតនៅពេលកុមារមានអាយុ១៨ខែ។

## ៤.៧. បញ្ហាទប់ស្កាត់លើការរីករាលដាលនៃជំងឺទូទាំងសាកលលោក

ផែនការយុទ្ធសាស្ត្រជាសកលស្ដីពីជំងឺកញ្ជ្រឹលនិងស្អូច(២០១២-២០២០)ផ្ដោតលើសមាសភាគស្នូលចំនួន៥ គឺ :

- ❖ សម្រេចនិងរក្សាអោយបាននូវភាពស៊ាំខ្ពស់សហគន៍ខ្ពស់(លើសពី៩៥%)តាមរយៈការបង្កើនអត្រាគ្របដណ្ដប់វ៉ាក់សាំងការពារជំងឺកញ្ជ្រឹលទាំងពីរដូសទាំងដូសទី១និងដូសទី២។
- ❖ តាមដានស្រាវជ្រាវនិងត្រួតពិនិត្យ និងការវាយតំលៃស្ថានការណ៍ជំងឺកញ្ជ្រឹលជាប្រចាំ។
- ❖ ចងក្រងផែនការឆ្លើយតបជាបន្ទាន់និងការបង្កើនសមត្ថភាពគ្រប់គ្រងដែលទាក់ទងទៅនឹងឆ្លើយតបជាបន្ទាន់ក្នុងករណីមានការផ្ទុះជំងឺកញ្ជ្រឹល។
- ❖ ទំនាក់ទំនងជាមួយសារធារណៈជនទាំងផ្នែករដ្ឋ ទាំងឯកជន និងសហគមន៍ជាប្រចាំ និង កសាងភាពទំនុកចិត្តរបស់សារធារណៈជនទៅសកម្មភាពផ្ដល់ថ្នាំបង្ការដើម្បីអោយសារធារណៈជនចូលរួមនិងគាំទ្រទៅលើសកម្មភាពផ្ដល់ថ្នាំបង្ការ។

❖ បង្កើនការគាំទ្រដល់ប្រតិបត្តិការកម្មវិធី និង ការចំណាយមួយអោយមានប្រសិទ្ធិភាពទៅលើសកម្មភាពផ្តល់ថ្នាំបង្ការអោយទទួលបានជោគជ័យនិងផ្គត់ផ្គង់ឧបករណ៍ពេទ្យវិនិច្ឆ័យអោយមានគុណភាពនិងប្រសិទ្ធភាព។

**ចំណុចសំខាន់៖**

❖ ជំងឺកញ្ជ្រឹល គឺជាជំងឺមួយដែលមានអត្រាឆ្លងខ្ពស់។ ជំងឺកញ្ជ្រឹល គឺឆ្លងមនុស្សម្នាក់ទៅមនុស្សតាមការប៉ះពាល់ទៅលើវត្ថុរាវដែលចេញមកពីច្រមុះនិងបំពង់ករបស់អ្នកជំងឺហើយនិងតាមដំណក់ទឹកដែលហើរតាមលំហអាកាសតាមរយៈអ្នកជំងឺក្រដាស់ ឬក៏ក្អក ។

❖ ពី៧ ទៅ១៨ថ្ងៃបន្ទាប់ពីការការប៉ះពាល់ទៅនឹងជំងឺកញ្ជ្រឹលអ្នកជំងឺចេញរោគសញ្ញាកន្ទួលក្រហម

❖ ជំងឺរលាកសួតគឺជាមូលហេតុមួយដែលបណ្តាលធ្វើអោយកុមារស្លាប់ពីព្រោះវាគឺជាផលវិបាករបស់ជំងឺកញ្ជ្រឹលឬក៏អាចបណ្តាលមកពីមេរោគបាក់តេរី ដែលជាអ្នកចម្លងទីពីរ។

❖ ជំងឺកញ្ជ្រឹល គឺត្រូវការពារតាមរយៈការផ្តល់ថ្នាំបង្ការជំងឺកញ្ជ្រឹល។កុមារត្រូវតែទទួលវ៉ាក់សាំងការពារជំងឺកញ្ជ្រឹលទាំងពីរដូស(ដូសទី១ផ្តល់ដល់កុមារនៅអាយុ៩ខែ និងដូសទី២នៅ១៨ខែ)។

# ៥. ជំងឺស្អូច និង ជំងឺស្អូចពីកំណើត (Rubella and Congenital Rubella Syndrome)

## ៥.១.តើជំងឺស្អូចនិង ជំងឺស្អូចពីកំណើត គឺជាអ្វី?

**ជំងឺស្អូច**គឺជាជំងឺឆ្លងដែលបង្កឡើងដោយវីរុស និងជាធម្មតាស្ថានភាពនៃជំងឺនេះវាមានលក្ខណៈស្រាលចំពោះកុមារនិងមនុស្សពេញវ័យ ។ ជំងឺស្អូចពីកំណើត (CRS) គឺជាក្រុមមួយនៃជំងឺស្អូចដែលឆ្លងពីកំណើតគឺទារកឆ្លងជំងឺស្អូចពីម្តាយនៅពេលមានគភ៌។ ស្រ្តីមានផ្ទៃពោះភាគច្រើនឆ្លងមេរោគស្អូច នៅពេលរយៈពេលដំបូងនៃការមានមានគភ៌ (ត្រីមាសដំបូងនៃការចាប់ផ្តើមមានគភ៌) ហើយមានឱកាសចម្លងប្រមាណ៩០%ពីម្តាយដែលមានផ្ទៃពោះទៅឱ្យទារកក្នុងផ្ទៃ ព្រមទាំងវាក៏អាចធ្វើអោយទារកស្លាប់នៅក្នុងផ្ទៃ ដោយសារជំងឺស្អូចពីកំណើតទៀតផង មិនតែប៉ុណ្ណោះវាបង្កអោយមានការបង្ករកំណើតមិនប្រក្រតី ជាទូទៅវាបង្កអោយទារកដែលកើតមកថ្លង់ ស្តាប់សម្លេងមិនបាន ជំងឺបេះដូងពីកំណើត ជំងឺភ្នែកស្បែកបាំង/ភ្នែកឡើងបាយនិងរលាកខួរក្បាល។

## ៥.២. តើជំងឺស្អូចឆ្លងដូចម្តេច?

**វីរុសជំងឺស្អូច** ត្រូវបានចម្លងតាមរយៈការប៉ះពាល់ដោយផ្ទាល់ជាមួយកំទេចទឹកមាត់ឬស្លេះរបស់អ្នកជំងឺដែលបានក្អក ឬ កណ្តាស់ ឬ ការឆ្លងរីករាលដាលតាមរយៈការដកដង្ហើមចូលនៅពេលដែលអ្នកមានជំងឺបានក្អក ឬកណ្តាស់ទៅក្នុងខ្យល់ ។ វីរុសនេះរាលដាលនៅក្នុងរាង្គកាយនិងស្រ្តីមានផ្ទៃពោះ ឆ្លងពីម្តាយទៅទារកប្រមាណទៅប្រាំពីរថ្ងៃបន្ទាប់ពីឆ្លងមេរោគ។ ការឆ្លងរាលដាលជំងឺស្អូចពីមនុស្សម្នាក់ទៅមនុស្សម្នក់ទៀតខ្លាំងគឺឆ្លងនៅថ្ងៃចេញកន្ទួលក្រហមទី១ទៅដល់ ថ្ងៃទី៥ ប៉ុន្តែវាក៏អាចឆ្លងផងដែរគឺចាប់ពី៥ថ្ងៃមុននិង១៤ថ្ងៃបន្ទាប់ពីចេញកន្ទួលក្រហមលេចឡើង។ ទារកដែលមានមេរោគជំងឺស្អូចពីកំណើត (CRS) គឺអាចចម្លងមេរោគទៅគេក្នុងរយៈពេលពេញមួយឆ្នាំឬច្រើនជាងនេះ។

## ៥.៣. តើរោគសញ្ញានិងអាការៈរោគរបស់ ជំងឺស្អូចគឺជាអ្វី?

៧ថ្ងៃទៅ១៤ថ្ងៃក្រោយពីបានប៉ះពាល់នឹងមេរោគជំងឺស្អូច មានចេញសញ្ញាជំងឺស្អូចដំបូងគឺ គ្រុនក្តៅតិចតួច ភ្នែកក្រហម (ជាញឹកញាប់ច្រើនកើតមានចំពោះមនុស្សពេញវ័យ) និង កើតមានហើមកូនកណ្តុរនៅនិងក។ រយៈពេល៥ទៅ១០ថ្ងៃបន្ទាប់មកក៏ស្តែងចេញរោគសញ្ញាកន្ទួល ជារឿយៗកន្ទួលចាប់ចេញនៅលើផ្ទៃមុខបន្ទាប់មកនៅលើក្បាលនិងទីបញ្ចប់នៅជើង។ ជាធម្មតារោគសញ្ញាកន្ទួលនៃជំងឺស្អូចមានពណ៌ផ្កាឈូកហើយកន្ទួលនេះគឺវាមានលក្ខណៈខ្សោយជាងកន្ទួលកញ្ជ្រឹល ។ ជាធម្មតាកន្ទួលមានរយៈពេលពីមួយទៅបីថ្ងៃ តាមការសិក្សាបានបង្ហាញថាពី២០%ទៅ៥០%នៃជំងឺស្អូចមិនចេញរោគសញ្ញាកន្ទួលទេ និង លើសពី៧០%មនុស្សពេញវ័យនិងស្រ្តីពេញវ័យស្តែងចេញនូវរោគសញ្ញាឈឺចាប់សន្លាក់និងពិបាកដកដង្ហើម។

កុមារដែលមានមេរោគជំងឺស្អូចពីកំណើត (CRS) គឺជាធម្មតាកើតមកមានភាពមិនប្រក្រតី ដូចជា៖ ជម្ងឺភ្នែកស្បែកបាំង ភ្នែកឡើងបាយ cataracts និងស្តាប់សម្លេងមិនបាន ប៉ុន្តែករណីមួយចំនួនមិនបានបង្ហាញពីសញ្ញាក្នុងរយៈពេលពី២ទៅ៤ឆ្នាំ។ ជំងឺវិកលចរិតក៏អាចកើតមានផងដែរ។

## ៥.៤. តើផលវិបាកនៃ ជំងឺស្អូចគឺជាអ្វី?

**ផលវិបាកនៃជំងឺស្អូច**គឺច្រើនតែកើតទៅលើមនុស្សពេញវ័យជាងកុមារ។ ប្រហែលជា៧០%នៃស្រ្តីពេញវ័យដែលបានឆ្លងជំងឺស្អូចគឺអាចមានឈឺសន្លាក់ ឬ ក៏មានជំងឺរលាកសន្លាក់ជាពិសេសគឺទៅលើម្រាមដៃកដៃហើយនិងជង្គង់។សំរាប់ជំងឺរលាកស្រោមខួរក្បាលកើតឡើង១ក្នុងចំណោម៦០០០ករណីជាពិសេសច្រើនតែកើតទៅលើស្រ្តីពេញវ័យ។បញ្ហាធ្លាក់ឈាមគឺកើតឡើង១ក្នុងចំណោម៣០០០ករណីជាពិសេសទៅលើកុមារ ។ ជំងឺ Guillain-Barreត្រូវបានគេរាយការណ៍កម្រ។

## ៥.៥. តើជំងឺស្អូចត្រូវការអ្វីសំរាប់ព្យាបាល?

គ្មានឱសថព្យាបាលសំរាប់ជំងឺស្អូច ឬក៏ជំងឺស្អូចមកពីកំណើតទេ។ វិធានការព្យាបាលទៅតាមរោគសញ្ញាជាវិធានការជួយកាត់បន្ថយហានិភ័យនៃជំងឺ និង កាត់បន្ថយវិបាកនៃ ជំងឺស្អូច។

## ៥.៦. តើ ជំងឺស្អូចត្រូវការអ្វីដើម្បីការពារ?

**វ៉ាក់សាំងការពារជំងឺស្អូច** គឺមានប្រសិទ្ធិភាពហើយនិងសុវត្ថភាពណាស់សំរាប់ការផ្តល់វ៉ាក់សាំងការពារជំងឺស្អូចអោយដល់កុមារ គឺត្រូវអោយវ៉ាក់សាំងស្អូចឬរួមបញ្ចូលគ្នាកញ្ជ្រឹលស្អូច ។ នៅក្នុងប្រទេសឧស្សាហកម្មខ្លះជំងឺស្អូចត្រូវបានគេលប់បំបាត់ជិតអស់ហើយដោយគេធ្វើតាមរយៈកម្មវិធីផ្តល់ថ្នាំបង្ការទៅដល់កុមារតែទោះបីជាយ៉ាងណាក៏ដោយត្រូវធ្វើការគ្រប់ដណ្តប់ទៅលើកុមារអោយបាន៩៥%ដើម្បី ជៀសវាងការផ្លាស់ប្តូរនៃការចំលងជំងឺស្អូច។

**ចំណុចសំខាន់៖**

- ជំងឺស្អូចនិងជំងឺស្អូចពីកំណើត (CRS)បង្កឡើងដោយវីរុស។ជាធម្មតាស្ថានភាពនៃជំងឺនេះមានលក្ខណៈស្រាលចំពោះកុមារនិងមនុស្សពេញវ័យ ប៉ុន្តែស្រ្តីមានផ្ទៃពោះភាគច្រើនឆ្លងមេរោគស្អូច នៅពេលរយៈពេលដំបូងនៃការមានមានគភ៌ ហើយមានឱកាសចម្លងប្រមាណ៩០%ពីម្តាយដែលមានផ្ទៃពោះទៅទារកក្នុងផ្ទៃ ព្រមទាំងវាក៏អាចធ្វើអោយទារកស្លាប់នៅក្នុងផ្ទៃ ទារកដែលកើតមកថ្លង់ ស្តាប់សម្លេងមិនបាន ជំងឺបេះដូងពីកំណើត ជំងឺភ្នែកស្បែកបាំង/ភ្នែកឡើងបាយនិងរលាកខួរក្បាល។
- ពី២០%ទៅ៥០%នៃជំងឺស្អូចមិនចេញរោគសញ្ញាកន្ទួលទេ។
- កុមារដែលមានមេរោគជំងឺស្អូចពីកំណើត (CRS) គឺជាធម្មតាកើតមកមានភាពមិនប្រក្រតី ដូចជា៖ជំងឺភ្នែកស្បែកបាំង កឡើងបាយភ្នែ/និងស្តាប់សម្លេងមិនបាន ហើយជំងឺវិកលចរិតក៏អាចកើតមានផងដែរ។
- បច្ចុប្បន្នអង្គការសុខភាពពិភពលោកបានផ្តល់អនុសាសន៍អោយប្រទេសនៅក្នុងពិភពលោកប្រើប្រាស់វ៉ាក់សាំងកញ្ជ្រឹលស្អូច សំរាប់គោលដៅលប់បំបាត់ជំងឺស្អូច។

# ៦. ជំងឺតេតាណូស (Tetanus)

## ៦.១ តើជំងឺតេតាណូសគឺជាអ្វី ?

**ជំងឺតេតាណូស**គឺបណ្ដាលមកពីបាក់តេរី Clostridium tetani ជាទូទៅ មេរោគនេះមានវត្តមាននៅក្នុងដីនិងនៅគ្រប់ទីកន្លែង ជំងឺតេតាណូសកើតឡើងដោយសារប៉ះពាល់ជាមួយមេរោគ ។ មេរោគនេះគឺវាបង្កនូវជាតិពុលហើយវាជ្រាតចូលទៅក្នុងសរសៃប្រសាទ មេរោគនេះវាមានការធំលូតលាស់បានគឺដោយសារកោសិការដែលស្លាប់ ឧទាហរណ៍ដូចជារបួសដែលក្រខ្វក់ ឬក៏នៅក្នុងទងផ្ចិតនៅពេលដែល ធ្វើការសំរាលមិនបានសំអាត។ ប្រជាពលរដ្ឋគ្រប់អាយុទាំងអស់គឺអាចកើតជំងឺតេតាណូស ។

តេតាណូសទារក (កើតទៅលើទារកទើបកើត) និងតេតាណូសមាតា (កើតទៅលើម្ដាយ) ជំងឺនេះគឺវាច្រើនតែកើតធ្ងន់ធ្ងរទៅលើទារកដែលទើបនិងកើត ។ ទារកស្ទើរតែទាំងអស់ដែលកើតជំងឺនេះគឺស្លាប់ ជំងឺតេតាណូសទារកច្រើនតែកើតតំបន់ជនបទដោយសារការសំរាលគឺធ្វើនៅតាមផ្ទះដោយគ្មានការសំអាតបានគ្រប់គ្រាន់ ។

## ៦.២. តើជំងឺតេតាណូសឆ្លងដូចម្ដេច ?

**ជំងឺតេតាណូស** គឺមិនអាចចំលងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបានទេ ។ អ្នកជំងឺដែលឆ្លងជំងឺតេតាណូសគឺបណ្ដាលមកពីរបស់ក្រខ្វក់បានមុតឬចូលទៅក្នុងរបួស។ មេរោគតេតាណូសចូលចិត្តរស់នៅក្នុងរបួសដែលមុតជ្រៅហើយនិងបណ្ដាលមកពីការមុតដែកគោល កាំបិត សំភារៈដែក បំណែកឈើ ហើយនិងសត្វខាំ ស្ត្រីគឺជាអ្នកប្រឈមមុខជាមួយ ការចំលងបន្ថែម ទៀតនៅពេលដែលកំពុង សំរាលឬក៏កំពុង រំលូតដោយប្រើសំភារៈមិនស្អាត។

**ទារកដែលទើបនិងកើត** ក៏អាចចំលងមេរោគតេតាណូសបានដែរគឺនៅពេលណាដែលគេប្រើកាំបិតឡាម ឬក៏សំភារៈដ៏ទៃទៀត ដែលមិនស្អាត មកកាត់ទងផ្ចិត ហើយនិងការប្រើសំភារៈមិនស្អាតយកទៅលាងសំអាតទងផ្ចិត ឬក៏ដៃរបស់អ្នកដែលបង្កើតទារកមិនស្អាត ។ ទារកឬក៏កុមារក៏អាចចំលងមេរោគតេតាណូស បានដែរនៅពេលណាគេប្រើប្រដាប់កាត់ផ្ចិត , ប្រដាប់ចោះស្បែកមិនបានជូតសំអាត ហើយនិងនូវពេលណាដែលគេប្រើកំទេចធូបឬក៏របស់អ្វីទៀតដែលមិនស្អាតយកទៅលាបលើរបួស។

## ៦.៣. តើរោគសញ្ញានិងអាការៈរោគរបស់ ជំងឺតេតាណូសគឺជាអ្វី ?

រយៈពេលនៃតំណាក់កាលមិនចេញរោគសញ្ញា(រយៈពេលរវាងការឆ្លងមេរោគនិងការបង្ហាញរោគសញ្ញាដំបូង) ជាធម្មតាតំណាក់កាលមិនចេញរោគសញ្ញាមានរយៈពេលពី៣ទៅ២១ថ្ងៃ ប៉ុន្តែវាក៏អាចមានរយៈពេលច្រើនខែដែរវាអាស្រ័យលើមុខរបួស ។ ហានិភ័យនៃការស្លាប់ដោយសារជំងឺនេះកើនឡើងចំណែកឯរយៈពេលនៃតំណាក់កាលមិនចេញរោគសញ្ញាវាថយចុះ។

ចំពោះកុមារហើយនិងមនុស្សពេញវ័យនៅពេលដែលយើងឃើញសាច់ដុំថ្គាមឡើងរឹងនេះគឺជាសញ្ញាដំបូងនៃជំងឺតេតាណូស ។ រោគសញ្ញានេះគឺ ធ្វើអោយរឹងក ពិបាកលេប សាច់ដុំក្រពះ ឡើងរឹងសាច់ដុំកន្ត្រាក់ បែក

ញើសហើយនិងគ្រុន ។ ទារកដែលមានជំងឺតេតាណូសគឺកើតមកជាធម្មតាប៉ុន្តែបន្ទាប់ពីកើតបានរយៈពេលពី៣ទៅ ២៨ថ្ងៃគឺទារកឈប់បៅឬជញ្ជក់ដោះ ។ នៅពេលដែលគេឈប់បៅរាងកាយគេឡើងរឹងនៅ ពេលណាសាច់ដុំរួញ ហើយកន្ទ្រាក់ ។ ស្ទើរតែគ្រប់ករណីជំងឺតេតាណូសទាំងអស់ត្រូវបានស្លាប់។

## ៦.៤. តើផលវិបាកនៃ ជំងឺតេតាណូសគឺជាអ្វី ?

**ផលវិបាកនៃជំងឺតេតាណូស** គឺធ្វើអោយឆ្អឹងខ្នងឬក៏ឆ្អឹងដ៏ទៃទៀតបាក់ដោយសារសាច់ដុំរួញ ហើយនិងដោយសារការប្រកាច់។ចង្វាក់បេះដូងដើរខុសធម្មតាហើយអាចភ្លឹក អាចមានជំងឺរលាកសួតហើយនិង ជំងឺដ៏ទៃទៀត។ ការស្លាប់ជាធម្មតាគឺច្រើនតែកើតទៅលើកុមារហើយ និងមនុស្សចាស់។

## ៦.៥. តើជំងឺតេតាណូសត្រូវការអ្វីសំរាប់ព្យាបាល ?

អ្នកជំងឺតេតាណូសគ្រប់អាយុទាំងអស់ត្រូវទៅព្យាបាលនៅមន្ទីរពេទ្យអោយបានឆាប់រហ័ស។

## ៦.៦. តើ ជំងឺតេតាណូសត្រូវការអ្វីដើម្បីការពារ ?

នៅពេលបច្ចុប្បន្ន័នេះប្រទេសកម្ពុជាបានប្រើវ៉ាក់សាំងរួមបញ្ចូលគ្នាវ៉ាក់សាំងខាន់ស្លាក់ តេតាណូស ក្អកមាន់ រលាកថ្លើមប្រភេទ បេនិង ហ៊ីប(DPT-Hep-Hib) សំរាប់កុមារ និង វ៉ាក់សាំងTT សំរាប់ស្ត្រី ។ ជំងឺតេតាណូសទារកអាចការពារបានតាមរយៈការផ្តល់ថ្នាំបង្ការតេតាណូសទៅអោយស្ត្រីដែលនៅក្នុងវ័យមានផ្ទៃពោះហើយ និងស្ត្រីនៅវ័យបន្តពូជ។វ៉ាក់សាំងនេះគឺការពារមាតាហើយ និង អាចធ្វើអោយមានភាពស៊ាំទៅលើរាង្គកាយហើយ និងអាចបញ្ជូនទៅអោយទារកនៅក្នុងផ្ទៃទៀតផង ។ ការសំរាលកូនស្អាតគឺវាមានសារៈសំខាន់ណាស់សំរាប់មាតា ទោះបីជានាងបានទទួលវ៉ាក់សាំងការពារជំងឺតេតាណូសក៏ដោយ។ អ្នកជំងឺដែលបានជាសះស្បើយមកពីជំងឺតេតាណូស ហើយនឹងមិនទាន់មានភាពស៊ាំពីកំណើតជំងឺតេតាណូសអាចវិលត្រឡប់មកវិញប៉ុន្តែទោះបីយ៉ាងណាត្រូវទៅទទួលវ៉ាក់សាំងការពារជំងឺតេតាណូស។

## ៦.៧. បញ្ហារទប់ស្កាត់នូវការរីករាលដាលជំងឺនៅទូទាំងសាកលលោក

អង្គការ WHO UNICEF ហើយ UNFPA បានយល់ព្រមយកឆ្នាំ២០០៥នេះ ធ្វើជាឆ្នាំនៃការលប់បំបាត់ជំងឺតេតាណូសទារក ។ ការកំណត់នេះគឺដើម្បីធ្វើកាត់បន្ថយនៅជំងឺតេតាណូសទារក ក្នុងចំណោមទារកកើតរស់១០០០ករណីមាន១ករណីស្លាប់ នៅក្នុងមួយស្រុក/ឆ្នាំ។ គោលបំណងនេះ គឺត្រូវបានអះអាងដោយសន្និសិទកំពូលរបស់អង្គការសហប្រជាជាតិ (UNGASS) នៅក្នុង ឆ្នាំ២០០២។ មេរោគតេតាណូស គឺវាអាចរស់នៅក្នុងបរិដ្ឋាន ហើយការលុបបំបាត់ជំងឺនេះគឺវាមិនអាចធ្វើបានទេនៅថ្នាក់លើ ដូច្នេះកម្មវិធីផ្តល់ថ្នាំបង្ការ ត្រូវបន្តនៅសកម្មភាពរបស់ខ្លួនបើទោះបីជាគេមាន គោលដៅរួចហើយក៏ដោយ ។ ដើម្បីធ្វើអោយបានសំរេចនៅគោលបំណងនៃការលប់បំបាតជំងឺតេតាណូសទារកប្រទេស និមួយៗត្រូវធ្វើការអនុវត្តន៍ទៅតាម យុទ្ធសាស្ត្រ ដូចមាននៅខាងក្រោមនេះ ៖

- ❖ បង្កើនអត្រាគ្របដណ្តប់វ៉ាក់សាំងតេតាណូសតាមរយៈការបង្កើនងាយស្ត្រីដែលមានផ្ទៃពោះអោយមកទទួលថ្នាំបង្ការជំងឺតេតាណូស។
- ❖ ផ្តល់វ៉ាក់សាំងការពារជំងឺតេតាណូសដល់ស្ត្រីដែលនៅក្នុងវ័យបន្តពូជ ។

- ❖ លើកកំពស់ការសំរាលស្អាត ហើយនិងអនុវត្តន៏ថែរក្សាកុមារអោយបានល្អ។
- ❖ ធ្វើអោយបានប្រសើរឡើងក្នុងការតាមដាននឹងការរាយការណ៍អំពីករណីជំងឺតេតាណូសទារក។

**ចំណុចសំខាន់៖**

- ❖ ជំងឺតោណូសគឺបណ្តាលមកពីមេរោគបាក់តេរីដែលមាននៅក្នុងបរិដ្ឋាន។ជំងឺនេះគឺឆ្លងតាមរយៈការសំរាលមិនស្អាត តាមរយៈសំភារៈដែលកាត់ទងផ្ចិតមិនស្អាត ឬក៏មេរោគ តេតាណូសចូលទៅតាមរយៈការមុតឬក៏ការដាច់ស្បែក។
- ❖ ជំងឺតេតាណូទារកគឺជាបញ្ហាមួយរបស់ប្រទេសដែលមានអត្រាគ្រប់ដណ្តប់ទាបទៅលើការផ្តល់ថ្នាំបង្ការ ហើយនិងការអនុវត្តន៍ ទៅលើការសំរាលទារកមិនស្អាត។ ស្ទើរតែគ្រប់ទារកទាំងអស់ដែលទើបនិងកើតហើយមានជំងឺតេតាណូសគឺត្រូវស្លាប់ ។
- ❖ វិធីសាស្រ្តដ៏ល្អគឺត្រូវចាក់ថ្នាំការពារជំងឺតេតាណូស ហើយនិងធ្វើការសំអាតយកចេញ ពីលើរបួសនូវកោសិកាដែលស្លាប់។វិធីសាសន៍ដ៏ល្អ ដើម្បីការពារជំងឺតេតាណូសទារក ត្រូវផ្តល់ថ្នាំបង្ការតេតាណូសទៅអោយស្រ្តីដែលមានអាយុចិតនៅក្នុងវយ័មានផ្ទៃពោះ (ឬក៏ស្រ្តីមានផ្ទៃពោះ) ហើយនិងធ្វើការអនុវត្តន៍ទៅការសំរាលស្អាត។

# ៧. ជំងឺរបេង (Tuberculosis )

## ៧.១. តើជំងឺរបេងគឺជាអ្វី ?

**ជំងឺរបេង** គឺបណ្តាលមកពីមេរោគមីកូបាក់តេរីយ៉ូម (Mycobacterium tuberculosis) ជាធម្មតាគឺវាធ្វើការចំលងទៅលើសួតប៉ុន្តែវាក៏អាចចំលងទៅលើផ្នែកដ៏ទៃទៀត នៃរាងកាយដូចជា ឆ្អឹង សន្លាក់ ហើយនិងខួរក្បាល។

មិនមែនមនុស្សគ្រប់គ្នាត្រូវតែឆ្លងមេរោគជំងឺរបេងនោះទេ អ្នកដែលបានឆ្លងជំងឺនេះជួនកាលគឺគ្មានអារម្មណ៍ថាឈឺហើយក៏ប្រហែលជាគ្មានរោគសញ្ញាផងដែរ ។ មេរោគនេះគឺអាចផ្ទុកនៅក្នុងខ្លួនយើងអស់មួយជីវិតប៉ុន្តែអ្នកដែលមានផ្ទុកមេរោគនេះគឺមេរោគនេះមិនមែនកើតឡើងដោយខ្លួនឯងទេ។ ប្រជាពលរដ្ឋ ដែលមានផ្ទុកមេរោគរបេងហើយមេរោគរបេងនោះគ្មានការវិវឌ្ឍន៏ទៅជាជំងឺដូច្នេះពួកគេមិនអាចចំលងមេរោគរបេងទៅអោយអ្នកដ៏ទៃបានទេ ។

## ៧.២. តើជំងឺរបេងឆ្លងដូចម្តេច ?

**ជំងឺរបេង** គឺឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយៈលំហអាកាសជាពិសេសនៅពេលដែលអ្នកជំងឺក្អកឬក៏ក្រដាស ។ ជំងឺរបេងឆ្លងរហ័សណាស់ជាពិសេសនៅក្នុងដំបន់ដែលមានប្រជាពលរដ្ឋរស់នៅច្រើន ហើយនិងខ្វះការថែរក្សាសុខភាព ហើយនិងកង្វះជីវជាតិ។ ប្រជាពលរដ្ឋគ្រប់វ័យទាំងអស់អាចចំលងជំងឺរបេងបាន។ ប៉ុន្តែបញ្ហាប្រឈមនឹងគ្រោះថ្នាក់ខ្ពស់បំផុតនៃជំងឺរបេងគឺកុមារដែលមានអាយុក្រោម៣ឆ្នាំហើនិងមនុស្សដែលមានវ័យចំណាស់។ អ្នកជំងឺដែលមានជំងឺរបេងគឺជាអ្នកដែលមានប្រព័ន្ធការពាររាងកាយខ្សោយ(ឧបហរណ៍ៈជាអ្នកដែលមានផ្ទុកមេរោគ HIV ច្រើនតែកើតជំងឺនេះ)។

## ៧.៣. តើរោគសញ្ញានិងអាការៈរោគរបស់ ជំងឺរបេងគឺជាអ្វី ?

រយៈពេលនៃការចាប់ផ្តើមបង្ករោគៈ សំរាប់រោគសញ្ញាដំបូងជាធម្មតាគឺចាប់ផ្តើមពី៤សប្តាហ៏ទៅដល់១២សប្តាហ៏ ប៉ុន្តែជំងឺនេះអាចសំងំនៅបានយូគឺពីមួយខែទៅដល់៧ឆ្នាំមុនពេលជំងឺនេះវិវត្តន៏។ អ្នកជំងឺដែលមានជំងឺនេះ គឺអាចចំលងទៅអ្នកដ៏ទៃក្នុងរយៈពេលពី២ទៅ៣សប្តារហ៏ បន្ទាប់ពីគាត់ចាប់ផ្តើមទទួលការព្យាបាល។ រោគសញ្ញាជំងឺរបេងគឺមានរួមបញ្ចូល រាងកាយចុះខ្សោយ ស្រកទម្ងន់ គ្រុនហើយនិងបែកញើសនៅពេលយប់។

**របេងក្នុងសួតគឺគ្រូវ** បានគេហៅថា របេងសួតហើយរបេងសួតមានរោគសញ្ញាក្អកជាប្រចាំ, ក្អកមានធ្លាក់ឈាម ហើយនិងឈឺទ្រូង។ចំពោះកុមារដែលមានរោគសញ្ញារបេងសួតហើយគឺកុមារនោះគ្មានការលូតលាស់ហើយនិងធ្វើអោយកុមារនោះក្រិន។ សំរាប់រោគសញ្ញាដ៏ទៃផ្សេងទៀត គឺយោងទៅលើរូបរាងកាយរបស់អ្នកជំងឺដែលត្រូវទទួលជំងឺ។ ឧទាហរណ៏ដូចជាជំងឺរបេងឆ្អឹង គឺអាចធ្វើអោយសន្លាក់ហើម, ឈឺហើយនិង ធ្វើអោយពិការទៅលើត្រគៀក ឬក៏ ឆ្អឹងខ្នង។

## ៧.៤. តើផលវិបាកនៃ ជំងឺរបេងគឺជាអ្វី ?

**ជំងឺរបេង**គឺមានច្រើនសណ្ឋានណាស់ ហើយក៏មានការពិបាកក្នុងការអោយរោគវិនិច្ឆ័យ ។ ជំងឺរបេងសួតបើមិនបានព្យាបាលគឺវានឹងធ្វើអោយអ្នកជំងឺចុះខ្សោយហើយក៏ស្លាប់។ជាពិសេសអ្នកជំងឺដែលមានផ្ទុកមេរោគ HIVគឺឆាប់ចុះខ្សោយហើយក៏ឆាប់ស្លាប់ណាស់។

## ៧.៥. តើ ជំងឺរបេងត្រូវការអ្វីដើម្បីព្យាបាល ?

**អ្នកជំងឺរបេង**គឺត្រូវព្យាបាលអោយបានចប់សព្វគ្រប់ ជាធម្មតាអ្នកជំងឺរបេងត្រូវលេបថ្នាំអង់ទីបីយ៉ូទីកពី២ ទៅ៣ មុខឡើងទៅ ហើយការព្យាបាលនេះយ៉ាងហោចណាស់ក៏៦ខែដែរ។ ការព្យាបាលនេះត្រូវបានគេហៅថាដូតស៍ដោយធ្វើការព្យាបាលផ្ទាល់ទៅលើអ្នកជំងឺទៅតាមកម្មវិធីព្យាបាល។វាគឺជាអកុសលផងដែរចំពោះអ្នកជំងឺខ្លះដែលមិនអាចលេបថ្នាំអោយបានចប់សព្វគ្រប់ទៅតាមការកំណត់នៃព្យាបាល។ អ្នកជំងឺខ្លះទៀតការព្យាបាលគឺគ្មានប្រសិទ្ធភាព ។ សំរាប់អ្នកជំងឺដែលស៊ាំនិងឱសថរបេងនេះគឺមានគ្រោះថ្នាក់ណាស់ក្នុងការចំលងទៅអ្នកដ៏ទៃ។នៅពេលដែលអ្នកជំងឺមិនបានព្យាបាលចប់សព្វគ្រប់ទៅតាម ការកំណត់ឬក៏ព្យាបាលខុសគឺពួកគេនៅតែមានជំងឺរបេងដ៏ដែល។

## ៧.៦. តើ ជំងឺរបេងត្រូវការអ្វីដើម្បីការពារ ?

ធ្វើការផ្តល់ថ្នាំបង្ការការពារជំងឺរបេងទៅអោយទារកដោយវ៉ាក់សាំង( Bacille Calmette-Guérin vaccine (BCG) គឺអាចការពារប្រឆាំង និងជំងឺរបេងស្រោមខួរហើយនិងរបេងផ្សេងទៀត ដែលកើតទៅលើកុមារដែលមានអាយុក្រោម៥ឆ្នាំ។

**ចំណុចសំខាន់៖**

- ជំងឺរបេងជាធម្មតាគឺវាច្រើនតែកើតទៅលើសួតក៏ប៉ុន្តែវាក៏អាចឆ្លងទៅផ្នែករាងកាយដ៏ទៃទៀតដែរ ដោយរួមបញ្ចូលទាំង ឆ្អឹង, សន្លាក់ ហើយនិង ខួរក្បាល។
- ជំងឺរបេងគឺឆ្លងទៅតាមលំហអាកាស។ រោគសញ្ញានៃជំងឺរបេងជាទូទៅ អ្នកជំងឺចុះខ្សោយ, ស្រកទម្ងន់, គ្រុន ហើយនិងបែកញើសនៅពេលយប់។ អ្នកជំងឺដែលមានជំងឺរបេង ត្រូវព្យាបាលអោយ បានចប់សព្វគ្រប់ ឬបើសិនមិនបានព្យាបាលចប់សព្វគ្រប់ទេពួកគេគឺអាចចំលងទៅអ្នកដ៏ទៃទៀត។
- ទៅតាមអនុសាសន៏បានកំណត់យកវិធីសាស្រ្តដើម្បីការពារកុមារដែលមានអាយុក្រោម១២ខែគឺត្រូវផ្តល់វ៉ាក់សាំង(BCG) អោយបានឆាប់នៅពេលគេទើបតែបានសំរាល់។

# ៨. ជំងឺរលាកខួរក្បាលជេអ៊ី (Japanese Encephalitis-JE)

## ៨.១. តើជំងឺរលាកខួរក្បាលជេអ៊ីជាអ្វី ?

**ជំងឺរលាកខួរក្បាលជេអ៊ី** គឺជាជម្ងឺធ្ងន់ធ្ងរមួយដែលមានការហើមខួរក្បាល ។ វីរុសJE (JEV)គឺជាមូលហេតុនាំមុខគេនៃជំងឺរលាកខួរក្បាល វាត្រូវបានរកឃើញនៅក្នុងបណ្តាប្រទេសអាស៊ី តំបន់អាស៊ីប៉ាស៊ីហ្វិក និង ផ្នែកខ្លះនៅនៃភាគខាងជើងនៃប្រទេសអូស្ត្រាលី។

ជាទូទៅវាបណ្តាលឲ្យមានជំងឺរលាកខួរក្បាលដែលមានលក្ខណៈធ្ងន់ធ្ងរ។ ជំងឺនេះកើតមានចំពោះមនុស្សគ្រប់វ័យ ជាពិសេសនៅពេលដែលមេរោគនេះ វាងាយឆ្លងណាស់ចំពោះប្រជាជនដែលមិនមានភាពស៊ាំ។

## ៨.២. តើការឆ្លងវារីសជំងឺរលាកខួរក្បាលជេអ៊ីតាមរបៀបណាខ្លះ ?

**វារីសជំងឺរលាកខួរក្បាលជេអ៊ី** ឆ្លងតាមរយៈមូសគុយឡិច(Culextritaeniorhynchus) ។ ជាទូទៅមូសទាំងនោះ មាននៅតាមជនបទដែលមានដំណាំស្រូវ និង កសិដ្ឋានចិញ្ចឹមជ្រូកប៉ុន្តែគេក៏អាចរកឃើញនៅតាមជាយក្រុងផងដែរ ។ មូសបាននាំយកវារីសជេអ៊ី ពីសត្វមួយចំនួន (ភាគច្រើនបំផុតគឺសត្វជ្រូក និងសត្វស្លាបទឹក) បន្ទាប់មកវាចំលងទៅមនុស្ស ។

**វារីសជំងឺរលាកខួរក្បាលជេអ៊ី** ឆ្លងទៅមនុស្សតាមរយៈការខាំនៃមូសគុយឡិច(Culex) ដែលមានមេរោគនិងបានធ្វើដំណើរក្នុង វដ្ដ enzootic(ក្នុងសត្វជ្រូកនិង សត្វស្លាបទឹក) wading birds( ដែលជាកន្លែងពង្រីកខ្លួន )amplifying hosts( មូសគុយឡិច )Culex tritaeniorhynchus( ដែលជាប្រភេទ វ៉ិចទ័រដ៏សំខាន់បំផុត វាបន្តពូជនៅក្នុងថ្លុកទឹកនិងវាលស្រែលិចទឹក និង ជាទូទៅវាខាំចម្បងក្នុងអំឡុងពេលយប់។

**មូសគុយឡិច**ខាំសត្វដែលមានវីរ៉ុសជំងឺ ជេអ៊ី រួចចំលងទៅមនុស្សទៅពេលវាខាំ។ ទោះជាយ៉ាងណាមនុស្សជា dead end hosts ដែលមួសគុយឡិច មិនអាចខាំចំលងពីមនុស្សម្នាក់ទៅមនុស្សទៀតបានឡើយ

## វដ្តនៃការចំលងរបស់វីរុសរលាកខួរក្បាលជេអ៊ី៖




## ៨.៣. តើរោគសញ្ញានៃជំងឺរលាកខួរក្បាលជេអ៊ី មានអ្វីខ្លះ ?

ភាគច្រើននៃមនុស្សដែលឆ្លងមេរោគនេះបានបង្ហាញនូវរោគសញ្ញាតិចតួចឬក៏មិនបង្ហាញនូវរោគសញ្ញាអ្វីទេ។ជាមធ្យមមានមនុស្សម្នាក់ក្នុងចំណោមមនុស្ស២៥០នាក់ ដែលបានឆ្លងមេរោគជំងឺរលាកខួរក្បាលជេអ៊ីនេះដែលបង្ហាញនូវរោគសញ្ញា។ រោគសញ្ញានៃជំងឺរលាកខួរក្បាលជេអ៊ី ជាធម្មតា រោគសញ្ញាគ្រុនផ្តាសាយ គ្រុនក្តៅរងាញាក់ អស់កំលាំង ឈឺក្បាល ក្អួត និង ចង្អោរ កើតឡើងពី៥ថ្ងៃទី១៥ថ្ងៃបន្ទាប់ពីឆ្លងមេរោគជំងឺរលាកខួរក្បាលជេអ៊ីនេះ ។ ចំពោះកុមាររោគសញ្ញាឈឺក្រពះឬការឈឺពោះអាចជារោគសញ្ញាដែលលេចធ្លោនៅក្នុងដំណាក់កាលដំបូងនៃជំងឺនោះ។ រោគសញ្ញាស្មារតីវង្វេងវង្វាយ និង ការឡេះឡះ រឹងក បង្អើយប៉ោង ប្រកាច់ញ័រញាប់ ខ្វិនសន្លប់ និង សញ្ញាដទៃទៀតដូចជា ពិបាកក្នុងការនិយាយជាដើមកើតឡើង៣ថ្ងៃទៅ៥ថ្ងៃពីណាក់កាលដំបូង ។ ជាញ័រញាប់កុមារស្តែងចេញជារោគសញ្ញា រឹងក បង្អើយប៉ោងនិងប្រកាច់ញ័រញាប់។

## ៨.៤. តើផលវិបាកនៃជំងឺរលាកខួរក្បាលជេអ៊ីជាអ្វី ?

មានអត្រាប្រមាណពី ២០% ទៅ ៣០% នៃ កុមារដែលបានកើតជម្ងឺរលាកខួរក្បាលជេអ៊ី នេះឆ្ពោះទៅសេចក្តីស្លាប់ជាពិសេសកុមារដែលមានអាយុតិចជាង១០ឆ្នាំ និង មានការប៉ាន់ប្រមានផងដែរថាអ្នកជម្ងឺរលាកខួរក្បាលជេអ៊ីដែលរួចផុតពីការស្លាប់មានពី៣០%ទៅ ៥០% មានពិការភាព ក្នុងនោះមានទាំងផ្លូវកាយនិងផ្លូវចិត្តនៃអ្នកជំងឺដែលនៅរស់រានបានបន្សល់នូវពិការភាពផ្នែកសរសៃវិញ្ញាណដូចជា បញ្ហាចិត្តសង្គម សតិបញ្ញា ឬ ពិការកាយសម្បទាហើយបញ្ហាទាំងនេះមានអត្រាខ្ពស់ចំពោះកុមារ ។

## ៨.៥. តើអ្នកណាខ្លះទទួលគ្រោះថ្នាក់ដោយសារវីរុសជេអ៊ី ៖

**មនុស្សរស់នៅតាមជនបទតំបន់កសិដ្ឋាននៅអាស៊ី**ជាកន្លែងដែលទទួលគ្រោះថ្នាក់ដោយវារ៉ុសជេអ៊ី ខ្លាំងជាងគេ។ កុមារដែលមានអាយុចន្លោះពី ១ឆ្នាំ ដល់ ១៥ឆ្នាំ មានគ្រោះថ្នាក់ដោយសារជំងឺជេអ៊ីច្រើនជាងមនុស្សពេញវ័យ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងករណីខ្លះមនុស្សពេញវ័យក៏អាចកើតជំងឺជេអ៊ីបានដែរជាពិសេស នៅពេលដែលជំងឺនេះទើបកើតមានថ្មីៗ នៅក្នុងតំបន់នោះ។

## ៨.៦. តើការធ្វើរោគវិនិច្ឆ័យជំងឺ ជេអ៊ីតាមរបៀបណា ?

**ការធ្វើរោគវិនិច្ឆ័យនៃការចំលងជំងឺជេអ៊ី** គឺផ្អែកទៅលើការពិនិត្យឈាម និង ការពិនិត្យទឹកខួរឆ្អឹងខ្នង។

## ៨.៧. តើមានការព្យាបាលជំងឺជេអ៊ី ដែរឬទេ ?

**មិនមានការព្យាបាលជំងឺជេអ៊ី** ដោយប្រើថ្នាំអង់ទីប៊ីយ៉ូទិកទេព្រោះពពួកថ្នាំនេះមិនអាចសំលាប់វារ៉ុសបានឡើយ ហើយក៏មិនទាន់មានឱសថប្រឆាំងវីរុសណាមួយសំរាប់ព្យាបាលជំងឺជេអ៊ីនេះដែរ ។ ទោះ ជាយ៉ាងណាក៏ដោយការថែទាំគាំទ្រអ្នកជំងឺគឺមានសារៈសំខាន់ណាស់សំរាប់កាត់បន្ថយគ្រោះថ្នាក់នៃការស្លាប់និងពិការភាព ។

## ៨.៨. តើវិធីការពារជំងឺជេអ៊ីយ៉ាងដូចម្តេច ?

**ការផ្តល់ថ្នាំបង្ការ**គឺជាមធ្យោបាយដ៏ល្អសំរាប់ការពារជំងឺជេអ៊ី ។ រដ្ឋាភិបាលកម្ពុជាបានបញ្ចូលវ៉ាក់សាំងជេអ៊ីទៅក្នុងសកម្មភាពផ្តល់ថ្នាំបង្ការជាប្រចាំ៖ ប្រើប្រាស់វ៉ាក់សាំងជេអ៊ី SA 14-14-2 ផ្តល់អោយកុមារជាមួយវ៉ាក់សាំងកញ្ជ្រឹល(៩ខែ)។

**ចំណុចសំខាន់៖**

- ❖ ជំងឺរលាកខួរក្បាលជេអ៊ីគឺជាទូទៅវាបណ្តាលឲ្យមានជំងឺរលាកខួរក្បាលធ្ងន់ធ្ងរ ។ មានអត្រាប្រមាណពី ២០% ទៅ ៣០% នៃ កុមារដែលបានកើតជម្ងឺរលាកខួរក្បាល ជេអ៊ី នេះ ឆ្ពោះទៅសេចក្តីស្លាប់ និង មានការប៉ាន់ប្រមានផងដែរថាអ្នកជម្ងឺរលាកខួរក្បាលជេអ៊ីដែលរួចផុតពីការស្លាប់មានពី៣០% ទៅ ៥០% មានភាពពិការភាព។
  - ❖ ជាធម្មតា រោគសញ្ញាគ្រុនផ្តាសាយ គ្រុនក្តៅ រងារញាក់ អស់កំលាំង ឈឺក្បាល ក្អួត និង ចង្អោរ កើតឡើងពី៤ថ្ងៃដល់ទី១៤ថ្ងៃបន្ទាប់ពីឆ្លងមេរោគជំងឺរលាកខួរក្បាលជេអ៊ីនេះ និងនិង ការឡេះឡុះ រឹងក បង្ហើយប៉ោង ប្រកាច់ញ៉ឹកញាប់ ខ្វិន សន្លប់ និង សញ្ញាដទៃទៀតដូចជា ពិបាកក្នុងការនិយាយជាដើមកើតឡើង៣ថ្ងៃទៅ៤ថ្ងៃពីដំណាក់កាលដំបូង ។
  - ❖ ការផ្តល់ថ្នាំបង្ការគឺជាមធ្យោបាយដ៏ល្អសំរាប់ការពារជំងឺជេអ៊ីប្រើប្រាស់វ៉ាក់សាំងជេអ៊ីSA14-14-2 ផ្តល់អោយកុមារជាមួយវ៉ាក់សាំងកញ្ជ្រឹល(៩ខែ)។

# ៩. ជំងឺហ៊ីប (Haemophilus Influenzae type b - Hib)

## ៩.១. តើជំងឺហ៊ីបជាអ្វី?

**ជំងឺហ៊ីប** គឺជាបាក់តេរីក្រាមអវិជ្ជមាន(Bacteria gram negative) មួយប្រភេទក្នុងចំណោមទាំង៦ប្រភេទ(Haemophilus influenzae type a,b,c,d,e,f) ជាទូទៅគេរកឃើញមេរោគនេះនៅក្នុងច្រមុះនិងបំពង់កកុមារ។ ហ៊ីបជាបាក់តេរីដែលដើរតួសំខាន់ជាងគេប្រមាណ ៩០% នៃជំងឺរលាកសួតនិងរលាកស្រោមខួរក្បាល(Pneumonia and Meningitis)បង្កដោយបាក់តេរីហ៊ីប (Haemophilus Influenzae type b) ។

**ជំងឺហ៊ីប**ត្រូវបានទទួលខុសត្រូវចំពោះជំងឺរលាកសួតនិងរលាកស្រោមខួរក្បាលធ្ងន់ធ្ងចំពោះកុមារដែលមានអាយុតិចជាង ៥ឆ្នាំ។ ជំងឺរលាកស្រោមខួរក្បាលបង្កដោយបាក់តេរី(Bacterial Meningitis) ការរលាកភ្នាសការពារខួរឆ្អឹងខ្នងនិងស្រោមខួរក្បាល ភាគច្រើនបណ្តាលមកពីបាក់តេរីហ៊ីប (Hib bacterial)។នៅបណ្តាប្រទេសអភិវឌ្ឍន៍ ជំងឺរលាកស្រោមខួរបង្កដោយបាក់តេរីហ៊ីបអាចបណ្តាលអោយកុមារស្លាប់ប្រហែលជាពី៣%ទៅ៥%។ប្រទេស កំពុងអភិវឌ្ឍន៍ ជំងឺនេះបណ្តាលអោយកុមារស្លាប់យ៉ាងច្រើនប្រហែលជា៤០%។

ក្នុងចំណោមកុមារប្រមាណ១៥-៣៥%ដែលរស់រានមានជីវិតបានទទួលរងនូវពិការភាពផ្នែកប្រពន្ធ័ប្រសាទជាអចិន្ត្រៃយ៍ដូចជាខ្សោយបញ្ញា ស្មារតី និង ថ្លង់ជាដើម។ ជំងឺរលាកសួតដោយសារបាក់តេរីហ៊ីប(Hib Pneumonia) នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ បាក់តេរីហ៊ីបដើរតួយ៉ាងសំខាន់ក្នុងការបង្កអោយមានជំងឺរលាកសួតឬរលាកផ្លូវដង្ហើមផ្នែកខាងក្រោមស្រួចស្រាវ។

## ៩.២. តើមេរោគហ៊ីបឆ្លងរបៀបណា?

**បាក់តេរីហ៊ីប** ចម្លងពីមនុស្សម្នាក់ទៅម្នាក់ទៀត តាមរយៈកំទេចទឹកមាត់នៅពេលអ្នកជំងឺក្អក ឬកណ្តាសជាដើម។ កុមារមួយចំនួនដែលមានបាក់តេរីហ៊ីបនេះពុំមានលេចចេញនូវរោគសញ្ញាអ្វីទេ ប៉ុន្តែកុមារទាំងនេះអាចចំលងទៅអ្នកដទៃទៀតបាន។ កុមារដែលងាយរងគ្រោះបំផុតគឺកុមារអាយុពី៦ខែទៅ២ឆ្នាំ។ អត្រានៃការឆ្លងនេះកើនឡើងនៅពេលកុមាររស់នៅជាមួយគ្នាដូចជានៅក្នុងមណ្ឌលថៃទាំកុមារ សាលារៀនជាដើម។

## ៩.៣. តើរោគសញ្ញានៃជំងឺហ៊ីបមានអ្វីខ្លះ ?

**ជំងឺរលាកសួត និង រលាកស្រោមខួក្បាលធ្ងន់ធ្ងរ** ជាញឹកញាប់បណ្តាលមកពីមេរោគហ៊ីបហើយមេរោគហ៊ីបក៏មិនមែនជាមូលហេតុតែមួយគត់នៃជំងឺទាំងនេះដែរហើយរោគសញ្ញារបស់ជំងឺហ៊ីបគឺវាអាស្រ័យឬពាក់ពន្ធ័ទៅលើជំងឺទាំងឡាយនោះ។ កុមារដែលមានជំងឺរលាកសួតអាចមានក្តៅខ្លួន គ្រុនញាក់ ក្អក ពិបាកដកដង្ហើម។ កុមារដែលមានជម្ងឺរលាកស្រោមខួរក្បាលអាចមានក្តៅខ្លួន គ្រុនញាក់ ឈឺក្បាល ភាពប្រែប្រួលស្មារតីពេលខ្លះយល់ច្រឡំ។ ជំងឺផ្សេងទៀតក៏ជាមូលហេតុនៃមេរោគហ៊ីបនេះដែរដូចជា ៖

- ការរលាកកន្លើត (Epiglottitis)
- មេរោគនៅក្នុងឈាម (Septicemia)៖ គឺជាវត្តមានបាក់តេរីបង្កជំងឺនៅក្នុងឈាម

- ការរលាកសន្លាក់ (Septic arthritis)
- ការរលាកឆ្អឹង (Osteomyelitis)
- ការរលាកកោសិកាស្បែក (Cellulitis)
- ការរលាកស្រោមបេះដូង (Pericarditis)

រោគសញ្ញារបស់ជំងឺខាងលើគឺវាអាស្រ័យឬពាក់ពន្ធ័ទៅលើជំងឺនោះ។

## ៩.៤. ក្រុមអាយុដែលរងគ្រោះដោយបាក់តេរីហ៊ីប

**ជំងឺហ៊ីប**យាយីភាគច្រើនលើកុមារអាយុក្រោម៥ឆ្នាំ ហើយកុមារដែលងាយរងគ្រោះបំផុតគឺក្រុមកុមារ អាយុពី៤ខែ ទៅ ១២ ខែ។ ចំពោះភាពស៊ាំពីកំណើត អាចការពារកុមារពីជំងឺនេះបាន ភាពស៊ាំនេះនឹងធ្លាក់ចុះនៅពេលកុមារ មានអាយុពី ២ខែ ទៅ៣ ខែ។ នៅពេលមានអាយុ៤ ឆ្នាំ ទៅ ៥ឆ្នាំ កុមារអាចបង្កើតបានប្រព័ន្ធការពារពេញលេញ ដោយឯកឯង បន្ទាប់ពីពេលនោះមក ជំងឺហ៊ីបអាចកើតមានដោយកម្រ ។

## ៩.៥. តើផលវិបាកនៃជំងឺហ៊ីបជាអ្វី ?

ផលវិបាកក្រោយពីការព្យាបាលជំងឺរលាកស្រោមខួរក្បាលដោយសារហ៊ីប (Hib meningitis) ច្រើនតែបន្សល់នូវពិការភាពអចិន្ត្រៃយ៍ ខូចខាតខួរក្បាល និងជំងឺវិកលចរិតរហូតដល់ទៅ៤០%នៃករណីជំងឺនេះ។

## ៩.៦. ការព្យាបាលជំងឺហ៊ីប

**ជំងឺហ៊ីបអាចព្យាបាលដោយ**ប្រើអង់ទីប៊ីយូទិកប៉ុន្តែអត្រាភាពស៊ាំជាមួយអង់ទីប៊ីយូទិកមានការកើនឡើង ។ កុមារភាគច្រើនពុំមានលទ្ធភាពមកទទួលការព្យាបាលត្រឹមត្រូវនៅមន្ទីរពេទ្យជំនាញ ។

## ៩.៧. ការការពារជំងឺហ៊ីប

ការពារជំងឺការពារបានដោយមកទទួលវ៉ាក់សាំងDPT-Hep B-Hib ៣ដង។

**ចំណុចសំខាន់៖**

- ហ៊ីប គឺជាបាក់តេរីក្រាមអវិជ្ជមាន(Bacteria gram negative) មួយប្រភេទក្នុងចំណោមទាំង៦ប្រភេទ(Haemophilus influenzae type a,b,c,d,e,f)
- ហ៊ីបជាបាក់តេរីដែលដើរតួសំខាន់ជាងគេគឺប្រមាណ៩០%នៃជំងឺរលាកសួតនិងរលាកស្រោមខួរក្បាលបង្កដោយបាក់តេរីហ៊ីប (Haemophilus Influenzae type b) ។
- បាក់តេរីហ៊ីបច្រើនរកឃើញនៅក្នុងច្រមុះនិងបំពង់ករបស់អ្នកជំងឺ។
- ការពារជំងឺការពារបានដោយមកទទួលវ៉ាក់សាំងDPT-Hep B-Hib ៣ដង។

# ១០. ជំងឺដែលបណ្ដាលមកពីមេរោគប្នឺម៉ូកូក (Pneumococcal Disease)

## ១០.១. អ្វីទៅជាជំងឺដែលបណ្ដាលមកពីមេរោគភ្នឺម៉ូកូក?

**ជំងឺដែលបណ្ដាលមកពីមេរោគប្នឺម៉ូកូក** គឺជាជំងឺទាំងឡាយណាដែលបង្កដោយបាក់តេរីដែលគេហៅស្ត្រិបតូកូកប្នឺម៉ូនីញៀរ (Streptococcus Pneumonia) ហើយដែលគេស្គាល់ជាទូទៅថាជាប្នឺម៉ូកូក (Pneumococcus)។ ការបង្ការរោគដោយរបស់ប្នឺម៉ូកូក (Pneumococcal infection) គឺមាននៅផ្នែកផ្សេងៗនៃសរីរាង្គ ។ ជំងឺដែលវាបង្កឡើងដោយមេរោគប្នឺម៉ូកូក សុទ្ធសឹងជាជំងឺធ្ងន់ធ្ងរដូចជា៖

(១) ជំងឺរលាកសួត

(២) ជំងឺរលាកស្រោមខួរក្បាល

(៣) ជំងឺដែលបង្កឡើងដោយបាក់តេរីនៅក្នុងឈាម(Bacteremia)

(៤) ជំងឺរលាកត្រចៀកកណ្ដាល(Otitis media)

(៥) រលាកឆ្អឹងច្រមុះ ( Sinusitis) និង

(៦) ជំងឺរលាកទងសួត(Bronchiolitis) ជាដើម។

**ជំងឺដែលបណ្ដាលមកពីមេរោគប្នឺម៉ូកូក** គឺជាមូលហេតុចំបងនៃឈឺនិងមានអត្រាស្លាប់ខ្ពស់នៅទូទាំងពិភពលោក ជាពិសេសនៅប្រទេសកំពុងអភិវឌ្ឍ ដូចជានៅក្នុងអនុតំបន់សាហារ៉ា ទ្វីបអាហ្វ្រិក និងអាស៊ី ភាគច្រើនកុមារវ័យក្មេងនិងមនុស្សចាស់ ។ សម្រាប់ទារកកត្តាដែលជាហានិភ័យនៃមេរោគប្នឺម៉ូកូកគឺជំងឺរលាកសួត រួមមានការខ្វះខាតនៃការបំបៅដោះកូននិងការប៉ះពាល់ទៅនឹងផ្សែងបារី ។ល។ ការឆ្លងមេរោគអេដស៍ ជំងឺ asplenia ជំងឺតម្រងនោមរ៉ាំរ៉ៃ ជំងឺផ្កាសាយក៏ជាកត្តាហានិភ័យសម្រាប់មនុស្សគ្រប់វ័យផងដែរ។

## ១០.២.តើទំរង់នៃជំងឺដែលបណ្ដាលមកពីមេរោគប្នឺម៉ូកូកយ៉ាងដូចម្ដេច?

**មូលហេតុបង្កដោយមេរោគប្នឺម៉ូកូកមាន**ពីរទម្រង់គឺទម្រង់ធ្ងន់ធ្ងរនិងទម្រង់មិនធ្ងន់ធ្ងរ ។ មេរោគប្នឺម៉ូកូក(Pneumococci) តែងតែមាននៅក្នុងច្រមុះនិងនៅក្នុងបំពង់ករវាមិនបានបង្ហាញជារោគសញ្ញាអ្វីឡើយ ទោះបីជាពេលខ្លះវាមានសមាមាត្រខ្ពស់នៅក្នុងច្រមុះ និង បំពង់កររបស់កុមារក៏ដោយ។ពេលខ្លះមេរោគមេរោគនៅផ្នែកច្រមុះ និង បំពង់ករអាចសាយភាយចូលទៅដល់ក្នុងឈាម។

**នៅពេលបាក់តេរីចូលទៅដល់ក្នុងឈាម** វាបង្កអោយរលាកស្រោមខួរក្បាល ។ ជំងឺដែលបង្កដោយបាក់តេរីនៅក្នុងឈាម នេះបន្ទាប់មកវាសាយភាយទៅកន្លែងផ្សេងៗទៀត រួចប្រមូលផ្តុំគ្នាបានច្រើនបង្កបង្កើតទៅជាជំងឺមួយដែលបណ្ដាល មកពីមេរោគប្នឺម៉ូកូកហើយរាតត្បាត(Invasive Pneumococcal Disease "IPD")។ មេរោគប្នឺម៉ូកូកគឺ(Pneumococci)ឆ្លងតាមរយៈការដកដង្ហើមច្រមុះ និង បំពង់ករចូលទៅក្នុងសួត។ព្រមទាំងវាបង្កឲ្យទៅជាជំងឺហើមសួត ។ ហើយសាយភាយទៅកន្លែងដ៏ទៃទៀតដូចជានៅត្រចៀកកណ្ដាលវាបណ្ដាល

អោយរលាកត្រចៀកកណ្តាល(Otitis media) កើតអំបៅអំបែកឬរលាកខ្ចង់ច្រមុះ(Sinusitis) ហើយភាគច្រើនទំរង់ដែលធ្ងន់ធ្ងរនៃមេរោគប្ញឹម៉ូកូកគី(Pneumococci) ហើយភាគខ្លះបណ្តាលអោយរលាកស្រោមខួរក្បាលដែលបណ្តាលអោយស្លាប់ឬក៏ពិការភាព។

## ១០.៣. តើជំងឺដែលបណ្តាលមកពីមេរោគប្ញឹម៉ូកូកឆ្លងយ៉ាងដូចម្តេច?

ជំងឺដែលបណ្តាលមកពីមេរោគប្ញឹម៉ូកូកឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀតតាមរយៈក្អក ក្រដាស ឬអ្នកដែលរស់នៅជាមួយអ្នកជំងឺដែលបង្កឡើងដោយមេរោគប្ញឹម៉ូកូក។

## ១០.៤. តើរោគសញ្ញានៃជំងឺដែលបណ្តាលមកពីមេរោគប្ញឹម៉ូកូកមានអ្វីខ្លះ ?

ដោយសារតែ pneumococcus នេះវាបង្កឡើងនៅផ្នែកជាច្រើននៃរាងកាយដូចនេះរោគសញ្ញាប្រែប្រួលអាស្រ័យលើទីតាំងនៃការដែលវាបង្ករ ដូចជាជំងឺរលាកសួតមានរោគសញ្ញាគ្រុន ក្តៅ ក្អក ហត់ ។ល។

## ១០.៥. តើការធ្វើរោគវិនិច្ឆ័យជំងឺដែលបណ្តាលមកពីមេរោគប្ញឹម៉ូកូកឆ្លងយ៉ាងដូចម្តេច?

**ជាការពិបាកបំផុតក្នុងការធ្វើរោគវិនិច្ឆ័យ**ទៅលើជំងឺដែលបណ្តាលមកពីមេរោគប្ញឹម៉ូកូក ហើយពិសេសទៅទៀតនោះពេលយើងយកវត្ថុវិភាគទៅធ្វើការវិភាគនៅមន្ទីរពិសោធន៍នោះ ក៏រកមិនឃើញបាក់តេរីដែលបង្ករោគដែរ ដោយហេតុថា មេរោគភាគច្រើនវាផ្តុំគ្នានៅក្នុងសួតដែលយើងមិនអាចយកវត្ថុវិភាគនៅក្នុងសួតមកធ្វើវិភាគនៅមន្ទីរពិសោធន៍បាន ។ ចំណែកឯមេរោគដែលនៅក្នុងឈាមវិញមានបរិមាណតិចតួចបំផុតមិនអាចយកមកធ្វើរោគវិនិច្ឆ័យនៅមន្ទីរពិសោធន៍បានដែរ ។ ករណីរលាកស្រោមខួរក្បាលវិញយើងបូមយកទឹកខួរឆ្អឹងខ្នង (CSF)ទៅធ្វើការវិភាគតាមរយៈការបណ្តុះរកមើលបាក់តេរី ។ ការធ្វើការបណ្តុះបាក់តេរីនៅមន្ទីរពិសោធន៍ភាគច្រើនពិបាកធ្វើរោគវិនិច្ឆ័យ ពីព្រោះបាក់តេរីនេះពិបាកបណ្តុះណាស់ ទោះបីជាយើងយកឈាមទៅពិនិត្យឬ ទឹកខួរឆ្អឹងខ្នង (CSF) យកទៅវិភាគក៏ដោយ ក៏នៅតែពិបាកធ្វើរោគវិនិច្ឆ័យនៃជំងឺ ដែល បណ្តាល មកពីមេរោគប្ញឹម៉ូកូកដែរ ។

## ១០.៦. តើក្រុមអាយុដែលប្រឈមនិងជំងឺដែលបណ្តាលមកពីមេរោគប្ញឹម៉ូកូកជាងគេ?

**កុមារអាយុក្រោម៥ឆ្នាំ** ជាពិសេសចំពោះកុមារអាយុក្រោម២ឆ្នាំជាអ្នកប្រឈមមុខយ៉ាងធ្ងន់ធ្ងរជាងគេ ហើយភាគច្រើនស្លាប់ដោយសារជំងឺដែលបណ្តាលមកពីមេរោគប្ញឹម៉ូកូកនេះ ។ នៅប្រទេសដែលកំពុងអភិវឌ្ឍន៍អត្រាស្លាប់អាចលើសពី២០%បណ្តាលមកពីជំងឺរលាកសួត និង លើសពី៥០%បណ្តាលពីជំងឺរលាកស្រោមខួរក្បាលដោយសារការកង្វះការបំបៅដោះក្នុង៦ខែដំបូង កង្វះចំណីអាហារ ហើយបរិយាកាសមិនល្អជា កត្តាប្រឈមមុខនៃជំងឺនេះ ដោយរួមបញ្ចូលទាំងរលាកសួតដោយសារមេរោគប្ញឹម៉ូកូកទៅលើកុមារ និង កុមារតូចៗជារួមកុមារអាយុតិចជាង២ឆ្នាំជាអ្នកដែលប្រឈមមុខខ្ពស់នៃអាំងស៊ីដង់ជំងឺដែលបណ្តាលមកពីមេរោគប្ញឹម៉ូកូក ជាងមនុស្សចាស់ (លើសពីអាយុ៦៥ឆ្នាំ) ហើយជាពិសេសចំពោះអ្នកពិសារបារី និង ផឹកស្រា ។ ការប្រឈមមុខខ្ពស់មួយទៀតគឺអ្នកដែលមានជំងឺបេះដូង អ្នកមានជំងឺសួត អ្នកមានជំងឺទឹកនោមផ្អែម ជំងឺខ្សោយតម្រងនោមរ៉ាំរ៉ៃ ឬ ករណីជំងឺផ្សេងទៀត ដូចជាអ្នកមានប្រព័ន្ធភាពស៊ាំចុះខ្សោយ (HIV) ជាដើម សុទ្ធសឹងជាជំពូកមនុស្សប្រឈមមុខនឹងជំងឺនេះ។ អ្នកកើតជំងឺផ្តាសាយក៏ជាអ្នកប្រឈមមុខនឹងជំងឺរលាកសួតដោយប្ញឹម៉ូកូកផងដែរ។

## ១០.៧. តើការព្យាបាលនៃជំងឺដែលបណ្តាលមកពីមេរោគប្នឺម៉ូកូកយ៉ាងដូចម្តេច ?

**ជំងឺដែលបណ្តាលមកពីមេរោគប្នឺម៉ូកូក** ដោយរាប់បញ្ចូលទាំងជំងឺរលាកសួត និង រលាកស្រោមខួរក្បាល ផងនោះអាចព្យាបាលបានដោយប្រើឱសថអង់ទីប៊ីយ៉ូទិកបាន ជាធម្មតាគេប្រើឱសថប្រភេទអាម៉ុកស៊ីលីន ប៉ុន្តែប្រភេទនៃមេរោគភាគច្រើននៃជំងឺនេះមានភាពស៊ាំទៅនឹងអង់ទីប៊ីយ៉ូទិក ហើយការព្យាបាលដោយឱសថអង់ទីប៊ីយ៉ូទិកនេះវិញមានតំលៃខ្ពស់ទៀតផង។ ដូចនេះយុទ្ធសាស្រ្តដែលល្អបំផុតនោះគឺមានតែចាក់ វ៉ាក់សាំងការពារជំងឺនេះទេទើបការពារ និង កាត់បន្ថយអត្រាឈឺ និង ស្លាប់បាន។

## ១០.៨. តើហេតុអ្វីបានជាត្រូវចាក់វ៉ាក់សាំងការពារជំងឺនេះ?

**ការប្រឈមមុខនៃជំងឺនេះធ្ងន់ធ្ងរបំផុត**នៅក្នុងរយៈពេល២៤ខែដំបូង។ជំងឺដែលបណ្តាលមកពីមេរោគប្នឺម៉ូកូកអាចអោយអាត្រាស្លាប់ខ្ពស់ ពិសេសនៅពេលដែលមិនមានការព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិក ឬក៏ការព្យាបាលមិនបានត្រឹមត្រូវ ។ វ៉ាក់សាំងអាចការពារបានអោយចាកផុតពីការស្លាប់ និង ពិការភាពជាពិសេសនៅក្នុងប្រទេសក្រីក្រ ។

### ចំណុចសំខាន់៖

- ជំងឺដែលបណ្តាលមកពីមេរោគប្នឺម៉ូកូក គឺជាជំងឺទាំងឡាយណាដែលបង្ករដោយបាក់តេរីដែលគេហៅស្រ្តិបតូកូកប្នឺម៉ូនីញៀរ (Streptococcus Pneumonia) ហើយដែលគេស្គាល់ជាទូទៅថាជាប្នឺម៉ូកូក (Pneumococcus)។ ការបង្ការរោគដោយរបស់ប្នឺម៉ូកូក (Pneumococcal infection) គឺមាននៅផ្នែកផ្សេងៗនៃសរីរាង្គ ។ ជំងឺដែលវាបង្ករឡើងដោយមេរោគប្នឺម៉ូកូក សុទ្ធសឹងជាជំងឺធ្ងន់ធ្ងរដូចជា៖(១)ជំងឺជំងឺរលាកសួត (២) ជំងឺរលាកស្រោមខួរក្បាល (៣)ជំងឺដែលបង្ករឡើងដោយបាក់តេរីនៅក្នុងឈាម (Bacteremia) (៤)ជំងឺរលាកត្រចៀកកណ្តាល(Otitis media) (៥)រលាកឆ្អឹងច្រមុះ ( Sinusitis) និង (៦)ជំងឺរលាកទងសួត(Bronchiolitis) ជាដើម។
- ជំងឺដែលបណ្តាលមកពីមេរោគប្នឺម៉ូកូក គឺជាមូលហេតុចំបងនៃឈឺនិងមានអត្រាស្លាប់ខ្ពស់នៅទូទាំងពិភពលោក ជាពិសេសនៅប្រទេសកំពុងអភិវឌ្ឍ ដូចជានៅក្នុងអនុតំបន់សាហារ៉ា ទ្វីបអាហ្វ្រិក និង អាស៊ី ភាគច្រើនកុមារវ័យក្មេងនិងមនុស្សចាស់។ សម្រាប់ទារកកត្តាដែលជាហានិភ័យនៃមេរោគប្នឺម៉ូកូកគឺជំងឺរលាកសួត រួមមានការខ្វះខាតនៃការបំបៅដោះកូននិងការប៉ះពាល់ទៅនឹងផ្សែងបារី ។ល។ ការឆ្លងមេរោគអេដស៍ ជំងឺ asplenia ជំងឺតម្រងនោមរ៉ាំរ៉ៃ ជំងឺផ្កាសាយក៏ជាកត្តាហានិភ័យសម្រាប់មនុស្សគ្រប់វ័យផងដែរ។
- ការប្រឈមមុខនៃជំងឺនេះធ្ងន់ធ្ងរបំផុតនៅក្នុងរយៈពេល២៤ខែដំបូង។ជំងឺដែលបណ្តាល មកពីមេរោគប្នឺម៉ូកូកអាចអោយអាត្រាស្លាប់ខ្ពស់ ពិសេសនៅពេលដែលមិនមានការព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិក ឬក៏ការព្យាបាលមិនបានត្រឹមត្រូវ ។ វ៉ាក់សាំងអាចការពារបានអោយចាកផុតពីការស្លាប់ និង ពិការភាជាពិសេសនៅក្នុងប្រទេសក្រីក្រ ។

# ១១. ជំងឺរលាកថ្លើមប្រភេទ បេ (Hepatitis B )

## ១១.១. តើជំងឺរលាកថ្លើមប្រភេទ បេគឺជាអ្វី?

**ជំងឺរលាកថ្លើមប្រភេទ បេ** គឺបណ្តាលមកពីមេរោគ (វីរុស)បង្ករោគនៅលើថ្លើម។ មនុស្សពេញវ័យ ដែលមានផ្ទុកជំងឺរលាកថ្លើមប្រភេទ បេ ជាធម្មតាប្រមាណ៩០% ជាសះស្បើយទាំងស្រុងដោយខ្លួន ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយចំពោះទារកស្ទើតែទាំងអស់(៩០%) ដែលឆ្លងមេរោគជំងឺរលាកថ្លើមប្រភេទ បេ ក្នុងអំឡុងពេលកើត ទារកនោះនិងក្លាយទៅជាអ្នកផ្ទុករ៉ាំរ៉ៃ។ ប្រជាជនប្រមាណ៨៧០.០០០ នាក់បានស្លាប់ជារៀងរាល់ឆ្នាំដោយសារតែផលវិបាកនៃជំងឺរលាកថ្លើមប្រភេទ បេ មានដូចជាជំងឺក្រិនថ្លើមឬមហារីកថ្លើម។

## ១១.២. តើជំងឺរលាកថ្លើមប្រភេទ បេឆ្លងយ៉ាងដូចម្តេច ?

វីរុសរលាកថ្លើមបេគឺមានផ្ទុកនៅក្នុងឈាមហើយនិងវត្ថុរាវដ៏ទៃទៀតដែលចេញពីមកពីសរីរាង្គកាយ ជំងឺរលាកថ្លើមប្រភេទ បេ ជាធម្មតាគឺឆ្លងតាមរយៈការប៉ះពាល់ទៅលើឈាមហើយនិងតាមរយៈផ្សេងទៀតដូចខាងក្រោម៖

- ចំលងមេរោគវីរុសពីម្តាយទៅទារកគឺឆ្លងនៅក្នុងអំឡុងពេលនៃសំរាលពីព្រោះទារកដែលទើបតែសំរាលនោះប៉ះពាល់ទៅលើឈាមរបស់ម្តាយ។
- ការចំលងរវាងកុមារទៅកុមារគឺតាមការប៉ះពាល់ទៅលើកន្លែងដែលមានស្នាមមុតដាច់ កោស ខាំ ហើយនឹងរអេសដាច់។
- ពីមនុស្សទៅមនុស្សក្នុងអំឡុងពេលរួមភេទដោយការប៉ះពាល់ទៅលើឈាម ឬ វត្ថុរាវដែលចេញពីមកពីសរីរាង្គកាយ។
- ចំលងតាមរយៈការចាក់ថ្នាំដោយគ្មានសុវត្ថិភាពនិងការចាក់សឺរ៉ាំងដែលមិនបានស្ងោររំងាប់មេរោគ គឺអាចចំលងមេរោគរលាកថ្លើមប្រភេបេ បានពីព្រោះដោយសារសឺរ៉ាំងហើយនឹងម្ជុលនោះត្រូវបានប្រើប្រាស់ដោយអ្នកជំងឺដែលមានផ្ទុករលាកថ្លើមប្រភេទបេ

***សរុបមកការឆ្លងមេរោគរលាកថ្លើមប្រភេទ បេ គឺ ៥០ ទៅ ១០០ ដងច្រើនទៀតការឆ្លងមេរោគអេដស៍។***

## ១១.៣. តើរោគសញ្ញានិងអាការៈរោគរបស់ជំងឺរលាកថ្លើមប្រភេទ បេគឺជាអ្វី ?

រលាកថ្លើមប្រភេទ បេ ស្រួចស្រាវជាញឹកញាប់មិនបង្កឱ្យមានការចេញរោគសញ្ញានិងអាការៈរោគនោះទេ ប៉ុន្តែនៅពេលដែលវាអ្នកជំងឺមានអាការៈរោគអស់កម្លាំង ចង្អោរ ក្អួត ឈឺពោះនិង រោគសញ្ញាលឿង (លឿងនៅលើស្បែកនិងត្របកភ្នែក) ។ ចំពោះអ្នកជំងឺរលាកថ្លើមប្រភេទ បេ រ៉ាំរ៉ៃសំដែងចេញនូវរោគសញ្ញានិងអាការៈរោគ

ដែលទាក់ទងទៅនឹងជំងឺរលាកថ្លើម (ដូចជាការស្តែងចេញនូវការហើមពោះ ការហូរឈាមមិនធម្មតានិងការផ្លាស់ប្តូរស្ថានភាពផ្លូវចិត្ត) នេះគឺជាការវិវឌ្ឍន៍នៃរោគសញ្ញាជំងឺរលាកថ្លើម ។

## ១១.៤. តើផលវិបាកនៃជំងឺរលាកថ្លើមប្រភេទ បេគឺជាអ្វី ?

មួយភាគតូចនៃការជំងឺរលាកថ្លើម បេ គឺអាចធ្វើអោយមានជំងឺធ្ងន់ធ្ងរហើយនិងអាចស្លាប់ ។ ផលវិបាកធ្ងន់ធ្ងរជាងគេគឺរួមមានជំងឺថ្លើមរ៉ាំរ៉ៃ កើតទាចទឹក ក្រិនថ្លើម ហើយនិងជំងឺបៅថ្លើម ជាពិសេសដចំពោះមនុស្សដែលមានផ្ទុកមេរោគរ៉ាំរ៉ៃ។

## ១១.៥. តើជំងឺរលាកថ្លើមប្រភេទ បេ ត្រូវការអ្វីដើម្បីព្យាបាល ?

គ្មានឱសថសំរាប់ព្យាបាលជំងឺរលាកថ្លើម បេ នេះទេ ប៉ុន្តែសំរាប់ឱសថជំនួយវិញគឺមាន ។ ចំពោះប្រភេទជំងឺថ្លើមរ៉ាំរ៉ៃ ករណីខ្លះអាចព្យាបាលជាផងដែរជាឱសថ ដូចជា interferon and antiviral agents។

## ១១.៦. តើជំងឺរលាកថ្លើមប្រភេទ បេ ត្រូវការអ្វីដើម្បីការពារ ?

ជំងឺរលាកថ្លើមប្រភេទបេ អាចការពារបានដោយសារការផ្តល់ថ្នាំបង្ការ។ ការចំលងមេរោគវីរុសពីម្តាយទៅទារកគឺឆ្លងនៅក្នុងអំឡុងពេលនៃសំរាលគឺជាមូលហេតុសំខាន់ដែលបង្ការអោយទៅជាជំងឺរ៉ាំរ៉ៃនៅទូទាំងពិភពលោក ដូចនេះទារកត្រូវតែផ្តល់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទបេ ដូសពេលកើតមួយដង នៅពេលកើតភ្លាម(តិចជាង២៤ម៉ោងក្រោយពីពេលកើត) ។ បន្ទាប់ពីផ្តល់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទបេ ដូសពេលកើត កុមារត្រូវតែផ្តល់វ៉ាក់សាំង DPT-Hep B-Hib ៣ ដូសទៀតគឺ លើកទី១នៅពេលកុមារអាយុបាន៦សប្តាហ៍ លើកទី២នៅពេលកុមារអាយុបាន១០សប្តាហ៍ និង លើកទី៣នៅពេលកុមារអាយុបាន១៤សប្តាហ៍។

**ចំណុចសំខាន់៖**

- ❖ ជំងឺរលាកថ្លើមប្រភេទ បេ គឺបណ្តាលមកពីមេរោគ (វីរុស)បង្ករោគនៅលើថ្លើម។ មនុស្សពេញវ័យ ដែលមានផ្ទុកជំងឺរលាកថ្លើមប្រភេទ បេ ជាធម្មតាប្រមាណ៩០% ជាសះស្បើយទាំងស្រុងដោយខ្លួន ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយចំពោះទារកស្ទើរតែទាំងអស់ដែលឆ្លងមេរោគជំងឺរលាកថ្លើមប្រភេទ បេ ក្នុងអំឡុងពេលកើត ទារកនោះនិងក្លាយទៅជាអ្នកផ្ទុករ៉ាំរ៉ៃ ។
- ❖ ជំងឺរលាកថ្លើមប្រភេទបេ អាចការពារបានដោយ វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទបេគឺ ផ្តល់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទបេដូសពេលកើតមួយដងនៅពេលកើតភ្លាម(តិចជាង២៤ម៉ោងក្រោយពីពេលកើត) ។ បន្ទាប់ពីផ្តល់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទបេ ដូសពេលកើត កុមារត្រូវតែផ្តល់វ៉ាក់សាំង DPT-Hep B-Hib ៣ ដូសទៀតគឺ លើកទី១នៅពេលកុមារអាយុបាន៦សប្តាហ៍ លើកទី២នៅពេលកុមារអាយុបាន១០សប្តាហ៍ និង លើកទី៣នៅពេលកុមារអាយុបាន១៤សប្តាហ៍។

# ជំពូកទី២៖

# ការរៀបចំទិវាផ្តល់ថ្នាំបង្ការ

# ១. ការរៀបចំទិវាផ្តល់ថ្នាំបង្ការ

## ១. ផែនទីនៅតំបន់គ្របដណ្តប់

គ្រប់ខេត្ត ស្រុកប្រតិបត្តិ និង មណ្ឌលសុខភាពត្រូវមានផែនទី។ គោលបំណងនៃការគូសផែនទីគឺចង់បង្ហាញអំពីប្រជាជនតាំងនៅគ្រប់កន្លែងតំបន់គ្របដណ្តប់ ។ ផែនទីមានពត៌មានលំអិតគឺជាមូលដ្ឋាននៃការធ្វើផែនការទិវាផ្តល់ថ្នាំបង្ការនិង ធ្វើផែនការអនុវត្តបានត្រឹមត្រូវ។ ទាំងនេះជាប្រភពព័ត៌មាននៃសកម្មភាពផ្តល់ថ្នាំបង្ការជាប្រចាំ ។

## ១. ១. ផែនទីមណ្ឌលសុខភាព

ផែនទីមណ្ឌលសុខភាពជាផែនទីដែលមានកលក្ខណធម្មតាហើយសំខាន់បំផុតនោះគឺត្រូវមានតំបន់គ្របដណ្តប់របស់មណ្ឌលសុខភាព ។ ការគូសផែនទីប្រតិបត្តការរបស់មណ្ឌលសុខភាពត្រូវមាន៖

- ដៅទីតាំង ភូមិ ឬក៏សហគមន៍នៃតំបន់គ្របដណ្តប់របស់មណ្ឌលសុខភាព
- សរសេរឈ្មោះ សហគមន៍ក្រីក្រដែលងាយរងគ្រោះ ឬប្រជាជនចល័ត ដោយ បូក អ្នកចំណូលថ្មី មកពីតំបន់ផ្សេងៗទៀត ។
- ទីតាំងមួយចំនួនទៀតដូចជា វត្ត សាលារៀន ផ្សារ ទីក្រុង ។ល។
- ប្រជាជនសរុប ប្រជាជនចំណុចសរុបនៃភូមិឬក៏សហគមន៍ នៃតំបន់គ្របដណ្តប់របស់មណ្ឌលសុខភាព
- ចំងាយផ្លូវពីមណ្ឌលសុខភាពទៅភូមិនិមួយៗ និងរយៈពេល ។
- ឈ្មោះអ្នកស្ម័គចិត្តតាមភូមិ និងលេខទូរសព្ទ័របស់គាត់ ។

## ១. ២. ផែនទីស្រុកប្រតិបត្តិ

ផែនទីស្រុកប្រតិបត្តិជាផែនទីដែលមានកលក្ខណធម្មតាហើយសំខាន់បំផុតនោះគឺត្រូវដៅឈ្មោះមណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព និង មន្ទីពេទ្យបង្អែក។ ការគូសផែនទីស្រុកប្រតិបត្តិត្រូវមាន៖

- ដៅទីតាំង មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព និង មន្ទីពេទ្យបង្អែក។
- សរសេរឈ្មោះ មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព និង មន្ទីពេទ្យបង្អែក។
- ទីតាំងមួយចំនួនទៀតដូចជា វត្ត សាលារៀន ផ្សារ ទីក្រុង ។ល។
- ប្រជាជនសរុប ប្រជាជនចំណុចសរុបនៃមណ្ឌលសុខភាព និង ប៉ុស្តិ៍សុខភាព ។
- ចំងាយផ្លូវពីស្រុកប្រតិបត្តិទៅមណ្ឌលសុខភាព និង ប៉ុស្តិ៍សុខភាពនិមួយៗ និងរយៈពេល ។

## ១. ៣. ផែនទីខេត្ត

ផែនទីខេត្តជាផែនទីដែលមានកលក្ខណធម្មតាហើយសំខាន់បំផុតនោះគឺត្រូវដៅឈ្មោះស្រុកប្រតិបត្តិ។ ការគូសផែនទីខេត្តត្រូវមាន៖

- ដៅទីតាំង ស្រុកប្រតិបត្តិនិង មន្ទីពេទ្យបង្អែកខេត្ត។
- សរសេរឈ្មោះ ស្រុកប្រតិបត្តិនិង មន្ទីពេទ្យបង្អែកខេត្ត។

- ទីតាំងមួយចំនួនទៀតដូចជា វត្ត សាលារៀន ផ្សារ ទីក្រុង ។ល។
- ប្រជាជនសរុប ប្រជាជនចំណុចសរុបនៃស្រុកប្រតិបត្តិ។
- ចំងាយផ្លូវពីខេត្តទៅស្រុកប្រតិបត្តិ និងរយៈពេល ។

## ២. ការចងក្រងផែនការលំអិតរបស់មណ្ឌលសុខភាព

មណ្ឌលសុខភាពទាំងអស់ត្រូវតែមានផែនការនៃទិវាផ្តល់ថ្នាំបង្ការរបស់ខ្លួនអោយបានលំអិតនិងច្បាស់លាស់ដោយផ្អែកទៅលើផែនទីគ្របដណ្តប់របស់មណ្ឌលសុខភាព ហើយនាថាគ្រប់សហគមន៍និងក្រុមប្រជាជនចំណុចទាំងអស់ទទួលបានថ្នាំបង្ការទៅតាមប្រតិទិននៃការផ្តល់ថ្នាំបង្ការ ។ ការផ្តល់ថ្នាំបង្ការតាមភូមិសម្រាប់ត្រីមាសទី១(បីខែ)ដោយបង្ហាញចំនួនទិវាក្នុងមួយត្រីមាស នៅតាមតំបន់និមួយៗ ដោយយោងទៅតាមផែនការទិវា ។ វាអាចមានមួយទិវាសម្រាប់រយៈពេល១ថ្ងៃ ។ មណ្ឌលសុខភាពនីមួយៗត្រូវតែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនិងយ៉ាងទៀងទាត់ជាមួយអ្នកស្ម័គ្រចិត្តភូមិ តំណាង សហគមន៍ និង អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់។ ធានាថារាល់ក្រុមចំណុចទាំងអស់មានប័ណ្ណផ្តល់ថ្នាំបង្ការត្រឹមត្រូវ/តាមកំណត់(ប័ណ្ណលឿង ប័ណ្ណតេតាណូសពណ៌ផ្កាឈូក ប័ណ្ណសកត់ត្រាសុខភាពមាតា) ។ ការផ្តល់ថ្នាំបង្ការត្រូវឱ្យបានទៀងទាត់តាមកាលវិភាគ និង ធានាថាការផ្តល់ថ្នាំបង្ការមាននៅគ្រប់ពេលវេលា។

មណ្ឌលសុខភាពត្រូវបំពេញនូវព័ត៌មានមួយចំនួនដែលទាក់ទងទៅនឹងស្ថានភាពភូមិសាស្ត្រ និង ប្រជាសាស្ត្រដូចខាងក្រោម (២តារាងទី)៖

- ឈ្មោះភូមិឬសហគមន៍ទាំងងាយរងគ្រោះ និង រងគ្រោះ
- ចំងាយពីមណ្ឌលសុខភាពទៅភូមិឬសហគមន៍
- ចំនួនប្រជាជនសរុបនៅក្នុងឆ្នាំនីមួយៗ
- ចំនួនកុមារអាយុក្រោម១ឆ្នាំ ក្នុង១ឆ្នាំនៃឆ្នាំនីមួយៗ
- ចំនួនស្ត្រីមានផ្ទៃពោះក្នុង១ឆ្នាំនៃឆ្នាំនីមួយៗ
- ចំនួនស្ត្រីអាយុពី ១៥-៤៤ឆ្នាំក្នុង១ឆ្នាំនៃឆ្នាំនីមួយៗ
- ឈ្មោះអ្នកស្ម័គ្រចិត្ត
- លេខទូរស័ព្ទអ្នកស្ម័គ្រចិត្ត

**តារាង ២ ៖ ឈ្មោះភូមិនៅក្នុងតំបន់គ្របដណ្តប់របស់មណ្ឌលសុខភាព**

មណ្ឌលសុខភាព៖.....................ខេត្ត៖...............................ស្រុកប្រតិបត្តិ៖........................................

| ល.រ | ឈ្មោះភូមិ | ប្រជាជនសរុប | កុមារចំណុច ក្រោម ១ឆ្នាំ | ស្ត្រី មានផ្ទៃពោះ | ស្ត្រី ១៥-៤៩ឆ្នាំ | ចំងាយពីភូមិ មកមណ្ឌលសុខភាព | ឈ្មោះអ្នក ស្ម័គ្រចិត្ត | លេខទូរស័ព្ទ អ្នកស្ម័គ្រចិត្ត |
|---|---|---|---|---|---|---|---|---|
| ១ | | | | | | | | |
| ២ | | | | | | | | |
| ៣ | | | | | | | | |
| ៤ | | | | | | | | |
| ៥ | | | | | | | | |
| ៦ | | | | | | | | |
| ៧ | | | | | | | | |
| ៨ | | | | | | | | |
| ៩ | | | | | | | | |
| ១០ | | | | | | | | |

តារាងទី៤៖ផែនការលំអិតនៃការចុះផ្តល់ថ្នាំបង្ការ .តាមឆ្នាំ៖

| ឈ្មោះភូមិ | ចំនួនទិវាក្នុង ១ត្រីមាស | ឈ្មោះអ្នកស្ម័គ្រចិត្តនិង លេខទូរស័ព្ទ | ខែមករា | ខែកុម្ភៈ | ខែមិនា |
|---|---|---|---|---|---|
| | | | ផែនការ.............អនុវត្តន៍.......... មធ្យោបាយធ្វើដំណើរ៖ ........................................ ឈ្មោះអ្នកទទួលខុសត្រូវ ....................................... | ផែនការ.............អនុវត្តន៍.......... មធ្យោបាយធ្វើដំណើរ៖ ........................................ ឈ្មោះអ្នកទទួលខុសត្រូវ ....................................... | ផែនការ.............អនុវត្តន៍.......... មធ្យោបាយធ្វើដំណើរ៖ ........................................ ឈ្មោះអ្នកទទួលខុសត្រូវ ....................................... |
| | | | ផែនការ.............អនុវត្តន៍.......... មធ្យោបាយធ្វើដំណើរ៖ ........................................ ឈ្មោះអ្នកទទួលខុសត្រូវ ....................................... | ផែនការ.............អនុវត្តន៍.......... មធ្យោបាយធ្វើដំណើរ៖ ........................................ ឈ្មោះអ្នកទទួលខុសត្រូវ ....................................... | ផែនការ.............អនុវត្តន៍.......... មធ្យោបាយធ្វើដំណើរ៖ ........................................ ឈ្មោះអ្នកទទួលខុសត្រូវ ....................................... |
| | | | ផែនការ.............អនុវត្តន៍.......... មធ្យោបាយធ្វើដំណើរ៖ ........................................ ឈ្មោះអ្នកទទួលខុសត្រូវ ....................................... | ផែនការ.............អនុវត្តន៍.......... មធ្យោបាយធ្វើដំណើរ៖ ........................................ ឈ្មោះអ្នកទទួលខុសត្រូវ ....................................... | ផែនការ.............អនុវត្តន៍.......... មធ្យោបាយធ្វើដំណើរ៖ ........................................ ឈ្មោះអ្នកទទួលខុសត្រូវ ....................................... |

## ៣. ការផ្តល់ថ្នាំបង្ការនៅតាមភូមិ

ការផ្តល់ថ្នាំបង្ការតាមភូមិ៖ សហគមន៍ខ្លះឆ្ងាយពីមណ្ឌលសុខភាពតំរូវអោយធ្វើការផ្តល់ថ្នាំបង្ការតាមភូមិជៀសមិនរួច។ភូមិត្រូវមានការផ្តល់ថ្នាំបង្ការជារៀងរាល់ខែដោយយោលទៅតាមកុមារចំណុចតាមភូមិនិមួយៗ ដោយមិនអោយតិចជាង៤ដងក្នុង១ឆ្នាំដើម្បីអោយកុមារ បានទទួលវ៉ាក់សាំងគ្រប់ដូស ។

## ៤. ការផ្តល់ថ្នាំបង្ការរបស់មណ្ឌលសុខភាព

ភូមិដែលនៅជិតមណ្ឌលសុខភាពត្រូវធ្វើការផ្តល់ថ្នាំបង្ការនៅមណ្ឌលសុខភាព តែក៏មិនគួរកំណត់តែលើចំងាយពីមណ្ឌលសុខភាពទៅភូមិនោះទេគឺគួរកំណត់យកកត្តាសំខាន់ផ្សេងៗទៀតថាតើភូមិណាអាចផ្តល់ថ្នាំបង្ការនៅនឹងមណ្ឌលសុខភាព ហើយភូមិណាទៀតអាចផ្តល់ថ្នាំបង្ការតាមភូមិ ។ ទិវាផ្តល់ថ្នាំបង្ការរបស់មណ្ឌលសុខភាពដែលបានអនុវត្តរួចគួរតែបានធ្វើការត្រួតពិនិត្យហើយនឹងដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំខែអោយបានទៀងទាត់។

# ជំពូកទី៣៖

# តួនាទីរបស់កម្មវិធី និង ប្រព័ន្ធត្រជាក់

# សេចក្តីផ្តើម

**កម្មវិធីជាតិផ្តល់ថ្នាំបង្ការ** នៃមជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារកបាននិងកំពុងបញ្ចូលវ៉ាក់សាំងថ្មីជាបន្តបន្ទាប់រហូតមកដល់ពេលនេះមានវ៉ាក់សាំងចំនួន១២មុខ ដែលបានបញ្ចូលទៅក្នុងសកម្មភាពផ្តល់ថ្នាំបង្ការជាប្រចាំ វ៉ាក់សាំងទាំងនោះរួមមាន៖ វ៉ាក់សាំងការពារជំងឺរបេង រលាកថ្លើមប្រភេទបេ ក្អកមាន់ ខាន់ស្លាក់ តេតាណូស រលាកសួត-រលាកស្រោមខួរក្បាលដែលបង្កដោយមេរោគហ៊ីប រលាកសួត-រលាកស្រោមខួរក្បាលដែលបង្កដោយមេរោគភ្នឺម៉ូកូក គ្រុនស្វិតដៃជើងប្រភេទបន្តក់ គ្រុនស្វិតដៃជើងប្រភេទចាក់ កញ្ជ្រឹល-ស្អូច និង រលាកខួរក្បាលជេអ៊ី ។

វ៉ាក់សាំងទាំងនេះផ្គត់ផ្គង់ដោយអង្គការមូលនិធិសម្រាប់កុមារនៃអង្គការសហប្រជាជាតិ(យូនីសេហ្វ) និងទទួលស្គាល់ត្រឹមត្រូវពីអង្គការសុខភាពពិភពលោក ។ វ៉ាក់សាំងទាំងនេះមាន៖

១. វ៉ាក់សាំងការពារជំងឺរបេង BCG
២. វ៉ាក់សាំងការពារជំងឺ ខាន់ស្លាក់ ក្អកមាន់ តេតាណូស រលាកថ្លើមប្រភេទបេ និង រលាកសួត-រលាកស្រោមខួរក្បាលដែលបង្កដោយមេរោគហ៊ីប DPT-HepB-Hib
៣. វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទបេ ដូសពេលកើត
៤. វ៉ាក់សាំងការពារជំងឺតេតាណូស
៥. វ៉ាក់សាំងការពារជំងឺគ្រុនស្វិតដៃជើងប្រភេទបន្តក់ OPV
៦. វ៉ាក់សាំងការពារជំងឺគ្រុនស្វិតដៃជើងប្រភេទចាក់ IPV
៧. វ៉ាក់សាំងការពារជំងឺ កញ្ជ្រឹល-ស្អូច MR
៨. វ៉ាក់សាំងជេអ៊ី (SA 14-14-2 JE)
៩. វ៉ាក់សាំងការពារជំងឺរលាកសួត-រលាកស្រោមខួរក្បាលដែលបង្កដោយមេរោគភ្នឺម៉ូកូក PCV13

# ១. វ៉ាក់សាំងការពារជំងឺរបេង ( BCG )

| | |
|---|---|
| វ៉ាក់សាំងការពារជំងឺរបេង (BCG) | • ជាប្រភេទវ៉ាក់សាំងរស់ ( live bacterial)<br>• ភាពសាហាវរបស់វាត្រូវបានកាត់បន្ថយ ពុំអាចអោយមានជំងឺបាន |
| ចំនួនដូសដែលត្រូវផ្តល់អោយ | • ផ្តល់តែមួយដូសគត់ |
| កំរិតផ្តល់ | • 0.0៥ ម.ល |
| ប្រតិទិនត្រូវផ្តល់អោយ | • ផ្តល់នៅពេលបន្ទាប់ពីកើត<br>• អាចផ្តល់អោយបានតែទារកឬកុមារអាយុក្រោម១ឆ្នាំតែប៉ុណ្ណោះ។ |
| ការផ្តល់បន្ថែម | • គ្មាន |
| របៀបផ្តល់ | • ចាក់សើស្បែក |
| កន្លែងផ្តល់ | • ស្មាឆ្វេង |
| បំរាមនៃការផ្តល់នៃវ៉ាក់សាំង | • កុមារកើតជំងឺអេដស៍បានគេស្គាល់ឬមានភាពស៊ាំចុះខ្សោយ |
| លក្ខខណ្ឌក្នុងការរក្សាទុក | • វ៉ាក់សាំងនេះត្រូវទុកដាក់ឱ្យបានសមស្របនិងរក្សាទុកនៅសីតុណ្ហ(ចន្លោះពី ២◦C ទៅ + ៨◦C)<br>• មិនត្រូវអោយកក<br>• ចោលក្រោយពេល លាយ៦ម៉ោង |
| ផលរំខាន | • ករណីកំរិតធ្ងន់ធ្ងរះជំងឺទូទៅឬការបង្ករអោយមានជំងឺដូចជា&រលាកឆ្អឹង (osteomyelitis) បូស( abscess) ការរលាកកូនកណ្តុរ (lymphadenitis)<br>• ករណីកំរិតស្រាលះ ប្រតិកម្មត្រង់កន្លែងចាក់ |

# ២. វ៉ាក់សាំងការពារជំងឺ ខាន់ស្លាក់ ក្អកមាន់ តេតាណូស រលាកថ្លើមប្រភេទបេ និង រលាកសួត-រលាកស្រោមខួរក្បាលដែលបង្កដោយមេរោគហ៊ីប (DPT-HepB-Hib)

| | |
|---|---|
| វ៉ាក់សាំង<br>(DPT-HepB-Hib) | • វ៉ាក់សាំងDPT-HepB-Hibជាវ៉ាក់សាំងរួមបញ្ចូលគ្នា៥មុខ (Pentavalents) ហើយវាអាចការពារ បានជំងឺ៥មុខ រួមមាន ជំងឺខាន់ស្លាក់ តេតាណូស ក្អកមាន់ រលាកថ្លើមប្រភេទបេ និង ជំងឺហ៊ីប ។ |
| ចំនួនដូសដែលត្រូវផ្តល់អោយ | • វ៉ាក់សាំងDPT-HepB-Hib វ៉ាក់សាំងរួមបញ្ចូលគ្នា៥មុខផ្តល់ចំនួនបីដង |
| កំរិតផ្តល់ | • 0,៥ ម.ល |
| ប្រតិទិនត្រូវផ្តល់អោយ | • វ៉ាក់សាំងDPT-HepB-Hib វ៉ាក់សាំងរួមបញ្ចូលគ្នា៥មុខផ្តល់ចំនួនបីដង លើកទី១ ៖ នៅពេលដែល កុមារមានអាយុ៦សប្តាហ៍<br>• លើកទី២ ៖ នៅពេលដែល កុមារមានអាយុ១០សប្តាហ៍<br>• លើកទី៣ ៖ នៅពេលដែល កុមារមានអាយុ១៤សប្តាហ៍ |
| ការផ្តល់បន្ថែម | • គ្មាន |
| របៀបផ្តល់ | • ចាក់សាច់ដុំ |
| កន្លែងផ្តល់ | • ភ្លៅស្តាំ |
| បំរាមនៃការផ្តល់នៃវ៉ាក់សាំង | • ធ្លាប់មានប្រតិកម្មធ្ងន់ធ្ងរក្រោយចាក់DTP-HepB-Hibលើកមុន<br>• គ្រុនក្តៅខ្លាំងលើសពី៣៩⁰C |
| លក្ខខណ្ឌក្នុងការរក្សាទុក | • វ៉ាក់សាំងនេះត្រូវទុកដាក់ឱ្យបានសមស្របនិងរក្សាទុកនៅសីតុណ្ហភាព (ចន្លោះពី ២°C ទៅ + ៨°C)<br>• មិនត្រូវអោយកក |
| ផលរំខាន | • ករណីកំរិតធ្ងន់ធ្ងរ៖ rare anaphylaxis<br>• ករណីកំរិតស្រាលៈ គ្រុនក្តៅ,ឈឺកន្លែងចាក់ |

# ៣. វ៉ាក់សាំងការពារជំងឺ រលាកថ្លើមប្រភេទបេ (HepB)

| | |
|---|---|
| វ៉ាក់សាំងរលាកថ្លើមប្រភេទបេ (HepB) | • វ៉ាក់សាំងរលាកថ្លើមប្រភេទបេ ដូសពេលកើត ហើយវាអាចការពាររលាកថ្លើមប្រភេទបេ ។ |
| ចំនួនដូសដែលត្រូវផ្តល់អោយ | • ផ្តល់តែមួយដូសគត់នៅពេលកើត (ក្រោម២៤ម៉ោង ក្រោយពេលកើត) |
| កំរិតផ្តល់ | • ០,៥ ម.ល |
| ប្រតិទិនត្រូវផ្តល់អោយ | • វ៉ាក់សាងរលាកថ្លើមប្រភេទបេ ដូសពេលកើត ផ្តល់តែម្តងគត់នៅពេលកើត (ក្រោម២៤ម៉ោង ក្រោយពេលកើត) |
| ការផ្តល់បន្ថែម | • គ្មាន |
| របៀបផ្តល់ | • ចាក់សាច់ដុំ |
| កន្លែងផ្តល់ | • ភ្លៅស្តាំ |
| បំរាមនៃការផ្តល់នៃវ៉ាក់សាំង | • គ្រុនក្តៅខ្លាំងលើសពី៣៩⁰C |
| លក្ខខណ្ឌក្នុងការរក្សាទុក | • វ៉ាក់សាំងនេះត្រូវទុកដាក់ឱ្យបានសមស្របនិងរក្សាទុកនៅសីតុណ្ហភាព (ចន្លោះពី ២◦C ទៅ + ៨◦C)<br>• មិនត្រូវអោយកក |
| ផលរំខាន | • ករណីកំរិតធ្ងន់ធ្ងរ៖ rare anaphylaxis<br>• ករណីកំរិតស្រាលៈ គ្រុនក្តៅ,ឈឺន្លែងចាក់ |

# ៤. វ៉ាក់សាំងការពារជំងឺតេតាណូស ( TT )

| | |
|---|---|
| វ៉ាក់សាំងការពារជំងឺតេតាណូស(TT) | • ពុកស៊ីន (Toxine ) របស់វាត្រូវបានកាត់បន្ថយអោយក្លាយជាពុកសយ (Toxoide) ពុំមានលទ្ធភាពបង្ករជំងឺ |
| ចំនួនដូសដែលត្រូវផ្តល់អោយ | • ចាក់ចំនួន៥ដង ចំពោះស្ត្រី |
| កំរិតផ្តល់ | • ០,៥ ម.ល |
| ប្រតិទិនត្រូវផ្តល់អោយ | • លើកទី១ ៖ ចាប់ពីអាយុ១៥ ឆ្នាំឡើងទៅ ឬចាប់ពីពេល មានផ្ទៃពោះ<br>• លើកទី២ ៖ មួយខែយ៉ាងតិច ក្រោយលើកទី ១<br>• លើកទី៣ ៖ ៦ខែយ៉ាងតិច ក្រោយលើកទី ២<br>• លើកទី៤ ៖ ១ឆ្នាំយ៉ាងតិច ក្រោយលើកទី ៣<br>• លើកទី៥ ៖ ១ឆ្នាំយ៉ាងតិច ក្រោយលើកទី ៤ |
| ការផ្តល់បន្ថែម | • មាន |
| របៀបផ្តល់ | • ចាក់សាច់ដុំ |
| កន្លែងផ្តល់ | • ស្មាស្តាំ |
| បំរាមនៃការផ្តល់នៃវ៉ាក់សាំង | • ធ្លាប់មាន ប្រតិកម្មធ្ងន់ធ្ងរ ក្រោយចាក់ លើកមុន |
| លក្ខខណ្ឌក្នុងការរក្សាទុក | • វ៉ាក់សាំងនេះត្រូវទុកដាក់ឱ្យបានសមស្របនិងរក្សាទុកនៅសីតុណ្ហភាព (ចន្លោះពី ២◦C ទៅ + ៨◦C)<br>• មិនត្រូវអោយកក<br>• ទុកប្រើបន្ត |
| ផលរំខាន | • ករណីកំរិតធ្ងន់ធ្ងរ៖ rare anaphylaxis, brachial neuritis<br>• ករណីកំរិតស្រាលៈ គ្រុនក្តៅ,ឈឺកន្លែងចាក់ |

# ៥. វ៉ាក់សាំងការពារជំងឺគ្រុនស្វិតដៃជើងប្រភេទបន្តក់ ( OPV )

| | |
|---|---|
| វ៉ាក់សាំងការពារជំងឺគ្រុនស្វិតដៃជើងប្រភេទបន្តក់ (OPV) | • ជាប្រភេទវ៉ាក់សាំងរស់ (Live attenuated)<br>• ភាពសាហាវរបស់វាត្រូវបានកាត់បន្ថយ |
| ចំនួនដូសដែលត្រូវផ្តល់ឲ្យ | • ផ្តល់ចំនួនបីដង |
| កំរិតផ្តល់ | • ២ដំណក់ |
| ប្រតិទិនត្រូវផ្តល់ឲ្យ | • លើកទី១ ៖ នៅពេលដែល កុមារមានអាយុ៦សប្តាហ៍<br>• លើកទី២ ៖ នៅពេលដែល កុមារមានអាយុ១០សប្តាហ៍<br>• លើកទី៣ ៖ នៅពេលដែល កុមារមានអាយុ១៤សប្តាហ៍ |
| ការផ្តល់បន្ថែម | • មាន |
| របៀបផ្តល់ | • បន្តក់ |
| កន្លែងផ្តល់ | • ផឹកតាមមាត់ |
| បំរាមនៃការផ្តល់នៃវ៉ាក់សាំង | • គ្មាន |
| លក្ខខណ្ឌក្នុងការរក្សាទុក | • វ៉ាក់សាំងនេះត្រូវទុកដាក់ឱ្យបានសមស្របនិងរក្សាទុកនៅសីតុណ្ហ(ចន្លោះពី ២◦C ទៅ + ៨◦C)<br>• មិនត្រូវអោយកក<br>• ទុកប្រើបន្ត |
| ផលរំខាន | • គ្មាន |

# ៦. វ៉ាក់សាំងការពារជំងឺគ្រុនស្វិតដៃជើងប្រភេទចាក់ ( IPV )

| | |
|---|---|
| វ៉ាក់សាំងការពារជំងឺគ្រុនស្វិតដៃជើងប្រភេទចាក់ (IPV) | • វ៉ាក់សាំង IPV ត្រូវបានផលិតពីប្រភេទវីរុសគ្រុនស្វិតដៃជើងដែលត្រូវបានគេ បង្អន់ភាពសាហាវ(បានសម្លាប់) ។ |
| ចំនួនដូសដែលត្រូវផ្តល់ឲ្យ | • វ៉ាក់សាំងIPVត្រូវផ្តល់ឱ្យកុមារតែមួយដូសគត់ |
| កំរិតផ្តល់ | • 0.៥ម.ល |
| ប្រតិទិនត្រូវផ្តល់ឲ្យ | • នៅកុមារមានអាយុ១៤សប្តាហ៍ |
| ការផ្តល់បន្ថែម | • គ្មាន |
| របៀបផ្តល់ | • ចាក់សាច់ដុំ |
| កន្លែងផ្តល់ | • ភ្លៅឆ្វេងខាងក្រោម២ម្រាមដៃ (២.៥ ស.ម) ពីចាក់ PCV. |
| បំរាមនៃការផ្តល់នៃវ៉ាក់សាំង | • វ៉ាក់សាំង IPVមិនគួរផ្តល់ឱ្យអ្នកដែលគេស្គាល់ឬដឹងថាមានប្រតិកម្មអាឡែហ្ស៊ី ជាមួយថ្នាំពេទ្យ Streptomycin, Neomycin ឬ Polymyxin B |
| លក្ខខណ្ឌក្នុងការរក្សាទុក | • វ៉ាក់សាំងនេះត្រូវទុកដាក់ឱ្យបានសមស្របនិងរក្សាទុកនៅសីតុណ្ហភាព (ចន្លោះពី ២∘C ទៅ + ៨∘C)<br>• មិនត្រូវអោយកក<br>• ទុកប្រើបន្ត |
| ផលរំខាន | • ហើមនិងឈឺនៅកន្លែងចាក់វ៉ាក់សាំង. |

# ៧. វ៉ាក់សាំងការពារជំងឺ កញ្ជ្រឹល-ស្អូច (MR)

| | |
|---|---|
| វ៉ាក់សាំងការពារជំងឺ កញ្ជ្រឹល-ស្អូច (MR) | • វ៉ាក់សាំងកញ្ជ្រឹល-ស្អូច(ជាប្រភេទវ៉ាក់សាំងរស់ដែលគេកាត់បន្ថយភាពសកម្មរបស់វា,កកស្ងួត)។<br>• វ៉ាក់សាំងជម្ងឺកញ្ជ្រឹល-ស្អូចអាចផ្តល់ឲ្យកុមារដែលមានផ្ទុកជំងឺ HIV បាន ។ |
| ចំនួនដូសដែលត្រូវផ្តល់ឲ្យ | • ផ្តល់ចំនួនពីរដូស |
| កំរិតផ្តល់ | • 0.៥ ម.ល |
| ប្រតិទិនត្រូវផ្តល់ឲ្យ | • លើកទី១ ៖ នៅពេលកុមារមានអាយុ៩ខែ<br>• លើកទី២ ៖ នៅពេលកុមារមានអាយុ១៨ខែ |
| ការផ្តល់បន្ថែម | • មាន |
| របៀបផ្តល់ | • ចាក់ក្រោមស្បែក |
| កន្លែងផ្តល់ | • ស្មាឆ្វេង |
| បំរាមនៃការផ្តល់នៃវ៉ាក់សាំង | • កុមារធ្លាប់ដឹងឬមានឯកសារបញ្ជាក់ថាមានប្រតិកម្មជាមួយ **Neomycin, Gelatine**<br>• ហាមផ្តល់ទៅលើស្ត្រីមានផ្ទៃពោះ ។<br>• វ៉ាក់សាំងជម្ងឺកញ្ជ្រឹល-ស្អូចហាមប្រើដាច់ខាត ចំពោះអ្នកដែលមានប្រតិកម្មជាមួយវ៉ាក់សាំងនេះពីកាលទទួលលើកមុន ។ |
| លក្ខខណ្ឌក្នុងការរក្សាទុក | • វ៉ាក់សាំងការពារជម្ងឺកញ្ជ្រឹល-ស្អូច ត្រូវរក្សាវាឲ្យនៅក្នុងកម្រិត សីតុណ្ហភាព (+២°Cទៅដល់+៨°C)។ មុនពេលចុះទិវា ទឹកលាយនិងទុកកន្លែងដូចវ៉ាក់សាំងការពារជម្ងឺកញ្ជ្រឹលដែរ ។ ម្យ៉ាងទៀតវ៉ាក់សាំងការពារជម្ងឺកញ្ជ្រឹល-ស្អូច ដែលបានលាយរួចត្រូវតែបោះចោលរយៈពេល៦ម៉ោងបន្ទាប់ពីលាយរួច ឬ នៅពេលបញ្ចប់ទិវាផ្តល់ថ្នាំបង្ការ ។<br>• មិនត្រូវទុកឲ្យប៉ះនឹងពន្លឺថ្ងៃ ។ |
| ផលរំខាន | • ហើមឈឺចាប់ក្រហាយឡើងក្រហមនៅកន្លែងចាក់ក្តៅខ្លួនបន្តិចបន្តួច |

# ៨. វ៉ាក់សាំងរលាកខួរក្បាលជេអ៊ី (SA 14-14-2 JE)

| | |
|---|---|
| វ៉ាក់សាំងរលាកខួរក្បាលជេអ៊ី (SA 14-14-2 JE) | • SA 14-14-2 គឺជាប្រភេទវ៉ាក់សាំងរស់ ដែលប្រើសម្រាប់ការពារជំងឺជេអ៊ី (Japanese Encephalitis)<br>• SA 14-14-2 គឺជាប្រភេទវ៉ាក់សាំងប្រើទឹកលាយ (Lyophilized ‘ i.e Freeze-dried ’)<br>• វ៉ាក់សាំងនេះជាប្រភេទម្សៅពណ៌សនៅក្នុងដប ។បន្ទាប់ពីលាយជាមួយទឹកលាយចូលគ្នាបានត្រឹមត្រូវ រួចមក វាជាល្បាយទឹកថ្លាពណ៌ស៊ីជម្ពូ / ទឹកក្រូច។ |
| ចំនួនដូសដែលត្រូវផ្តល់ឲ្យ | • ផ្តល់ចំនួនមួយដូសគត់ |
| កំរិតផ្តល់ | • 0.៥ ម.ល |
| ប្រតិទិនត្រូវផ្តល់ឲ្យ | • នៅពេលកុមារមានអាយុ៩ខែ |
| ការផ្តល់បន្ថែម | • គ្មាន |
| របៀបផ្តល់ | • ចាក់ក្រោមស្បែក |
| កន្លែងផ្តល់ | • ស្មាស្តាំ |
| បំរាមនៃការផ្តល់នៃវ៉ាក់សាំង | • កុមារដែលធ្លាប់មានប្រតិកម្មធ្ងន់ធ្ងរ (anaphylaxis) ទាក់ទងទៅនឹងវ៉ាក់សាំង JE SA 14-14-2, ប្រតិកម្ម hypersensitivity ធ្ងន់ធ្ងរធន់ ទៅនឹងធាតុផ្សំណាមួយ (gelatin, gentamicin) កុមារមានភាពស៊ាំពីកំណើតថយចុះ ឬ ទើបទទួលការព្យាបាលដោយimmunodepressive និងចំពោះកុមារមានជំងឺគ្រុនក្តៅ ការចាក់ថ្នាំបង្ការគួរត្រូវបានពន្យារពេលរហូតដល់ជំងឺគ្រុនបានជាសះស្បើយ |
| លក្ខខណ្ឌក្នុងការរក្សាទុក | • ត្រូវរក្សាវាអោយនៅក្នុងកម្រិត សីតុណ្ហភាព (+២◦Cទៅដល់+៨◦C)។ មុនពេលចុះទិវាទឹកលាយត្រូវទុកជាមួយវ៉ាក់សាំង។វ៉ាក់សាំងលាយរួចត្រូវតែបោះចោលរយៈពេល៦ម៉ោងបន្ទាប់ពីលាយរួច ។<br>• មិនត្រូវទុកឲ្យប៉ះនឹងពន្លឺថ្ងៃ ។ |
| ផលរំខាន | • មានប្រតិកម្មទូទៅៈ ក្តៅខ្លួន, ការរហើម, កន្ទួលក្រហម និង ឆាប់ខឹង មានមិនលើសពី ១ ទៅ ៣ ភាគរយឡើយ។ |

# ៩. វ៉ាក់សាំងការពារជម្ងឺរលាកសួត-រលាកស្រោមខួរក្បាលដោយប្រើម៉ូកូក (PCV)

| | |
|---|---|
| វ៉ាក់សាំងការពារជម្ងឺរលាកសួត-រលាកស្រោមខួរក្បាលដោយប្រើម៉ូកូក (PCV) | • វ៉ាក់សាំងPCV គឺជាវ៉ាក់សាំងមួយប្រភេទសម្រាប់ការពារនឹងជំងឺចំពោះកុមារដែលមានអាយុក្រោមពីរឆ្នាំ។វាការពារចំពោះទម្រង់ធ្ងន់ធ្ងរដែលបង្កឡើងដោយបាក់តេរីភ្នឺម៉ូកូកដូចជាជម្ងឺរលាកសួត ជម្ងឺរលាកស្រោមខួរក្បាល និងជម្ងឺដែលមានបាក់តេរីនៅក្នុងឈាម វ៉ាក់សាំងនេះវាមិនអាចការពារបានទេប្រសិនបើជម្ងឺដែលបង្កឡើងដោយបាក់តេរីផ្សេងពីបាក់តេរីភ្នឺម៉ូកូកឬក៏ទម្រង់ផ្សេងពីទម្រង់នៃវ៉ាក់សាំងដែលមាន។ វ៉ាក់សាំងPCV មានពីរប្រភេទដែលមានចាប់តាំងពីឆ្នាំ២០០៩មកម្លេះ ៖ |
| ចំនួនដូសដែលត្រូវផ្តល់ឲ្យ | • ផ្តល់ចំនួនបីដង |
| កំរិតផ្តល់ | • ០,៥ ម.ល |
| ប្រតិទិនត្រូវផ្តល់ឲ្យ | • លើកទី១ ៖ នៅពេលដែល កុមារមានអាយុ៦សប្តាហ៍<br>• លើកទី២ ៖ នៅពេលដែល កុមារមានអាយុ១០សប្តាហ៍<br>• លើកទី៣ ៖ នៅពេលដែល កុមារមានអាយុ១៤សប្តាហ៍ |
| ការផ្តល់បន្ថែម | • គ្មាន |
| របៀបផ្តល់ | • ចាក់សាច់ដុំ |
| កន្លែងផ្តល់ | • ភ្លៅខាងឆ្វេង |
| បំរាមនៃការផ្តល់នៃវ៉ាក់សាំង | • វ៉ាក់សាំងPCVមិនត្រូវផ្តល់ចំពោះកុមារទាំងឡាយណាធ្លាប់មានប្រតិកម្មធ្ងន់ធ្ងរក្រោយពីចាក់វ៉ាក់សាំងPCVលើកមុនទេ កុមារគ្រុនក្តៅលើសពី ៣៩°C មិនត្រូវផ្តល់នៅពេលនេះ ប៉ុន្តែត្រូវផ្តល់ឲ្យនៅពេលកុមារនោះមានសុខភាពធម្មតា ។ |
| លក្ខខណ្ឌក្នុងការរក្សាទុក | • ត្រូវរក្សាវាអោយនៅក្នុងកម្រិត សីតុណ្ហភាព (+២◦Cទៅដល់+៨◦C)។ មុនពេលបើកទិវាទឹកលាយត្រូវទុកេជាមួយវ៉ាក់សាំង។វ៉ាក់សាំងលាយរួចត្រូវតែបោះចោលរយៈពេល៦ម៉ោងបន្ទាប់ពីលាយរួច ឬ នៅពេលបញ្ចប់ទិវាផ្តល់ថ្នាំបង្ការ ។<br>• មិនត្រូវទុកឲ្យប៉ះនឹងពន្លឺថ្ងៃ ។ |
| ផលរំខាន | • ហើម ឈឺចាប់នៅកន្លែងចាក់ក្តៅខ្លួនបន្តិចបន្តួច |

# ១០. សន្ទេបរបៀបផ្តល់វ៉ាក់សាំង ការរក្សាទុក និង ប្រតិទិននៃការផ្តល់វ៉ាក់សាំងសម្រាប់កុមារ និង ស្ត្រី

**កត្តាដែលនាំឲ្យវ៉ាក់សាំងខូច**

វ៉ាក់សាំងភាគច្រើនឆាប់ខូចដោយសារ ៖

- កំដៅ
- ពន្លឺថ្ងៃ
- សារធាតុគីមីមួយចំនួន (ដូចជាសាប៊ូ អាល់កុល)
- វ៉ាក់សាំងមួយចំនួន(HepB,IPV,PCV,TT, DPT-HepB-Hib)ខូចដោយការកក

**ចំណុចសំខាន់ៗក្នុងការថែរក្សាវ៉ាក់សាំង**

ក). សីតុណ្ហភាព ៖

ក.១)ថ្នាក់ជាតិថែរក្សាយ៉ាងយូរក្នុងរយៈពេល៩ខែ ។

ថ្នាក់ខេត្តថែរក្សាយ៉ាងយូរក្នុងរយៈពេល៤ខែ

ស្រុកប្រតិបត្តិថែរក្សាយ៉ាងយូរក្នុងរយៈពេល ១ខែ កន្លះ ។

- វ៉ាក់សាំងប៉ូលីយូ (OPV) ថែរក្សាក្នុងសីតុណ្ហភាពពី -១៥ ដល់ -២៥អង្សាសេ
- វ៉ាក់សាំង BCG,HepB , DPT-HepB-Hib,PCV,IPV ,MR, TT, JEថែរក្សានៅក្នុង សីតុណ្ហភាពពី +២ ទៅ +៨ អង្សាសេ

ក.២)ថ្នាក់មណ្ឌលសុខភាពថែរក្សាយ៉ាងយូរយៈពេល១ខែ កន្លះនៅក្នុងទូទឹកកក

- គ្រប់មុខវ៉ាក់សាំងទាំងអស់ត្រូវថែរក្សាក្នុងសីតុណ្ហភាពពី +២ ទៅ +៨ អង្សាសេ

ខ). តម្រូវការសំរាប់ថែរក្សាវ៉ាក់សាំង ៖

ដោយសារវ៉ាក់សាំងគ្រប់មុខត្រូវការចាំបាច់នូវការថែរក្សាក្នុងសីតុណ្ហភាពមួយ ត្រឹមត្រូវ និងមានរយៈពេល កំណត់ ។ ដូច្នេះទាមទាឲ្យមានចាំបាចមួយចំនួនដើម្បីឲ្យមានប្រសិទ្ធភាព ដូចជា ៖

- បន្ទប់កក បន្ទប់ត្រជាក់ (នៅថ្នាក់ជាតិ)
- ទូទឹកកក
- ក្លាស្សៀ

- ធុងវ៉ាក់សាំង(ប្រអប់អ៊ីសូទែម)
- ប្រអប់កក
- ឧបករណ៍សម្រាប់តាមដានស៊ីតុណ្ហភាព

**ការរៀបចំវ៉ាក់សាំងក្នុងទូទឹកកក : ក្នុងទូទឹកកកត្រូវមានកញ្ច្រែង៤**

ទូទឹកកកអគ្គីសនី: កញ្ច្រែង២ខាងលើដាក់វ៉ាក់សាំងHepB,DPT-HepB-Hib,PCV,IPV, TT, HPV(វ៉ាក់សាំងខូចក្រោយកក)

កញ្ច្រែង២ខាងក្រោមដាក់វ៉ាក់សាំង OPV , BCG , JE ,MR (វ៉ាក់សាំងកកមិនខូច)

ទូទឹកកកRCW50EG: កញ្ច្រែង២ផ្នែកខាងស្តាំវ៉ាក់សាំងHepB,DPT-HepB-Hib,PCV,IPV, TT, HPV(វ៉ាក់សាំងខូចក្រោយកក)

កញ្ច្រែង២ផ្នែកខាងឆ្វេង ដាក់វ៉ាក់សាំង OPV , BCG , JE ,MR (វ៉ាក់សាំងកកមិនខូច)

**ល្វែងកក ដាក់ប្រអប់កក**

**មិនត្រូវដាក់វត្ថុអ្វីក្រៅពីវ៉ាក់សាំង ក្នុងទូទឹកកកថែរក្សាវ៉ាក់សាំង**

## តារាងទី៨៖តារាងនៃវ៉ាក់សាំងដែលរក្សាទុកនៅមណ្ឌលសុខភាព(សម្រាប់គ្រប់វ៉ាក់សាំងទាំងអស់)

| វ៉ាក់សាំង | រក្សាក្នុងសីតុណ្ហភាព | ខូចក្រោយពេលកក | ខូចដោយសារកំដៅ | ខូចដោយពន្លឺ (UV) | បើកប្រើហើយដល់ចប់ទិវា |
|---|---|---|---|---|---|
| BCG | +២°C ទៅ+៨°C | ទេ | ឆាប់ខូច | ឆាប់ខូច | ចោលក្រោយពេល លាយ៦ម៉ោង |
| OPV | +២°C ទៅ+៨°C | ទេ | ឆាប់ខូច | ក្រខូច | ទុកប្រើបន្ត |
| IPV | +២°C ទៅ+៨°C | ឆាប់ខូច | ឆាប់ខូច | ក្រខូច | ទុកប្រើបន្ត |
| DTP-HepB-Hib | +២°C ទៅ+៨°C | ឆាប់ខូច | ក្រខូច | ក្រខូច | |
| PCV | +២°C ទៅ+៨°C | ឆាប់ខូច | ក្រខូច | ក្រខូច | |
| HepB | +២°C ទៅ+៨°C | ឆាប់ខូច | ក្រខូច | ក្រខូច | |
| MR | +២°C ទៅ+៨°C | ទេ | ឆាប់ខូច | ឆាប់ខូច | ចោលក្រោយពេលលាយ៦ម៉ោង |
| JE | +២°C ទៅ+៨°C | ទេ | ឆាប់ខូច | ឆាប់ខូច | ចោលក្រោយពេលលាយ៦ម៉ោង |
| TT | +២°C ទៅ+៨°C | ឆាប់ខូច | ក្រខូច | ក្រខូច | ទុកប្រើបន្ត |
| HPV | +២°C ទៅ+៨°C | ឆាប់ខូច | ក្រខូច | ក្រខូច | ចោលក្រោយពេលបើកប្រើ៦ម៉ោង |

## ចំណាំ

- ទុកប្រើបន្ត: អនុវត្តចំពោះវ៉ាក់សាំងដែលមិនប្រើទឹកលាយ និង ត្រូវគោរពតាមលក្ខខណ្ឌប្រាំយ៉ាង ដែលមានចែកក្នុងគោលការណែនាំស្តីអំពីវ៉ាក់សាំងដែលបើកប្រើហើយទុកប្រើសម្រាប់ទិវាបន្តបន្ទាប់
- មុនពេលដាក់ប្រអប់កកចូលក្នុងធុងវ៉ាក់សាំង ត្រូវទុកប្រអប់កកនៅខាងក្រៅរហូតដល់មានទឹករលាយតិចៗនៅក្នុងប្រអប់កកជាមុនសិន
- នៅពេលដឹកជញ្ជូន ដើម្បីការពារ វ៉ាក់សាំងដែលខូចដោយសារការកកត្រូវខ្ចប់ដោយ ក្រដាសធម្មតា និង ដាក់ចូល ទៅក្នុងស្បោងប្លាស្ទិកចងឱ្យបានជិត ដើម្បីកុំឱ្យប៉ះផ្ទាល់ជាមួយទឹកកក
- ប្រសិនបើមានប្រអប់កកត្រូវប្រើប្រអប់កកជំនួសទឹកកកវិញ

## តារាងទី៦៖ របៀបផ្តល់ថ្នាំបង្ការសម្រាប់កុមារនិងផលរំខានបន្ទាប់បន្សំ

| អាយុ | មុខវ៉ាក់សាំង | កំរិតផ្តល់ | របៀបផ្តល់ | កន្លែងផ្តល់ | ផលរំខាន | បម្រាម |
|---|---|---|---|---|---|---|
| ក្រោយពេល កើត | BCG <១២ខែ | 0.0៥ម.ល | ចាក់សើស្បែក | ស្មាឆ្វេង | ហើម ឈឺចាប់នៅកន្លែងចាក់ | គ្មាន |
| | HepB <២៤ម៉ោង | 0,៥ម.ល | ចាក់សាច់ដុំ | ភ្លៅស្តាំ | គ្រុនក្តៅ ឈឺកន្លែងចាក់ | គ្រុនក្តៅខ្លាំងលើសពី៣៩$^{0}$C |
| ៦សប្តាហ៍ | OPV 1 | ២ដំណក់ | បន្តក់ | ផឹកតាមមាត់ | គ្មាន | គ្មាន |
| | DPT-HepB-Hib1 | 0,៥ម.ល | ចាក់សាច់ដុំ | ភ្លៅស្តាំ | គ្រុនក្តៅ ឈឺ កន្លែងចាក់ | គ្រុនក្តៅខ្លាំងលើសពី៣៩$^{0}$C |
| | PCV1 | 0,៥ម.ល | ចាក់សាច់ដុំ | ភ្លៅឆ្វេង | ហើមឈឺចាប់នៅកន្លែងចាក់ក្តៅខ្លួនបន្តិចបន្តួច | គ្រុនក្តៅខ្លាំងលើសពី៣៩$^{0}$C |
| ១០សប្តាហ៍ | OPV 2 | ២ដំណក់ | បន្តក់ | ផឹកតាមមាត់ | គ្មាន | គ្មាន |
| | DPT-HepB-Hib2 | 0,៥ម.ល | ចាក់សាច់ដុំ | ភ្លៅស្តាំ | គ្រុនក្តៅ ឈឺកន្លែងចាក់ | គ្រុនក្តៅខ្លាំងលើសពី៣៩$^{0}$C |
| | PCV2 | 0,៥ មល. | ចាក់សាច់ដុំ | ភ្លៅឆ្វេង | ហើម ឈឺចាប់នៅកន្លែងចាក់និងក្តៅខ្លួនបន្តិចបន្តួច | ធ្លាប់មានប្រតិកម្មធ្ងន់ធ្ងរក្រោយចាក់PCVលើកមុន គ្រុនក្តៅខ្លាំងលើសពី៣៩$^{0}$C |
| ១៤សប្តាហ៍ | OPV 3 | ២ដំណក់ | បន្តក់ | ផឹកតាមមាត់ | គ្មាន | គ្មាន |
| | DPT-HepB-Hib3 | 0,៥ម.ល | ចាក់សាច់ដុំ | ភ្លៅស្តាំ | គ្រុនក្តៅ ឈឺន្លែងចាក់ | គ្រុនក្តៅខ្លាំងលើសពី៣៩$^{0}$C |
| | PCV3 | 0,៥ម.ល | ចាក់សាច់ដុំ | ភ្លៅឆ្វេង | ហើម ឈឺចាប់នៅកន្លែងចាក់និងក្តៅខ្លួនបន្តិចបន្តួច | ធ្លាប់មានប្រតិកម្មធ្ងន់ធ្ងរក្រោយចាក់PCVលើកមុន គ្រុនក្តៅខ្លាំងលើសពី៣៩$^{0}$C |
| | IPV | 0,៥ម.ល | ចាក់សាច់ដុំ | ភ្លៅឆ្វេងក្រោមវ៉ាក់សាំង PCVពីរធ្នាប់ដៃ | ហើម ឈឺចាប់នៅកន្លែងចាក់ | កុមារធ្លាប់ដឹងឬមានឯកសារបញ្ជាក់ថាមានប្រតិកម្មជាមួយ Streptomycin, Neomycin, Polymyxin B |

| | | | | | | |
|---|---|---|---|---|---|---|
| ៩ខែ | MR1 | 0,៥ម.ល | ចាក់ក្រោមស្បែក | ស្មាឆ្វេង | ហើមឈឺចាប់ក្រហាយឡើងក្រហមនៅកន្លែងចាក់ក្តៅខ្លួនបន្តិចបន្តួច | កុមារធ្លាប់ដឹងឬមានឯកសារបញ្ជាក់ថាមានប្រតិកម្មមួយ Neomycin, Gelatineនិងវ៉ាក់សាំងដ៏ទៃទៀត និងមនុស្សដែលមានភាពស៊ាំចុះខ្សោយខ្លាំង |
| | JE | 0,៥ម.ល | ចាក់ក្រោមស្បែក | ស្មាស្តាំ | ឈឺចាប់នៅកន្លែងចាក់ | គ្មាន |
| ១៨ខែ | MR2 | 0,៥ម.ល | ចាក់ក្រោមស្បែក | ស្មាឆ្វេង | ហើមឈឺចាប់ក្រហាយ ឡើងក្រហមនៅកន្លែងចាក់ក្តៅខ្លួនបន្តិចបន្តួច | កុមារធ្លាប់ដឹងឬមានឯកសារបញ្ជាក់ថាមានប្រតិកម្មមួយ Neomycin, Gelatineនិងវ៉ាក់សាំងដទៃទៀត និងមនុស្សដែលមានភាពស៊ាំចុះខ្សោយខ្លាំង |

## តារាងទី៧៖ ប្រតិទិននៃការផ្ដល់ថ្នាំបង្ការសម្រាប់កុមារ

| ប្រភេទវ៉ាក់សាំង | អាយុ | | | | | |
|---|---|---|---|---|---|---|
| | ក្រោយពេលកើត | ៦សប្ដាហ៍ | ១០សប្ដាហ៍ | ១៤សប្ដាហ៍ | ៩ខែ | ១៨ខែ |
| BCG | √ | | | | | |
| Hepatitis B | √ | | | | | |
| OPV | | √ | √ | √ | | |
| DTP-HepB-Hib | | √ | √ | √ | | |
| PCV13 | | √ | √ | √ | | |
| IPV | | | | √ | | |
| MR | | | | | √ | √ |
| JE | | | | | √ | |

## តារាងទី៨៖ ប្រតិទិននៃការចាក់ថ្នាំតេតាណូសចំពោះស្ត្រីមានផ្ទៃពោះនិងស្ត្រីក្នុងវ័យអាចមានកូន(១៥ដល់៤៩ឆ្នាំ)

| ចាក់ថ្នាំបង្ការតេតាណូស | រយៈពេលផ្ដល់ស្ត្រីគ្មានផ្ទៃពោះ | រយៈពេលផ្ដល់ស្ត្រីមានផ្ទៃពោះ | កំរិត | របៀបផ្ដល់ | កន្លែងផ្ដល់ | បំរាម |
|---|---|---|---|---|---|---|
| លើកទី ១ | ចាប់ពីអាយុ ១៥ ឆ្នាំឡើងទៅ | ចាប់ពីពេលមានផ្ទៃពោះ | 0,៥ មល | ចាក់ សាច់ដុំ | ស្មាស្តាំ | ធ្លាប់មាន ប្រតិកម្មធ្ងន់ធ្ងរ ក្រោយចាក់លើកមុន |
| លើកទី ២ | មួយខែយ៉ាងតិចក្រោយលើកទី ១ | មួយខែយ៉ាងតិចក្រោយលើកទី ១ | 0,៥ មល | ចាក់ សាច់ដុំ | ស្មាស្តាំ | |
| លើកទី ៣ | ៦ខែយ៉ាងតិច ក្រោយលើកទី ២ | ពេលមានផ្ទៃពោះលើកក្រោយ | 0,៥ មល | ចាក់ សាច់ដុំ | ស្មាស្តាំ | |
| លើកទី ៤ | មួយឆ្នាំយ៉ាងតិចក្រោយលើកទី ៣ | ពេលមានផ្ទៃពោះលើកក្រោយ | 0,៥ មល | ចាក់ សាច់ដុំ | ស្មាស្តាំ | |
| លើកទី ៥ | មួយឆ្នាំយ៉ាងតិចក្រោយលើកទី ៤ | ពេលមានផ្ទៃពោះលើកក្រោយ | 0,៥ មល | ចាក់ សាច់ដុំ | ស្មាស្តាំ | |

# ១១. ការបំពេញតារាងរបាយការណ៍ប្រព័ន្ធត្រជាក់

## ក- គោលបំណង ៖

- ដើម្បីធ្វើការកត់ត្រាឱ្យបានត្រឹមត្រូវនិងច្បាស់លាស់នូវការចេញ ចូលវ៉ាក់សាំងឬ ដែលមានជាក់ស្តែងនៅតាមខេត្ត ស្រុកប្រតិបត្តិ ឬមណ្ឌលសុខភាពនីមួយៗ។
- ផ្តល់ភាពងាយស្រួលដល់អ្នកទទួលខុសត្រូវវ៉ាក់សាំង/ក្នុងការធ្វើផែនការស្នើសុំ វ៉ាក់សាំង ឬឱ្យបានត្រឹមត្រូវ សម្រាប់ពេលខាងមុខ ។
- ដើម្បីទុកជាឯកសារអនុវត្តបន្តសំរាប់អ្នកដ៏ទៃដែលទទួលខុសត្រូវ វ៉ាក់សាំង/សម្ភារ

## ខ- ការបំពេញសលាកប័ត្រឃ្លាំង ( ឧបសម្ព័ន្ធទី ១-២ )

- អ្នកទទួលខុសត្រូវផ្នែក វ៉ាក់សាំង និង ប្រព័ន្ធត្រជាក់ត្រូវយល់អំពីតារាងសលាកប័ត្រឃ្លាំងនិង ត្រូវបំពេញតារាង នេះ ឱ្យបានត្រឹមត្រូវនៅ ពេលទទួល បញ្ចេញឬធ្វើសារពើភ័ណ្ឌ របស់វ៉ាក់សាំងនិងផ្សេងៗ ។
- នៅលើសាលាកប័ត្រឃ្លាំងមានពីរផ្នែកគឺផ្នែកខាងលើតារាងនិងផ្នែកខាងក្នុងតារាង ។ អ្នកត្រូវយល់ ន័យរបស់ ចំណងជើងនៅផ្នែកនីមួយៗនិងត្រូវបំពេញដូចការណែនាំខាងក្រោមៈ

### ខ-១-នៅខាងលើតារាង

- សលាកប័ត្រឃ្លាំងលេខ......មានន័យថាជាលេខកូដសម្ភារ/វ៉ាក់សាំង សម្រាប់សំគាល់ សម្ភារ/ វ៉ាក់សាំង នៅក្នុង កន្លែងរបស់អ្នក
- ខេត្ត..................បំពេញឈ្មោះខេត្តរបស់អ្នក ឧទាហរណ៍ : ខេត្ត កំពង់ឆ្នាំង
- ស្រុក.................បំពេញឈ្មោះស្រុកប្រតិបត្តិ ។ បើជាមណ្ឌលសុខភាពគឺត្រូវបំពេញឈ្មោះ របស់មណ្ឌលសុខ ភាពអ្នក ។ ឧទាហរណ៍ : មណ្ឌលសុខភាព កំពង់ឆ្នាំង
- ឈ្មោះវ៉ាក់សាំង/សម្ភារ......បើជាវ៉ាក់សាំងអ្នកត្រូវបំពេញឈ្មោះ ″វ៉ាក់សាំងឈ្មោះអ្វី″ ឧទាហរណ៍ៈ វ៉ាក់សាំង DPT-HepB-Hib បើជាសម្ភារបំពេញ "សម្ភារឈ្មោះអ្វី″ ឧទាហរណ៍ៈ សឺរាំង AD 0,5 មល
- សន្លឹកលេខ...........មានន័យថាលេខរៀងរបស់សលាកប័ត្រឃ្លាំងនិងសម្រាប់សម្គាល់ វ៉ាក់សាំងមួយមុខៗ
- ចំនួនដូស...............ឯកតាគិតជា(ដូស) យើងត្រូវសរសេរថា ដូស នៅពីមុខ (ឯកតាគិត ) ឧទាហរណ៍ៈ វ៉ាក់ សាំង DPT-HepB-Hib ១ដបមាន ១ដូស យើងត្រូវសរសេរ ដូស
- ចំនួនស្តុកបំរុង..........៖មានន័យថាជាចំនួនវ៉ាក់សាំង ឬសម្ភារដែលត្រូវរក្សាទុកសម្រាប់ប្រើប្រាស់ ដើម្បីការពារកុំ ឱ្យដាច់ស្តុកនៅពេលដែលការប្រើប្រាស់លើសពីចំនួនប៉ាន់ស្មាន។ ឧទាហរណ៍ៈ មណ្ឌលសុខភាពកំពង់ឆ្នាំង

ដែលមានទូរទឹកកក សម្រាប់ថែរក្សាវ៉ាក់សាំង ហើយប្រើប្រាស់វ៉ាក់សាំង DPT-HepB-Hib ជាមធ្យមក្នុងមួយខែ អស់ ៨០ដូស ។ ចំនួនស្តុកបំរុងរបស់វ៉ាក់សាំង DPT-HepB-Hib គឺស្មើពាក់កណ្តាលនៃចំនួនវ៉ាក់សាំងប្រើប្រាស់ ជាមធ្យមក្នុងមួយខែ ។ ដូចនេះចំនួនស្តុកបំរុងរបស់វ៉ាក់សាំង DPT-HepB-Hib គឺស្មើ៨០ដូស ចែកជាពីរ ស្តុកបំរុង គឺស្មើ៤០ដូស។

- ចំនួនស្តុកអតិបរមា......... ៖មានន័យថាជាចំនួនវ៉ាក់សាំងឬដែលត្រូវមានច្រើនបំផុត នៅក្នុង ស្តុក។ ឧទាហរណ៍ ៖ នៅមណ្ឌលសុខភាពកំពង់ឆ្នាំង ដែលមានទូរទឹកកក សម្រាប់ ថែរក្សាវ៉ាក់សាំង DPT-HepB-Hibចំនួនស្តុកសរុបរបស់ វ៉ាក់សាំង DPT-HepB-Hib គឺស្មើ ចំនួនវ៉ាក់សាំងប្រើជាមធ្យមក្នុងមួយខែ គឺ៨០ដូស បូកនិងចំនួនស្តុកបំរុង គឺ ៤០ដូស។ ដូចនេះស្តុក អតិបរមាររបស់វ៉ាក់សាំង DPT-HepB-Hib គឺ ១២០ ដូស។

## ខ-២-នៅក្នុងតារាង

- ជួរឈរខាងឆ្វេងដៃបង្អស់របស់តារាង អ្នកត្រូវបំពេញលេខរៀងតាមលំដាប់លំដោយចាប់ពីលេខ១លេខ២..
- ជួរឈរបន្ទាប់ជាថ្ងៃខែឆ្នាំ បញ្ចូល បញ្ចេញ វ៉ាក់សាំង ឬសម្ភារ
- លេខវិក័យប្រ័តៈ ចុះលេខវិក័យប័ត្រ ឬបណ្ណ័បញ្ចេញវ៉ាក់សាំងឬ ដែលបានទទួល ឬបញ្ចេញ
- បរិយាយៈ ចុះឈ្មោះប្រភពដែលបានផ្តល់ឬដែលបានចែកចាយនិងវ៉ាក់សាំងខូចគុណភាព និង ចំនួនវ៉ាក់សាំងដែលនៅសល់លើសពីស្តុកពិតប្រាកដ ក្រោយពេលអង្កេតឃ្លាំង។ ឧទាហរណ៍ៈ មណ្ឌលសុខភាពកំពង់ឆ្នាំងបានអង្កេតឃ្លាំងឃើញមានវ៉ាក់សាំងសល់ ៣០ ដូស ។ ត្រូវបរិយាយថា( អង្កេតឃ្លាំង ) ។ មណ្ឌលសុខភាពកំពង់ឆ្នាំងបានទទួលវ៉ាក់សាំងពីស្រុកប្រតិបត្តិកំពង់ឆ្នាំង ។ ត្រូវបរិយាយថា ស្រុកប្រតិបត្តិ "កំពង់ឆ្នាំង" ។ មណ្ឌលសុខភាព "កំពង់ឆ្នាំង" ដដែលបាន ចែកចាយវ៉ាក់សាំងទៅ ចាក់នៅភូមិ "ឡទឹកត្រី" ត្រូវបរិយាយថា ភូមិ "ឡទឹកត្រី " ។
- លេខឡូត៍ៈចំពោះវ៉ាក់សាំង ត្រូវបំពេញលេខ ឡូត៍ដែលមានសរសេរលើដបវ៉ាក់សាំង ដែលបានបញ្ចូលឬបញ្ចេញ
- ថ្ងៃខែឆ្នាំផុតកំណត់ៈ ជាថ្ងៃខែឆ្នាំផុតកំណត់ដែលមានសរសេរនៅលើដប វ៉ាក់សាំងឬសម្ភារ ដែលបានបញ្ចូលឬបញ្ចេញ ។
- ស្ថានភាព VVM ជាសញ្ញាសំគាល់គុណភាពវ៉ាក់សាំង
- បញ្ចូលៈ នេះគឺជាចំនួនវ៉ាក់សាំងដែលបានទទួល, ឧទាហរណ៍ៈ មណ្ឌលសុខភាព "កំពង់ឆ្នាំង" បានទទួលវ៉ាក់សាំងពីស្រុកប្រតិបត្តិ "កំពង់ឆ្នាំង " ចំនួន៩០ដូស។ ប្រសិនបើក្រោយ ពីចាក់នៅភូមិ (ឡទឹកត្រី ) នៅសល់វ៉ាក់សាំង ១០ដូស ត្រូវសរសេរនៅជួរ (បញ្ចូល) ១០ដូស ។ ក្រោយអង្កេតឃ្លាំងមានចំនួនវ៉ាក់សាំងលើស១០ដូសក៏ត្រូវសរសេរនៅជួរ (បញ្ចូល ) ១០ ដូសដែរ ។
- បញ្ចេញៈ នេះគឺជាចំនួនវ៉ាក់សាំងដែលបានបញ្ចេញទៅប្រើប្រាស់ ឬទៅឱ្យកន្លែងណាមួយ។ ឧទាហរណ៍ៈ មណ្ឌលសុខភាព កំពង់ឆ្នាំង បានបញ្ចេញ វ៉ាក់សាំងទៅចាក់នៅភូមិ "ឡទឹកត្រី" ចំនួន២០ដូស។ នៅក្នុងស្តុកមានវ៉ាក់សាំងខូចគុណភាពចំនួន១០ដូស ។

- សល់៖ នេះគឺជាចំនួនវ៉ាក់សាំងឬសំភារៈដែលនៅសល់ក្នុងទូទឹកកកឬក្នុងឃ្លាំង។ ចំនួននេះត្រូវស្មើនិងចំនួនដែលមានពិតប្រាកដនៅក្នុងទូ ឬក្នុងឃ្លាំង។ បើពេលពិនិត្យឃើញវ៉ាក់សាំងខូច ត្រូវចុះនៅក្នុងបរិយាយថា( ខូចគុណភាព ) និងត្រូវកត់នៅជួរឈរ បញ្ចេញ នូវចំនួនវ៉ាក់សាំងដែលបាន ខូចនោះ ។ ឧទាហរណ៍៖ វ៉ាក់សាំងខូច ១០ដូស នោះត្រូវកត់នៅជួរ បញ្ចេញ ១០ដូស និងនៅជួរឈរ សល់ ១០០ ដូស (១១០-១០ =១០០ ដូស) ។

## ចំណាំ ៖

- ពេលមានវ៉ាក់សាំងចូលនិងចេញ បើសិនជាមានលេខឡូត៍ខុសគ្នាត្រូវសរសេរជួរខុសគ្នា ។
- វ៉ាក់សាំងដែលនៅសល់មិនបាច់បញ្ជាក់អំពីលេខឡូត៍ទេ
- ចំពោះទឹកលាយវ៉ាក់សាំងត្រូវកត់ត្រាក្នុងសលាកប័ត្រឃ្លាំងមួយសន្លឹកផ្សេងពីវ៉ាក់សាំង។
- វ៉ាក់សាំងប្រភេទដូចគ្នាដែលមានចំនួនដូសខុសគ្នាក្នុង១ដបត្រូវកត់ត្រាក្នុងមានសលាកប័ត្រឃ្លាំងខុសគ្នា (ឧទា. វ៉ាក់សាំងប៉ូលីយ៉ូក្នុង ១ដបមាន១០ដូស និង វ៉ាក់សាំងប៉ូលីយ៉ូក្នុង ១ដបមាន២០ដូស)។

## គ- ការបំពេញរបាយការណ៍ស្ថានភាពវ៉ាក់សាំងនិងសម្ភារប្រចាំខែ សំរាប់ថ្នាក់មណ្ឌលសុខភាព ( ឧបសម្ព័ន្ធទី ៣ )

បុគ្គលិកទទួលខុសត្រូវវ៉ាក់សាំង សម្ភារនិងប្រព័ន្ធត្រជាក់របស់ ស្រុក ប្រតិបត្តិ និងមណ្ឌលសុខភាព ត្រូវយល់ដឹង អំពីរបាយការណ៍ស្ថានភាពវ៉ាក់សាំង ប្រចាំខែ និង ត្រូវបំពេញរបាយការណ៍ នេះឱ្យបាន ត្រឹមត្រូវនិងច្បាស់លាស់ ។ មណ្ឌលសុខភាពត្រូវផ្ញើររបាយការណ៍នេះឱ្យដល់ផ្នែកផ្គត់ផ្គង់ថ្នាំបង្ការស្រុកប្រតិបត្តិ នៅថ្ងៃទី.........នៃខែនីមួយៗ។

នៅក្នុងរបាយការណ៍នេះមានចែកជាពីរផ្នែកដែរគឺនៅផ្នែកខាងលើតារាងនិងផ្នែកខាងក្នុងតារាង ។ របៀបបំពេញតារាងរបាយការណ៍ស្ថានភាពវ៉ាក់សាំងប្រចាំខែមានដូចខាងក្រោម ៖

### គ-១-នៅផ្នែកលើតារាង

- របាយការណ៍ស្ថានភាពវ៉ាក់សាំងប្រចាំខែ........ឆ្នាំ........ នេះមានន័យថាស្ថានភាពវ៉ាក់សាំងនៅក្នុងខែ ណា ? ឆ្នាំណា ?
- មណ្ឌលសុខភាព៖ ឈ្មោះរបស់មណ្ឌលសុខភាព
- ស្រុកប្រតិបត្តិ៖ ឈ្មោះរបស់ស្រុកប្រតិបត្តិ
- ចំនួនទិវាក្នុងផែនការណ៍៖ ជាចំនួនទិវាដែលមណ្ឌលសុខភាពបានកំណត់និងគ្រោង អនុវត្តន៍នៅក្នុង ខែខាងលើ
- ចំនួនទិវាបានអនុវត្តន៍៖ ជាចំនួនទិវាដែលមណ្ឌលសុខភា ពបានអនុវត្តជាក់ស្តែងនៅក្នុងខែខាងលើ

## គ-២-នៅខាងក្នុងតារាង

- ❖ នៅជួរឈរខាងឆ្វេងដៃបង្អស់មានរាយឈ្មោះគ្រប់មុខវ៉ាក់សាំង ស៊ីរ៉ាំងអេឌី និងប្រអប់សុវត្ថិភាព។ នៅជួរ ឈរបន្ទាប់ មានរាយឈ្មោះឯកតាគិត ជាដូស ចំពោះវ៉ាក់សាំងនិងជាគ្រឿង ចំពោះសម្ភារ។ នៅជួរឈរបន្ទាប់ដែលគ្មានឈ្មោះនោះអ្នកត្រូវបំពេញដូចខាងក្រោម ៖

- ចំនួនដូសវ៉ាក់សាំងបានផ្តល់ដល់កុមារ/ស្ត្រី ៖ មានន័យថាចំនួនដូសវ៉ាក់សាំងបានផ្តល់ដល់ ទារក-កុមារ-ស្ត្រី តាមមុខវ៉ាក់សាំងនិមួយៗ ទាំងក្នុងចំណុច និង ក្រៅចំណុច។
- សល់ពីខែមុន ៖ មានន័យថាចំនួនវ៉ាក់សាំងឬសម្ភារសល់ពីខែមុន(រាប់ចំនួននៅសល់ចុងខែ)។ ឧទាហរណ៍: តារាងនេះបំពេញនៅខែមេសាឆ្នាំនេះ លើឈ្មោះវ៉ាក់សាំងBCG ។ ដូចនេះអ្នកត្រូវរាប់ ចំនួនវ៉ាក់សាំងBCG សល់ពីចុងខែមិនាមានចំនួនប៉ុន្មាន ដូស ។
- ទទួលក្នុងខែ៖ មានន័យថាចំនួនវ៉ាក់សាំងឬសម្ភារ ដែលបានទទួលនៅក្នុងខែ (មណ្ឌលសុខភាពទទួលពីស្រុកប្រតិបត្តិ ឬ មណ្ឌលសុខភាពទទួលពីមណ្ឌលសុខភាពដទៃ) ។ ឧទាហរណ៍: តារាងនេះ បំពេញនៅខែមេសាឆ្នាំនេះ លើឈ្មោះវ៉ាក់សាំងBCG។ ដូចនេះអ្នកត្រូវរាប់ចំនួនវ៉ាក់សាំង BCG ដែលអ្នកបានទទួលនៅក្នុងខែមេសា ។
- ប្រើប្រាស់ក្នុងខែ ៖ មានន័យថាចំនួនវ៉ាក់សាំងដែលបានប្រើអស់នៅក្នុងខែ ។
- ខូចខាតមិនទាន់បើកប្រើៈ មានន័យថាចំនួនដូសវ៉ាក់សាំងដែលដបរបស់វាមិនបានចាក់ឱ្យកុមារ ណាម្នាក់ហើយ ខូចដោយសារអ្វីមួយ ដូចជាហួសកំណត់ពេល ប្រើប្រាស់ VVMឡើងខ្មៅខ្លាំង របកផ្លាកសញ្ញា វ៉ាក់សាំងកក( DPT, DPT-HepB-Hib, HepB, TT) ។ល។
- សល់ចុងខែ ៖ មានន័យថាចំនួនវ៉ាក់សាំងឬសម្ភារដែលនៅសល់ចុងខែ ។ ឧទាហរណ៍: តារាងនេះបំពេញនៅខែ មេសាឆ្នាំនេះ លើឈ្មោះវ៉ាក់សាំង BCG ។ ដូចនេះអ្នកត្រូវរាប់ចំនួន វ៉ាក់សាំង BCG សល់នៅចុង ខែមេសាមានចំនួនប៉ុន្មាន ដូស ។
- អត្រាខាតបង់: មានន័យថាអត្រាចំនួនវ៉ាក់សាំងដែលខាតបង់ពុំបានផ្តល់ដល់កុមារឬស្ត្រី
- តម្រូវការខែបន្ទាប់ ៖ មានន័យថាចំនួនវ៉ាក់សាំងឬសម្ភារដែលត្រូវស្នើសុំសម្រាប់ប្រើប្រាស់នៅក្នុងខែបន្ទាប់
- ថ្ងៃខែឆ្នាំធ្វើរបាយការណ៍ ហត្ថលេខានិងឈ្មោះអ្នកធ្វើរបាយការណ៍ ៖ អ្នកធ្វើរបាយការណ៍ត្រូវចុះ ថ្ងៃខែឆ្នាំ ហត្ថលេខា និងឈ្មោះរបស់ខ្លួននៅពេលបំពេញតារាងនេះ ចប់សព្វគ្រប់ ។
- បានឃើញនិងឯកភាពៈ អ្នកធ្វើរបាយការណ៍ត្រូវបញ្ជូនរបាយការណ៍នេះទៅឱ្យប្រធានមណ្ឌលសុខភាព ពិនិត្យ និង ចុះហត្ថលេខា ។

## ឃ- តារាងតាមដានសីតុណ្ហភាពទូទឹកកក(ឧបសម្ព័ន្ធទី ៥)ដើម្បីធ្វើការ តាមដានសីតុណ្ហភាពរបស់ផ្នែកសំខាន់ៗរបស់ទូទឹកកកអ្នកត្រូវមាន:

- ❖ សីតុណ្ហមាត្របប្រហិចថេប និងតារាងគូសសីតុណ្ហភាពដែលអ្នកត្រូវបិទឱ្យជាប់ទូខាងក្រៅដើម្បីតាមដានសីតុណ្ហភាព ត្រូវដំណើរការដូចខាងក្រោមៈ
  - បើកទែម៉ូស្តារបស់ទូទឹកកកឱ្យត្រឹមត្រូវ ដើម្បីឱ្យបានសីតុណ្ហភាពនៅក្នុង ចន្លោះពី +២ សេ ទៅ +៨ សេ
  - តាមដានសីតុណ្ហភាពជាមុន នៅក្នុងពេលព្រឹក ហើយនឹងពេលល្ងាចមុនពេលដែលអ្នកចាកចេញពីកន្លែង ធ្វើការ។ ប្រសិនបើសីតុណ្ហភាពនៅចន្លោះពី +២ សេ ទៅ +៨ សេ នោះកុំបើកទែម៉ូស្តាទៀត។
  - បន្តការតាមដានសីតុណ្ហភាពជាមុននៅក្នុងពេលព្រឹក ហើយមុនពេលដែលអ្នកចាកចេញពីកន្លែងធ្វើការនៅពេលល្ងាច ដោយរួមទាំងថ្ងៃធ្វើការ ថ្ងៃចុងសប្តាហ៍ និងថ្ងៃសំរាក។
  - កត់ត្រាសីតុណ្ហភាពតាមថ្ងៃ និងពេលនៅលើតារាងតាមដានសីតុណ្ហភាពទូទឹកកក
  - នៅពេលបំពេញតារាងតាមដាននេះពេញត្រូវអោយមានអ្នកត្រួតពិនិត្យចុះហត្ថលេខានៅយ៉ាងយូរអាទិត្យទី២ នៃខែបន្ទាប់ហើយដាក់តារាងតាមដានថ្មីជំនួស

## ខ- ការបំពេញតារាងតាមដានស្ថានភាពការប្រើប្រាស់ និង អត្រាខាតបង់ វ៉ាក់សាំង - សឺរ៉ាំង

- ❖ បំពេញតារាងតាមដានស្ថានភាព ការប្រើប្រាស់ និងអត្រាខាតបង់ វ៉ាក់សាំង-សឺរ៉ាំងរៀងរាល់អាទិត្យទី១នៃខែបន្ទាប់ ដោយស្រង់ចេញពីរបាយការណ៍ស្ថានភាពវ៉ាក់សាំងប្រចាំខែ

# ១២. ការគណនា និង ការស្នើសុំសម្ភារ និងវ៉ាក់សាំង

- ❖ ស្តុកប្រើប្រាស់ប្រចាំខែជាមធ្យម = ចំនួនដូសប្រើប្រាស់ប្រចាំឆ្នាំ / ១២ខែ
- ❖ ស្តុកអប្បបរិមា ឬស្តុកបំរុង = ស្តុកប្រើប្រាស់ប្រចាំខែជាមធ្យម / ២
- ❖ ស្តុកអតិបរមា = ស្តុកប្រើប្រាស់ប្រចាំខែ +ស្តុកអប្បបរិមា (បំរុង)
  = ស្តុកប្រើប្រាស់ប្រចាំខែ X ១,៥
- ❖ គណនាចំនួនវ៉ាក់សាំងត្រូវស្នើសុំ = ស្តុកអតិបរិមា – ស្តុកនៅសល់

## សឺរ៉ាំង និងប្រអប់សុវត្ថិភាព:

- ❖ ស្តុកប្រើប្រាស់ប្រចាំខែជាមធ្យម = ចំនួនប្រើប្រាស់ប្រចាំឆ្នាំ / ១២ខែ
- ❖ ស្តុកអប្បបរិមា ឬស្តុកបំរុង = ស្តុកប្រើប្រាស់ប្រចាំខែជាមធ្យម
- ❖ ស្តុកអតិបរមា = ស្តុកប្រើប្រាស់ប្រចាំខែ + ស្តុកអប្បបរិមា (បំរុង)
- ❖ = ស្តុកប្រើប្រាស់ប្រចាំខែ X ២
- ❖ គណនាចំនួនវ៉ាក់សាំងត្រូវស្នើសុំ = ស្តុកអតិបរិមា – ស្តុកនៅសល់

## រូបមន្តសម្រាប់គណនា អត្រាខាតបង់វ៉ាក់សាំង( គិតជាភាគរយ )

វ៉ាក់សាំង...... = (ចំនួនដូសវ៉ាក់សាំងប្រើប្រាស់និងខូចខាត - ចំនួនដូសផ្តល់ដល់កុមារឬស្ត្រី) / (ចំនួនដូសវ៉ាក់សាំងប្រើប្រាស់និងខូចខាត) X 100

## អត្រាខាតបង់ AD ( គិតជាភាគរយ )

ស៊ីរ៉ាំង AD 0.05ml (BCG) = (( ចំនួន AD 0.05ml (BCG) ប្រើប្រាស់និងខូចខាត) - ចំនួនកុមារទទួល (BCG)) / (( ចំនួន AD 0.05ml (BCG) ប្រើប្រាស់និងខូចខាត) X 100

ស៊ីរ៉ាំង AD 0.5ml = ((ចំនួន AD 0.5ml ប្រើប្រាស់និងខូចខាត) - ចំនួនចាក់ (DTC-HepB-Hib +…….)) / (ចំនួន AD 0.5ml ប្រើប្រាស់និងខូចខាត) X 100

# ១៣. ការធ្វើអន្ដេតឃ្លាំងវ៉ាក់សាំងនិងសម្ភារ

## ការធ្វើអន្ដេតឃ្លាំងវ៉ាក់សាំងនិងសម្ភារ

- ❖ រាប់ចំនួនវ៉ាក់សាំងឬសម្ភារជាក់ស្តែងក្នុងទូទឹកកកឬឃ្លាំងដោយប្រៀបធៀបជាមួយសលាកប័ត្រឃ្លាំងរាល់ចុងខែមុនធ្វើរបាយការណ៍ប្រចាំខែ
- ❖ ការធ្វើរបាយការណ៍ពេលចំនួនវ៉ាក់សាំងឬសម្ភារក្នុងបញ្ជីខុសពីចំនួនជាក់ស្តែង
- ❖ ការពិនិត្យគុណភាពវ៉ាក់សាំង(VVM , Expiry Date)
- ❖ ការរៀបចំទុកដាក់វ៉ាក់សាំងក្នុងទូទឹកកក,ក្លាស៊ែ្យ,ការលាយវ៉ាក់សាំង,ការរៀបចំទីតាំងនៅពេលវេលាបើកទិវានៅតាមភូមិ

## ការថែទាំទូទឹកកកនិងការជួសជុលតូចតាច

## ការរំលាយទឹកកក

- ❖ ដោយសារភាពសើមក្នុងសីតុណ្ហភាពខាងក្រៅព្រុយទឹកកកនឹងចាប់កកបន្តិចម្តងៗ លើកញ្ច្រែងកក។ ជាលទ្ធផលតាមការណែនាំស្រទាប់ព្រុយទឹកកកនេះចាប់ផ្តើមមានពីខាងឆ្វេងនៃកញ្ច្រែង ប្រសិនបើស្រទាប់ព្រុយទឹកកកមានកំរាស់លើសពី ១ ស.ម សកម្មភាពត្រជាក់របស់ទូទឹកកកនឹងថយចុះ ។ ក្នុងករណីនេះយើងគប្បីរំលាយវាចេញ ។
- ❖ យកវ៉ាក់សាំង, ប្រអប់កក និង ជញ្ជាំងខ័ណ្ឌចេញដោយថែរក្សារបស់ទាំងនោះ ក្នុងកន្លែងត្រជាក់ របស់ទូទឹកកកមួយផ្សេងទៀត(ក្លាស៊ែ្យ)
- ❖ បិទដំណើរការទូទឹកកក ៖
    - ក្នុងការប្រើថាមពលអគ្គិសនី   ដកខ្សែភ្លើងចេញ
    - ក្នុងការប្រើថាមពលហ្គាស     មួលបិទធុងហ្គាស
- ❖ បើកគំរបទូទឹកកកចោលរហូតដល់ទឹកកករលាយអស់
- ❖ មិនត្រូវប៉ុនប៉ងយកកំរាស់ព្រុយទឹកកកចេញដោយប្រើកាំបិត ឬប្រដាប់ប្រដារ ផ្សេងៗទៀតឡើង
- ❖ ក្រោយពេលរំលាយព្រុយទឹកកកហើយ ផ្នែកខាងក្នុងនៃទូទឹកកកត្រូវជូតសំអាត ឲ្យបានត្រឹមត្រូវ និង ស្ងួតល្អ
- ❖ មិនត្រូវប្រើឧបករណ៍កំដៅណាមួយ ដើម្បីធ្វើឲ្យផ្នែកខាងក្នុងស្ងួតឡើយ
- ❖ ប្រសិនបើយើងទុកទូទឹកកកមិនប្រើក្នុងដំណាក់កាលយូរ ផ្នែកខាងក្នុងនៃទូត្រូវជូតឲ្យបានស្អាត ហើយត្រូវបង្ហើបគំរបឲ្យមានចន្លោះបន្តិចដើម្បីជៀសវាងខ្លិនមិនល្អ

## ការថែទាំប្រចាំថ្ងៃ

- ត្រួតពិនិត្យសីតុណ្ហភាពដោយប្រើសីតុណ្ហមាត្រ
- ត្រួតពិនិត្យពណ៌អណ្ដាតភ្លើងហ្គាស
- ត្រួតពិនិត្យហ្គាសដែលដែលនៅសល់ក្នុងធុងហ្គាស
- ត្រួតពិនិត្យវ៉ាក់សាំងឲ្យបានសមស្របត្រឹមត្រូវតាមលំដាប់លំដោយ ដោយត្រូវធានាអោយបានថា ខ្យល់អាចឆ្លងកាត់ចុះឡើងយ៉ាងងាយតាមចន្លោះកញ្ចប់និមួយៗ
- ត្រូវយកទឹកចេញពីផ្នែកខាងក្នុងរបស់ទូទឹកកកឲ្យបានឆាប់

## ការថែទាំប្រចាំសប្ដាហ៍

- ត្រួតពិនិត្យកំរាសទឹកកកដែលកកជាប់នឹងកញ្ចែងកក ។ បើសិនជាវាមានកំរាស់លើសពី ១ ស.ម ត្រូវរំលាយកំរាស់ទឹកកកចេញ
- ត្រួតពិនិត្យកៅស៊ូទ្រនាប់គំរបទូទឹកកក និង ពិនិត្យគំរបនៅពេលដាក់គន្លឹះជាប់តឹងល្អ
- ត្រួតពិនិត្យអណ្ដាតភ្លើងឲ្យបាននៅខៀវដដែល

## ការថែទាំប្រចាំខែ

- ពិនិត្យលើការរំធូលីលើភ្នែកធ្វើឲ្យត្រជាក់ (Coolingunit) បើមានត្រូវ បោសចេញដោយ ប្រើច្រាសទន់ៗ
- ត្រួតពិនិត្យបណ្ដាញភ្ជាប់ហ្គាសឲ្យបានជិតល្អ មិនលេចធ្លាយហ្គាសចេញក្រៅ

## ការជួសជុល

## ទូទឹកកកមិនត្រជាក់សោះ ជាទូទៅ

- ទូទឹកកកមិនបានដាក់ឲ្យត្រង់ជំហរល្អ
- ចរន្តខ្យល់តិចតួចសំរាប់ទូ
- ទូទឹកកកំពុងដំណើរដោយប្រើប្រភពថាមពល ២ ក្នុងពេលតែមួយ
- ផ្នែកធ្វើឲ្យត្រជាក់មានបញ្ហា

## ទូប្រើដោយថាមពលអគ្គិសនី

- ផ្នែកកំដៅមានបញ្ហា
- ដំណើរការដោយខុសតង់ស្យុងអគ្គិសនី
- ដោតចរន្តពុំបានជិតល្អ
- ផ្នែកកំដៅមិនបាននៅចំកន្លែងក្នុងបំពង់កំដៅ
- ដំណើរការទែម៉ូស្តាមិនបានត្រឹមត្រូវ
- ទែម៉ូស្តាអគ្គិសនីមានបញ្ហា

## ទូច្រើដោយថាមពលហ្គាស

- អស់ហ្គាសពីធុង
- ក្បាលបញ្ចេញហ្គាសមានក្រមរ ឬខូច
- ក្បាលប្រឆេះមានក្រមរ
- ទែម៉ូស្តាហ្គាសមានបញ្ហា
- អណ្តាតភ្លើងពុំបានល្អ (ពណ៌លឿង)

## ទូទឹកកកត្រជាក់តិចៗ ជាទូទៅ

- ទូទឹកកកមិនបានដាក់ឲ្យត្រង់ស្មើ
- ចរន្តខ្យល់តិចតួចសម្រាប់ទូ
- ទូទឹកកកកំពុងដំណើរការដោយប្រើប្រភពថាមពល ២ ក្នុងពេលតែមួយ
- សីតុណ្ហភាពជុំវិញក្តៅខ្លាំង
- គ្របគំរបពុំបានជិតត្រឹមត្រូវ
- ចរន្តខ្យល់តិចតួចក្នុងទូទឹកកក
- ដាក់វ៉ាក់សាំងចូលមុនទូទឹកកកត្រជាក់បានត្រឹមត្រូវ
- កំរាស់ព្រុយទឹកកកនៅកញ្ចែងកក
- មិនបានដាក់ ឬដាក់ជញ្ជាំងខ័ណ្ឌខុសកន្លែង

## ទូច្រើដោយថាមពលអគ្គិសនី

- ដំណើរការដោយខុសតង់ស្យុងអគ្គិសនី
- ផ្នែកកំដៅមិនបាននៅចំកន្លែងក្នុងបំពង់កំដៅ
- ដំណើរការទែម៉ូស្តាមិនបានត្រឹមត្រូវ
- ទែម៉ូស្តាអគ្គិសនីមានបញ្ហា (បំពង់មិនបាននៅជាប់ល្អជាមួយកញ្ចែងកក)
- ចរន្តអគ្គិសនីពុំស្ថេរ

## ទូច្រើដោយថាមពលហ្គាស

- ក្បាលបញ្ចេញហ្គាសមានក្រមរ ឬខូច
- ក្បាលប្រឆេះមានក្រមរ
- ទែម៉ូស្តាហ្គាសមានបញ្ហា (បំពង់តូចមិនបានទៅជាប់ល្អជាមួយកញ្ចែងកក)
- អណ្តាតភ្លើងពុំបានល្អ (ពណ៌លឿង)

**ទូទឹកកកត្រជាក់ខ្លាំងពេក** ជាទូទៅ

- ❖ ទឹកជញ្ជាំងខំណ្ឌកក
- ❖ គ្មានទឹកនៅជញ្ជាំងខំណ្ឌ

**ទូប្រើដោយថាមពលអគ្គិសនី**

- ❖ ដំណើរការទែម៉ូស្តាពុំត្រឹមត្រូវ
- ❖ ទែម៉ូស្តាអគ្គិសនីមានញ្ហា (បំពង់មិនបាននៅជាប់ល្អជាមួយកញ្ចែងកក)

**ទូប្រើដោយថាមពលហ្គាស**

- ❖ ដំណើរការទែម៉ូស្តាមិនបានត្រឹមត្រូវ
- ❖ តែម៉ូស្តាហ្គាសមានបញ្ហា (បំពង់តូចមិនបានទៅជាប់ល្អជាមួយកញ្ចែងកក)

**ក្បាលប្រឆេះពុំមានភ្លើងឆេះ** ប្រើដោយថាមពលហ្គាស

- ❖ ម៉ាញ៉េតូសំរាប់បញ្ឆោះមានបញ្ហា
- ❖ តំណរម៉ាញ៉េតូ ឬខ្សែម៉ាញ៉េតូរលុង ឬមានបញ្ហា
- ❖ ដាក់ទូទឹកកកនៅចំខ្សែខ្យល់ ឬក្រោមកង្ហារ
- ❖ អស់ហ្គាសក្នុងធុង
- ❖ ក្បាលបញ្ចេញហ្គាសមានក្រមរ ឬខូច
- ❖ ក្បាលប្រឆេះមានក្រមរ
- ❖ តែម៉ូស្តាហ្គាសមានបញ្ហា
- ❖ សុវត្ថិភាពភ្លើងសម្រាប់បញ្ឆេះមានបញ្ហា

**ក្បាលប្រឆេះរលត់អណ្តាតភ្លើង** ទូប្រើដោយថាមពលហ្គាស

- ❖ ដាក់ទូទឹកកកនៅចំខ្សែខ្យល់ ឬក្រោមកង្ហារ
- ❖ អស់ហ្គាសក្នុងធុង
- ❖ ក្បាលបញ្ចេញហ្គាសមានក្រមរ ឬខូច
- ❖ ក្បាលប្រឆេះមានក្រមរ
- ❖ តែម៉ូស្តាហ្គាសមានបញ្ហា
- ❖ សុវត្ថិភាពភ្លើងសម្រាប់បញ្ឆេះមានបញ្ហា
- ❖ ប្រដាប់ស្ទង់កំដៅធូរលុង
- ❖ ប្រដាប់ស្ទង់កំដៅមានបញ្ហា

**ការធ្វើបញ្ជីរសារពើភ័ណ្ឌ ត្រូវធ្វើនៅរៀងរាល់ចុងឆមាសទី១ និង ចុងឆ្នាំ មួយឆ្នាំ២ដង។**

# ជំពូកទី៤៖

# ការចាក់ថ្នាំប្រកបដោយសុវត្ថិភាពនិងហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ

# ( AEFI )

# ១. ការចាក់ថ្នាំប្រកបដោយសុវត្ថិភាព

## ១-ស្ថានភាពទូទៅ

អង្គការសុខភាពពិភពលោក(WHO) បានធ្វើការប៉ាន់ស្មានថាយ៉ាងហោចណាស់មានចំនួន៥០ភាគរយក្នុងចំណោមការចាក់ថ្នាំចំនួន១២០០០លាននាក់ក្នុងមួយឆ្នាំៗ គឺគ្មានសុវត្ថិភាពដែលបង្កឲ្យមានការប៉ះពាល់សុខភាពដ៏ធ្ងន់ធ្ងរចំពោះអ្នកទទួលអ្នកអនុវត្តផ្ទាល់និង សហគមន៍(១១០០០លាននាក់គឺបណ្ដាលមកពីការទទួលការព្យាបាលផ្សេងៗនិង១០០០លាននាក់ផ្សេងទៀតបណ្ដាលពីការទទួលថ្នាំ) ការចំលងរោគដ៏ធ្ងន់ធ្ងរដោយការចាក់ថ្នាំបង្ការគ្មានសុវត្ថិភាពជារួមមានដូចជា ជំងឺរលាកថ្លើមប្រភេទ បេ ជំងឺរលាកថ្លើមប្រភេទ សេ និងជំងឺអេដស៍។ អង្គការសុខភាពពិភពលោកបានធ្វើការប៉ាន់ប្រមាណលើការចាក់ថ្នាំគ្មានសុវត្ថិភាពអាចចំលងរោគមានអត្រាដូចខាងក្រោម

- រលាកថ្លើមប្រភេទបេ ពី ៨ ទៅ ១៦ លាននាក់ក្នុង ១ ឆ្នាំ
- រលាកថ្លើមប្រភេទសេពី ២.៣ ទៅ ៤.៧ លាននាក់ក្នុង១ ឆ្នាំ
- មេរោគ HIV ពី ៨ ម៉ឺន ទៅ ១៦ ម៉ឺន នាក់ ក្នុង ១ ឆ្នាំ

## ២-ក្រុមប្រឈមមុខនឹងផលវិបាកនៃការចាក់ថ្នាំគ្មានសុវត្ថិភាព

- អ្នកទទួលក្រោយពីការទទួលការចាក់ថ្នាំណាមួយដែលគ្មានសុវត្ថិភាពអ្នកនោះនឹងត្រូវឆ្លងជំងឺដែលបង្កឡើងពីមេរោគដែលមានជាប់នឹងស៊ីរ៉ាំងម្ជុលពីអ្នកចាក់មុន។
- អ្នកអនុវត្តផ្ទាល់គឺជាអ្នកដែលអនុវត្តក្នុងការចាក់ថ្នាំឲ្យអ្នកជំងឺ។អ្នកនោះនឹងត្រូវរងនូវការចំលងតាមរយៈការមុតម្ជុលដែលមានមេរោគដោយអចេតនាក្រោយពីបានចាក់ឲ្យអ្នកជំងឺ។
- សហគមន៍:ការបោះចោលនូវសម្ភារចាក់ថ្នាំដែលមិនមានសណ្ដាប់ធ្នាប់តាមទីសាធារណៈអាចបណ្ដាលឲ្យមានការនិងឆ្លងមេរោគដល់ប្រជាជនដែលរស់នៅកន្លែងនោះ។

## ៣-ដូចម្ដេចដែលហៅថា ការផ្ដល់ថ្នាំប្រកបដោយសុវត្ថិភាព ?

ការផ្ដល់ថ្នាំប្រកបដោយសុវត្ថិភាពគឺជាសកម្មភាពមួយដែលមិនបង្កគ្រោះថ្នាក់ដល់អ្នកទទួលអ្នកផ្ដល់និង សហគមន៍ឡើយ ។

### តារាងទី៩៖ តារាងប្រៀបធៀបរវាងការផ្តល់ថ្នាំប្រកបដោយសុវត្ថិភាព និងគ្មានសុវត្ថិភាព

| ការផ្តល់ថ្នាំប្រកបដោយសុវត្ថិភាព | ការផ្តល់ថ្នាំគ្មានសុវត្ថិភាព |
| --- | --- |
| ❖ លាយវ៉ាក់សាំងឲ្យបានត្រឹមត្រូវ<br>❖ លាយវ៉ាក់សាំងដោយប្រើទឹកលាយដែលមានប្រភពផលិតដូចគ្នា<br>❖ ប្រើសីរាំងនិងម្ជុលថ្មី សម្រាប់លាយវ៉ាក់សាំងនីមួយៗ<br>❖ មិនប្រើសីរ៉ាំង និងម្ជុលដែលលាយវ៉ាក់សាំងរួចហើយ<br>❖ ដើម្បីផ្តល់វ៉ាក់សាំងដល់កុមារ<br>❖ ដបវ៉ាក់សាំងត្រូវមានផ្លាកសញ្ញាសំគាល់ឈ្មោះ<br>❖ វ៉ាក់សាំងថែរក្សានៅក្នុងធុងវ៉ាក់សាំងនិងដាក់នៅក្នុងម្លប់<br>❖ លាយវ៉ាក់សាំងក្នុងពេលដែលមានកុមារនិងស្ត្រីមកដល់ប៉ុណ្ណោះ<br>❖ ធុងវ៉ាក់សាំងគ្របឲ្យជិតល្អជានិច្ច<br>❖ កន្លែងផ្តល់ថ្នាំបង្ការស្អាត និង សមរម្យ<br>❖ មានសម្ភារៈគ្រប់គ្រាន់(សីរ៉ុាំង ម្ជុល ប្រអប់សុវត្ថិភាព)<br>❖ ចាក់ថ្នាំត្រឹមត្រូវតាមបច្ចេកទេស<br>❖ កុមារស្ថិតនៅក្នុងភាពមានលំនឹង<br>❖ ប្រើសំឡីស្អាតនៅពេលសង្កត់ទៅលើកន្លែងចាក់ថ្នាំមិនគ្របម្ជុលវិញ<br>❖ ទំលាក់សីរ៉ុាំងម្ជុលប្រើរួចទៅក្នុងប្រអប់សុវត្ថិភាពភ្លាម<br>❖ ដាក់ស៊ីរ៉ាំងត្រឹមតែ ៣ /៤នៃប្រអប់សុវត្ថិភាព<br>❖ មិនប្រើវ៉ាក់សាំងដែលកកខូច<br>❖ ដុតកំទេចប្រអប់សុវត្ថិភាពដែលប្រើប្រាស់រួចនៅក្នុងឡសុវត្ថិភាព | ❖ លាយវ៉ាក់សាំងមិនបានត្រឹមត្រូវ<br>❖ ប្រើទឹកលាយវ៉ាក់សាំង ខុសប្រភពផលិតពីគ្នា<br>❖ ប្រើសីរ៉ុាំងម្ជុលតែមួយសម្រាប់លាយវ៉ាក់សាំងគ្រប់មុខ<br>❖ ប្រើសីរ៉ុាំង និងម្ជុលដែលលាយវ៉ាក់សាំងរួចហើយដើម្បីផ្តល់វ៉ាក់សាំងដល់កុមារ<br>❖ ដបវ៉ាក់សាំងគ្មានផ្លាកសញ្ញាសំគាល់ឈ្មោះ<br>❖ វ៉ាក់សាំងដាក់ត្រូវពន្លឺថ្ងៃ<br>❖ លាយវ៉ាក់សាំងទុកយូរមុនពេលកុមារនិងស្ត្រីមកដល់<br>❖ ធុងវ៉ាក់សាំងបើកចំហចោល<br>❖ កន្លែងចាក់ថ្នាំមិនស្អាតនិងគ្មានអនាម័យ<br>❖ គ្មានសម្ភារគ្រប់គ្រាន់<br>❖ ចាក់ថ្នាំមិនត្រូវទៅតាមបច្ចេកទេស<br>❖ កុមារគ្មានលំនឹងក្នុងពេលផ្តល់ថ្នាំបង្ការ<br>❖ ប្រើម្រាមដៃ និងក្រណាត់អត់ស្អាតសង្កត់ទៅលើកន្លែងចាក់ថ្នាំ<br>❖ គ្របម្ជុលវិញ<br>❖ ចោលសីរ៉ុាំងនិងម្ជុលដែលប្រើរួច គ្មានការគ្រប់គ្រង<br>❖ ដាក់ស៊ីរ៉ាំងលើស ៣ /៤នៃប្រអប់សុវត្ថិភាព<br>❖ ប្រើវ៉ាក់សាំងដែលកកខូច<br>❖ ចោលប្រអប់សុវត្ថិភាពដែលប្រើប្រាស់រួចក្រៅឡសុវត្ថិភាព |

## ៤-ការផ្តល់ថ្នាំបង្ការប្រកបដោយសុវត្ថិភាពដោយប្រើសឺរ៉ាំងអូតូឌីសេប៊ល

"Auto-disable Syringes" ឬ ស៊ីរ៉ាំង AD

* សឺរ៉ាំងអូតូឌីសេប៊ីល "Auto-disable Syringes" ឬ ស៊ីរ៉ាំង AD




សូឡូសត / Soloshot

សឺរ៉ាំងអូតូឌីសេប៊ីល "Auto-disable Syringes" ឬ ស៊ីរ៉ាំង AD គឺជាស៊ីរ៉ាំងបែបបច្ចេកទេសថ្មីដែលវាអាចទប់ស្កាត់ការចំលងជំងឺផ្សេងៗ តាមរយៈការចាក់ថ្នាំព្រោះថាយើងមិនអាចប្រើវាលើសពីម្តងឡើយ និយាយអោយខ្លីគឺពីស្តុងរបស់វាអាចធ្វើចលនាឡើងចុះបានតែម្តងគត់ និងវាមានទំហំសម្រាប់តម្រូវតែមួយដូសប៉ុណ្ណោះ ។

### ក. ប្រភេទសឺរ៉ាំង AD ៖

សឺរ៉ាំង AD មានពីរប្រភេទដូចខាងក្រោម:

- សឺរ៉ាំង AD ចំណុះ 0,៥ មល ប្រើសំរាប់ចាក់វ៉ាក់សាំង ៖ វ៉ាក់សាំង DTP-HepB-Hib,IPV ,MR,JE, HepB,HPV និង វ៉ាក់សាំង TT
- សឺរ៉ាំង AD ចំណុះ 0,0៥មល (សរសេរ) ៖ ប្រើសំរាប់ចាក់វ៉ាក់សាំង BCG តែមួយមុខគត់

## ខ. ដំណើរការចាក់ថ្នាំបង្ការដោយប្រើប្រាស់សឺរ៉ាំង AD








- ❖ បូងយើងត្រូវរៀបចំកន្លែង និង សម្ភារផ្តល់វ៉ាក់សាំងឲ្យបានសមរម្យ
- ❖ ត្រួតពិនិត្យសីរាំង AD លើគុណភាពនិងថ្ងៃខែផុតកំណត់ប្រើប្រាស់ និង ពិនិត្យមើលស្រោមប្លាស្ទីក របស់វាផង ។
- ❖ លាងដៃជាមួយសាប៊ូ និង ទឹកស្អាត
- ❖ សំអាតគម្របដបវ៉ាក់សាំងនឹងសំឡីជ្រលក់ទឹកឆ្អិន
- ❖ ហែកស្រោមប្លាស្ទីកចេញដោយប្រយ័ត្នកុំដៃប៉ះម្ជុលនិងស៊ីរាំងដែលមានម្ជុលដាច់ពីស៊ីរាំងដកគម្របពីស្តុង ដកគម្របម្ជុល ទំលាក់ចូលទៅក្នុងប្រអប់សុវត្ថិភាព។
- ❖ ចាក់ម្ជុលចូលទៅក្នុងដបវ៉ាក់សាំងដោយរក្សាឲ្យចុងម្ជុលនៅក្នុងទឹកវ៉ាក់សាំងជានិច្ច
- ❖ បូមវ៉ាក់សាំងដោយប្រុងប្រយ័ត្នកុំឲ្យចូលខ្យល់ គឺធ្វើយ៉ាងណាអោយបានបរិមាណវ៉ាក់សាំងមាន ចំណុះ 0,0៥ មល ឬសរសេ  0,៥ មល ។ ដែលយើងត្រូវការ (សរសេរ)

ប្រសិនបើពេលបូមវ៉ាក់សាំងអ្នកសង្កេតឃើញមានបរិមាណខ្យល់ចូលក្នុងស៊ីរាំងអ្នកត្រូវបូមឲ្យដល់កំរិតអតិបរិមាបន្ទាប់មកត្រូវបញ្ចេញខ្យល់ចូលក្នុងដបវ៉ាក់សាំងវិញ ដោយរក្សាបរិមាណវ៉ាក់សាំងត្រឹម 0,0៥ មល ឬ 0,៥ មល ដែលយើងត្រូវការ សរសេ

- ❖ ជូតសំអាតកន្លែងចាក់ឲ្យបានស្អាតដោយសំឡីជ្រលក់ទឹកឆ្អិន បន្ទាប់មកចាក់វ៉ាក់សាំងទៅតាមបច្ចេកទេសណែនាំ    BCG ចាក់សើរស្បែក MR ចាក់ក្រោមស្បែក ហើយ DTP-HepB-Hib និង TT ចាក់សាច់ដុំ ។

ក្រោយពីចាក់រួចយើងត្រូវទំលាក់ស៊ីរ៉ាំង AD និង ម្ជុលរបស់វាចូលទៅក្នុងប្រអប់សុវត្ថិភាពជាបន្ទាន់ដោយទំលាក់ខាងម្ជុលទៅមុន ។

### គ. ការគណនាតំរូវការ ៖ ចំនួនសីរ៉ាំង AD ខែបន្ទាប់:

ចំពោះស៊ីរ៉ាំង0,១/0.0៥មល ឬ 0,៥មល (ស្មើនិងចំនួន ស្តុកអតិបរិមា ដកចំនួនស្តុកដែលមានស្រាប់ ចំនួនស៊ីរ៉ាំងលាយ ៖

- ចំពោះស៊ីរ៉ាំង ២មល ត្រូវស្មើនឹងចនួនដបវ៉ាក់សាំង BCG ដែលបានបើក
- ចំពោះស៊ីរ៉ាំង ៥មល ត្រូវស្មើនឹងចនួនដបវ៉ាក់សាំង MR និង JE ដែលបានបើក

## ៥-ប្រអប់សុវត្ថិភាព "Safety box"

ប្រអប់សុវត្ថិភាពគឺជាប្រអប់ក្រដាសកាតតុងរឹងដែលប្រើប្រាស់សម្រាប់ដាក់ស៊ីរ៉ាំង AD ដែលប្រើហើយនៅពេលផ្តល់ថ្នាំបង្ការ ។ ប្រការចាំបាច់ដែលយើងត្រូវប្រើប្រអប់សុវត្ថិភាពគឺនៅរាល់ពេលដែលមានសកម្មភាពផ្តល់ថ្នាំបង្ការ ព្រោះប្រអប់សុវត្ថិភាពអាចធានាបាននូវសុវត្ថិភាពគ្រប់ពេលដែលយើងទំលាក់ស៊ីរ៉ាំង ម្ជុល វត្ថុមុតស្រួចគម្របពីស្តុង និងគម្របម្ជុលចូលទៅក្នុងប្រអប់នេះ។ ការការពារបានដូច្នេះដោយសារប្រអប់នេះ មានភាពស្ថិតធានាបានមិនឲ្យម្ជុលឬវត្ថុស្រួចផ្សេងៗទៀតដែលប្រើរួចចាក់ទំលុះភាពស្ថិតរបស់វាមកមុតយើង បានហើយវាមានទំងន់ស្រាលបំផុតងាយស្រួលក្នុងការដឹកជញ្ជូនទៀតផង ។




នៅរាល់ពេលប្រើប្រាស់ប្រអប់សុវត្ថិភាព បុគ្គលិកផ្តល់ថ្នាំបង្ការត្រូវចងចាំប្រការដូចខាងក្រោម ៖

- ត្រូវមានប្រអប់សុវត្ថិភាពជាចាំបាច់រាល់ពេលបើកទិវា
- ត្រូវតំលើងប្រអប់សុវត្ថិភាពតាមការណែនាំដែលនៅភ្ជាប់នឹងប្រអប់នេះ

- ក្នុងប្រអប់សុវត្ថិភាពត្រូវដាក់តែស៊ីរាំងនិងគម្របស៊ីរាំងតែប៉ុណ្ណោះ
- ប្រអប់សុវត្ថិភាពត្រូវតែរក្សាឲ្យស្ងួតជានិច្ច និង ទុកដាក់នៅកន្លែងដែលមានសុវត្ថិភាពល្អ
- មិនត្រូវផ្ទេរស៊ីរាំង AD ដែលប្រើប្រាស់រួចពីប្រអប់មួយទៅប្រអប់មួយទៀតឡើយ
- ត្រូវដាក់សីរាំងត្រឹមតែ ៣ ភាគ ៤ នៃប្រអប់សុវត្ថិភាពតែប៉ុណ្ណោះ ។ ប្រសិនបើការដាក់សីរាំង(សូមមើលរូបខាងលើ)មិនទាន់បាននៃចំណុះប្រអប់៣ភាគ៤ មិនទាន់បានសុវត្ថិភាពទេ ត្រូវយកវាទៅប្រើបន្តទៀត។
- ចំនួនប្រអប់សុវត្ថិភាពត្រូវស្មើនឹងចំនួនស៊ីរាំងសរុបចែកនឹង ១៥០ មានន័យថាប្រអប់សុវត្ថិភាពមួយជាមធ្យមអាចដាក់បានសីរាំងបានចំនួន ១៥ ។

## ៦-ការផ្គត់ផ្គង់

ការផ្គត់ផ្គង់សីរាំង AD ប្រអប់សុវត្ថិភាពនិងការប្រមូលមកវិញដើម្បីដុតកំទេចថ្នាក់ស្រុកប្រតិបត្តិ ជាអ្នកគ្រប់គ្រងលើការបែងចែកសីរាំង AD ប្រអប់សុវត្ថិភាព និង វ៉ាក់សាំងដល់ថ្នាក់មណ្ឌលសុខភាពនូវចំនួនត្រឹមត្រូវតាមសំណើរតម្រូវការជាក់ស្តែង ឬតាមផែនការ ហើយត្រូវតាមដានការប្រមូលប្រអប់សុវត្ថិភាពដែលពេញឲ្យបានអស់ពីគ្រប់មណ្ឌលសុខភាព។

ថ្នាក់មណ្ឌលសុខភាពក្រោយពីបានទទួលស៊ីរាំងAD ប្រអប់សុវត្ថិភាព វ៉ាក់សាំង រួចមកត្រូវប្រមូលមកវិញនូវប្រអប់សុវត្ថិភាពដែលពេញជូនថ្នាក់ស្រុកប្រតិបត្តិវិញនៅមុនពេលទទួលសីរាំង AD ប្រអប់សុវត្ថិភាព វ៉ាក់សាំងពីថ្នាក់ស្រុកប្រតិបត្តិជាថ្មី ។

## ៧- ការដុតកំទេចប្រកបដោយសុវត្ថិភាព ៖

ត្រូវដុតដោយឡពិសេស ដែលបានដាក់ឲ្យប្រើប្រាស់ដោយក្រសួងសុខាភិបាល និង គាំទ្រដោយ អង្គការសុខភាពពិភពលោក ដែលអាចដុតកំទេចកាកសំណល់មន្ទីរពេទ្យ និង ប្រអប់សុវត្ថិភាពបានយ៉ាងល្អប្រសើរ ហើយប្រអប់សុវត្ថិភាពដែលពេញត្រូវតែប្រមូលមកដុតក្នុងឡនេះទាំងអស់ ។ ដូចជាឡ SICIM ជាឡដែលមានកំដៅក្តៅខ្លាំងនៅពេលដុតកំដៅលើសពី ៨០០ C ដូច្នេះការដុតកំទេចស៊ីរាំង និង ម្ជុលក្នុងឡនេះអាចកាត់បន្ថយបាននូវជាតិពុលដែលកើតមានឡើងក្នុងផ្សែងក្រោយពីដុតស៊ីរាំងនិងអាចសំលាប់មេរោគផ្សេងៗ ដែលមានជាប់នឹងម្ជុលបាន ។ ដូច្នេះការធ្វើបែបនេះទើបយើងអាចជៀសផុតពីការចំលងរោគផ្សេងៗ តាមរយៈការមុតម្ជុលដែលប្រើប្រាស់រួច ឬ ការរើសយកកាកសំណល់ស៊ីរាំងជំរធម្មតា ដែលបានប្រើប្រាស់រួចយកមកច្រកចង់ប្លាស្ទិកបន្តលក់នៅលើទីផ្សារ និង កាត់បន្ថយជាតិពុលក្នុងបរិស្ថាន ។ ប្រអប់សុវត្ថិភាពដែលពេញទាំងអស់ ត្រូវយកមកដុតកំទេចចោលនៅក្នុងប្រភេទឡ ដូចឡ SICIM !

## ៨-ការតាមដាន និង វាយតំលៃ

### ក.ពេលចប់ទិវា ៖

អ្នកផ្តល់ថ្នាំបង្ការត្រូវកំណត់ឲ្យបានច្បាស់នូវចំនួនម្ជុលស៊ីរ៉ាំងដែលបានប្រើ និង នៅសល់ដោយប្រៀបធៀបជាមួយនិង ចំនួនដែលចាក់បាន ។

### ខ.ពេលចុងខែ

ត្រូវកំណត់ឲ្យបានច្បាស់នូវចំនួនដែលមានសល់ជាក់ស្តែងជាមួយនឹងចំនួនដែលមានក្នុងរបាការណ៍ និង សលាកប័ត្រឃ្លាំងដោយធ្វើការពិនិត្យផ្ទៀងផ្ទាត់លើគុណភាពផងដែរ ។

### គ.រាល់ត្រីមាស

- គប្បីសាកល្បងធ្វើការគណនារកអត្រាខាតបង់ និងធ្វើការសាកល្បងរិះរកមូលហេតុដែលបណ្តាល ឲ្យមានអត្រាបោះបង់ខ្ពស់ ។
- គប្បីសាកល្បងធ្វើការដោះស្រាយតាមមូលហេតុដែលអាចធ្វើទៅបាន ។
- រូបមន្តសំរាប់គណនា-អត្រាខាតបង់ស៊ីរ៉ាំង AD(គិតជាភាគរយ)

$$\text{ស៊ីរ៉ាំង AD 0.0៥ml (BCG)} \quad \frac{\text{ចំនួនស៊ីរ៉ាំង AD 0.0៥ml (BCG) ប្រើប្រាស់និងខូចខាត - ចំនួនកុមារទទួល BCG}}{\text{ចំនួនស៊ីរ៉ាំង AD 0.0៥ml (BCG) ប្រើប្រាស់និងខូចខាត}} \text{ X 100}$$

$$\text{ស៊ីរ៉ាំង AD 0.៥ml} = \frac{\text{(ចំនួនស៊ីរ៉ាំងAD0.៥mlប្រើប្រាស់និងខូចខាត) - ចំនួនចាក់ (DTC-HepB-Hib+TT+MR+JE...)}}{\text{ចំនួនស៊ីរ៉ាំង AD 0.៥ml ប្រើប្រាស់និងខូចខាត}} \text{ X 100}$$

ឧទាហរណ៍ ៖ អត្រាខាតបង់ស៊ីរ៉ាំងអេឌី 0,៥មល ។ ក្នុងត្រីមាសកន្លងមក តាមរយៈ លទ្ធផលផ្តល់ថ្នាំបង្ការយើង ពិនិត្យឃើញថា យើងបាន DTP-HepB1 = 20, DTP-HepB2 = 18, DTP-HepB3 = 12, Rouvax (Measles) = 15, TT1 = 30, TT2 = 25, TT3 = 20, TT4 = 16, TT5 = 15។ ឯចំណែកស៊ីរ៉ាំងយើងពិនិត្យ ក្នុងរបាយការណ៍ប្រើប្រាស់ ខូចខាតដោយផ្ទៀងផ្ទាត់ជាមួយសលាកប័ត្រឃ្លាំងយើងឃើញថា ទាំងការប្រើប្រាស់ និង ខូចខាត បាត់បង់មានចំនួន ២១០ គ្រឿង ។

ដូច្នេះអត្រាខាតបង់ស៊ីរាំង អេឌី ០,៥មល ស្មើនិង ៖

$$= \frac{(210) - (20 + 18 + 12 + 15 + 30 + 25 + 20 + 16 + 15)}{210} \times 100$$

$$= \frac{210 - 171}{210} \times 100 = 18,57\%$$

| អត្រាខាតបង់ស៊ីរាំងអេឌី ០,៥មល ក្នុងត្រីមាសកន្លងមក 18,57% |
|---|

## ៩-ចំណុចសំខាន់ៗ អំពីការផ្តល់ថ្នាំដោយសុវត្ថិភាព

### ក. ស៊ីរាំងអូតូឌីសេប៊ល ( Auto-disable Syringes ឬ ស៊ីរាំង AD )

- ស៊ីរាំង AD ចំណុះ ២ ខុសគ្នា ៖
  - ចំណុះ ០,៥ មល (សរសេរ) សំរាប់ចាក់វ៉ាក់សាំង DTP-HepB-Hib,PCV,IPV,HepB,JE, តេតាណុល, MR , HPV
  - ចំណុះ ០,០៥ មល (សេសេ) សំរាប់ចាក់វ៉ាក់សាំង BCG
- មិនត្រូវធ្វើតេស្តស៊ីរាំងមុនបូមវ៉ាក់សាំង
- ត្រូវបូមវ៉ាក់សាំងយឺតៗ
- ពេលចាក់មិនចាំបាច់សាកល្បងបឺតទេ (aspirate)
- ក្រោយពេលចាក់មិនត្រូវគ្របម្ជុលវិញទេ
- ស៊ីរាំងប្រើហើយត្រូវតែទម្លាក់ក្នុងប្រអប់សុវត្ថិភាពភ្លាម !
- ស៊ីរាំង AD សល់ក្រោយចប់ទិវាត្រូវបញ្ជូលទៅក្នុងស្តុករបស់មណ្ឌលសុខភាពវិញរាល់ពេល

### ខ. ប្រអប់សុវត្ថិភាព ( Safety Box )

- ត្រូវមានប្រអប់សុវត្ថិភាពជាប់រហូតគ្រប់ទីកន្លែងដែលប្រើ AD ស៊ីរាំង
- ប្រអប់សុវត្ថិភាពសម្រាប់តែម្ជុល ស៊ីរាំង គម្របស៊ីរាំង និង គម្របម្ជុលតែប៉ុណ្ណោះ
- ត្រូវប្រើរហូតដល់ពេញ (៣/៤ នៃប្រអប់)ដោយរក្សានៅកន្លែងស្ងួត និងមានសុវត្ថិភាពជាប់ជានិច្ច ។
- មិនត្រូវផ្ទេរ AD ស៊ីរាំងដែលប្រើរួចពីប្រអប់មួយទៅប្រអប់មួយទៀតឡើយ
- ប្រអប់សុវត្ថិភាពដែលពេញ ត្រូវប្រគល់ឲ្យថ្នាក់ស្រុកប្រតិបត្តិវិញដើម្បីចាត់ចែងក្នុងការដុតកំទេចក្នុងឡពិសេស ។




**ឡសម្រាប់ដុតប្រអប់សុវត្ថិភាព - INCINERATOR**

# ហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ

## Adverse Events Following Immunization (AEFI)

ហេតុការណ៍ដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ(AEFI) គឺជាហេតុការណ៍វេជ្ជសាស្ត្រណាមួយកើតឡើងបន្ទាប់ពីការផ្តល់ថ្នាំបង្ការតែតាមពិតមូលហេតុរបស់វាមិនបណ្តាលមកពីការប្រើប្រាស់វ៉ាក់សាំងទេ ។ ហេតុការណ៍នេះអាចជាសញ្ញាមួយដែលកើតឡើងដោយចេតនា ឬ មិនចេតនាណាមួយដែលអាចបញ្ជាក់បានច្បាស់លាស់តាមរយៈមន្ទីរពិសោធន៍ ឬ ក៏ការស្តែងចេញជាជម្ងឺតែម្តង ។

វ៉ាក់សាំងដែលគេប្រើប្រាស់នៅក្នុងកម្មវិធីជាតិផ្តល់ថ្នាំបង្ការគឺមានសុវត្ថិភាពនិងមានប្រសិទ្ធិភាពបំផុត។ដូចនេះបញ្ហាកើតមានឡើងក្រោយផ្តល់ថ្នាំបង្ការធ្ងន់ធ្ងរអាចមានដោយកម្របំផុត ។ ហេតុការណ៍ដែលកើតមានក្រោយផ្តល់ថ្នាំបង្ការត្រូវបានចាត់ថ្នាក់ជាប្រាំប្រភេទ ។ (តារាងទី១) ហេតុការណ៍ដែលកើតមានក្រោយផ្តល់ថ្នាំបង្ការគឺមិនមែនសុទ្ធតែមកពីវ៉ាក់សាំងទេករណីខ្លះទាក់ទងទៅនឹងកំហុសបច្ចេកទេសនៅពេលវ៉ាក់សាំងករណីខ្លះទាក់ទងទៅនឹងការផលិតផលនៃ

វ៉ាក់សាំងករណីខ្លះទាក់ទងទៅនឹងគុណភាពនៃការផលិតវ៉ាក់សាំងករណីខ្លះទៀតទាក់ទងទៅនឹងការភ័យខ្លាច ចំណែកករណីផ្សេងៗទៀតអាចទាក់ទងទៅនឹងហេតុការណ៍ជាន់ដានដែលរួមផ្សំជាមួយការផ្តល់ថ្នាំបង្ការ។

## តារាងទី១៖ប្រភេទមូលហេតុជាក់លាក់នៃហេតុការណ៍ដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ

| ប្រភេទមូលហេតុជាក់លាក់នៃហេតុការណ៍ដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ | និយមន័យ |
|---|---|
| ១.ប្រតិកម្មដែលមានការទាក់ទងទៅនឹងផលិតផលនៃវ៉ាក់សាំង<br>Vaccine product-related reaction | ហេតុការណ៍ដែលកើតមានក្រោយផ្តល់ថ្នាំបង្ការណាមួយដែលត្រូវបានបង្កឡើងដោយសមាសភាពផ្សំមួយឬច្រើនដែលមាននៅក្នុងវ៉ាក់សាំង។ |
| ២.ប្រតិកម្មដែលមានការទាក់ទងទៅនឹងគុណភាព នៃការផលិតវ៉ាក់សាំង<br>Vaccine quality defect-related reaction | ហេតុការណ៍ដែលកើតមានក្រោយផ្តល់ថ្នាំបង្ការមួយដែលត្រូវបានបង្កឡើងមកពីវ៉ាក់សាំងខូចគុណភាពនៅពេលផលិតផលវ៉ាក់សាំងដោយខូចគុណភាពនៃសមាសភាពផ្សំមួយ ឬ ច្រើននៃផលិតផលវ៉ាក់សាំងរួមទាំងឧបករណ៍ដែលបានផ្តល់ដោយក្រុមហ៊ុនផលិតផងដែរ ។ |
| ៣.ប្រតិកម្មដែលមានការទាក់ទងទៅនឹងកំហុសបច្ចេកទេសនៅពេលផ្តល់វ៉ាក់សាំង<br>Immunization error-related reaction (formerly “programme error”) | ប្រតិកម្មដែលមានការទាក់ទងទៅនឹងកំហុសបច្ចេកទេសនៅពេលផ្តល់វ៉ាក់សាំងដែលត្រូវបានបង្កឡើងដោយសារការគ្រប់គ្រងវ៉ាក់សាំងមិនបានសមរម្យដូចជា៖<br>• ការលាយវ៉ាក់សាំង<br>• ការទុកដាក់ ការដឹកជញ្ជូនវ៉ាក់សាំងនិង<br>• ការផ្តល់ដែលជាធម្មតាអាចការពារបាន |
| ៤. ប្រតិកម្មដែលមានការទាក់ទងទៅនឹងការភ័យខ្លាចឬការព្រួយបារម្មណ៍<br>Immunization anxiety-related reaction | ហេតុការណ៍ដែលកើតមានក្រោយផ្តល់វ៉ាក់សាំង ដែលកើតឡើងពីការបារម្ភឬ ការភ័យខ្លាចអំពីការចាក់វ៉ាក់សាំង។ |
| ៥. ប្រតិកម្មដែលមានការទាក់ទងទៅនឹងហេតុការណ៍ជាន់ដាន<br>Coincidental event | ហេតុការណ៍ដែលកើតមានក្រោយផ្តល់ថ្នាំបង្ការមួយដែលត្រូវបានបង្កឡើងដោយអ្វីផ្សេងក្រៅពីផលិតផលវ៉ាក់សាំងកំហុសបច្ចេកទេសនៃការផ្តល់ថ្នាំបង្ការឬក៏ការភ័យខ្លាចការចាក់ថ្នាំបង្ការ |

**ចំណាំ ៖**

- ពាក្យថា “**ថ្នាំបង្ការ**”សំដៅទៅដល់ការប្រើប្រាស់វ៉ាក់សាំងផ្តល់ដល់ប្រជាជនចំណុចម្នាក់ៗ
- ពាក្យថា “**ទ្រើប្រាស់**”សំដៅទៅដល់ដំណើរការដែលកើតមានឡើងបន្ទាប់ពីផលិតវ៉ាក់សាំងបានបញ្ចេញពីរោងចក្រ ឧទាហរណ៍ ៖ ការផ្តល់វ៉ាក់សាំង ឬ ការចាក់វ៉ាក់សាំង។

## ១. ប្រតិកម្មដោយសារវ៉ាក់សាំង(Vaccine reaction)

**ប្រតិកម្មដោយសារវ៉ាក់សាំង**ត្រូវបានចំណាក់ថ្នាក់ជា **ប្រតិកម្មធម្មតា ឬប្រតិកម្មបន្ទាប់បន្សំ**និង**ប្រតិកម្មធ្ងន់ធ្ងរ**ដែលកើតមានដ៏កម្រ។ភាគច្រើននៃប្រតិកម្មវ៉ាក់សាំង គឺជាប្រតិកម្មធម្មតា ឬ ប្រតិកម្មបន្ទាប់បន្សំ (ប្រតិកម្មស្រាលៗ) និងអាចដោះស្រាយដោយខ្លួនឯងបាន។ចំណែកឯប្រតិកម្មធ្ងន់ធ្ងរគឺ ប្រតិកម្មមួយដែលគេកម្រនឹងជួបប្រទះណាស់ដែលជាទូទៅប្រតិកម្មធ្ងន់ធ្ងរតែងតែកើតឡើងភ្លាមៗក្រោយការផ្តល់វ៉ាក់សាំង។ចំណាត់ថ្នាក់ប្រភេទថ្មីៗនៃមូលហេតុជាក់លាក់គឺមានសារៈសំខាន់សម្រាប់ការសម្រេចចិត្តនៅលើការជ្រើសរើសផលិតផលវ៉ាក់សាំង ប្រតិកម្មវ៉ាក់សាំង អាចចែកជាពីរប្រភេទខុសគ្នាគឺ៖

**[ក] ប្រតិកម្មដែលមានការទាក់ទងទៅនឹងផលិតផលនៃវ៉ាក់សាំង** គឺប្រតិកម្មដែលកើតមានឡើងទៅបុគ្គលដែលទាក់ទង ទៅនិងផលិតផលរបស់វ៉ាក់សាំងទោះ បីជាមានការគ្រប់គ្រង វ៉ាក់សាំងបានត្រឹមត្រូវដូចជា៖ ការលាយវ៉ាក់សាំង ការទុកដាក់វ៉ាក់សាំង ការដឹកជញ្ជូនវ៉ាក់សាំង និង ការផ្តល់វ៉ាក់សាំងបានត្រឹមត្រូវក៏ដោយ ។

**[ខ]ប្រតិកម្មដែលមានការទាក់ទងទៅនឹងគុណភាពនៃវ៉ាក់សាំង** គឺប្រតិកម្មដែលកើតមានឡើងបណ្តាលមកពីវ៉ាក់សាំងខូចគុណភាព នៅពេលផលិតផលវ៉ាក់សាំង ។ ដោយសារវ៉ាក់សាំងខូចគុណភាព ភាពស៊ាំដែលកើតឡើងដោយសារវ៉ាក់សាំងរបស់បុគ្គលដែលទទួលវ៉ាក់សាំងនោះក៏មិនមានដែរ ហើយវាក៏បង្កហានិភ័យ នៃប្រតិកម្មកើតឡើងក្រោយទទួលថ្នាំបង្ការទៀតផង ។ ការបង្កើនគុណភាពផលិតទៅតាមស្តង់ដា(GMP) និង ការបង្កើនគុណភាពផលិតទៅតាមស្តង់ដាធ្វើឱ្យមានការថយចុះ នូវការខូចគុណភាពនៃវ៉ាក់សាំងថយចុះនៅពេលផលិត។

### ១.១. ប្រតិកម្មវ៉ាក់សាំងធម្មតាឬបន្ទាប់បន្សំ (Common and minor vaccine reactions)

គោលបំណងនៃការផ្តល់វ៉ាក់សាំងគឺធ្វើឱ្យបង្កើតប្រព័ន្ធភាពស៊ាំការពារជម្ងឺនៅក្នុងសរីរាង្គ។ប្រតិកម្មធម្មតា ឬ បន្ទាប់បន្សំមានដូចជាក្តៅខ្លួន និង រោគសញ្ញាផ្សេងៗទៀត និងបញ្ជាក់ពីការបង្កើតឡើងនូវភាពស៊ាំនៃសមាសធាតុរបស់វ៉ាក់សាំង។ចំណុចនេះបង្ហាញភាពជោគជ័យរបស់វ៉ាក់សាំងគឺប្រព័ន្ធបង្កើតភាពស៊ាំការពារជំងឺដ៏ល្អបំផុត។ (ឧបសម្ព័ន្ធទី១ ប្រតិកម្មញឹកញាប់ដែលកើតឡើងដោយសារវ៉ាក់សាំង)

## ១.២. ប្រតិកម្មវ៉ាក់សាំងធ្ងន់ធ្ងរដែលកើតមានជាកម្រ (Rare, serious vaccine reaction)

ភាគច្រើនកម្រជួបប្រតិកម្មធ្ងន់ធ្ងរណាស់ប៉ុន្តែអាចមានដូចជា:Seizures,Thrombocytopenia.etc. ហើយជាទូទៅកើតមានភ្លាមៗ ក្រោយផ្តល់វ៉ាក់សាំង។Anaphylaxis អាចស្លាប់ដូចនេះត្រូវការព្យាបាលឱ្យទាន់ពេលទើបមានប្រសិទ្ធិភាព ។ ហេតុការណ៍ធ្ងន់ធ្ងរភាគច្រើនដែលកើតមាន ក្រោយផ្តល់ថ្នាំបង្ការត្រូវបានរាយការណ៍ គឺ ជាហេតុការណ៍ជាន់ដានដែលច្រើនជួបប្រទះជាញឹកញាប់ជាងប្រតិកម្ម ដោយសារវ៉ាក់សាំងពិតប្រាកដ។

## ២. ប្រតិកម្មដែលមានការទាក់ទងទៅនឹងកំហុសបច្ចេកទេសនៅពេលផ្តល់ថ្នាំបង្ការ

## (Immunization error-related reaction)

ហេតុការណ៍ដែលមានការទាក់ទងទៅនឹងកំហុសបច្ចេកទេសនៅពេលផ្តល់ថ្នាំបង្ការ(ដែលគេស្គាល់ពីមុនថាជា "កំហុសបច្ចេកទេស") បណ្តាលមកពីការរៀបចំទុកដាក់វ៉ាក់សាំងការលាយវ៉ាក់សាំង និងការផ្តល់វ៉ាក់សាំងមិនបានត្រឹមត្រូវតាមបច្ចេកទេស។ការស្វែងរកមូលហេតុ និង កែតម្រូវនូវកំហុសឆ្គងគឺវាមានសារៈសំខាន់ណាស់ដើម្បីបញ្ចៀសការខូចខាតផលប្រយោជន៍ដល់កម្មវិធីផ្តល់ថ្នាំបង្ការ ។

ការកំណត់អត្តសញ្ញាណនិងការកែកំហុសទាំងនេះគឺមានសារៈសំខាន់និងជាគោលដៅនៃការតាមដានរកករណីហេតុការណ៍ដែលកើតមានក្រោយផ្តល់ថ្នាំបង្ការនេះដើម្បីការពារបុគ្គលិកសុខាភិបាលផ្តល់ថ្នាំបង្ការ (តារាងទី២) ។

ប្រតិកម្មដែលមានការទាក់ទងទៅនឹងកំហុសបច្ចេកទេស នៅពេលផ្តល់ថ្នាំបង្ការអាចនាំឱ្យមានជាចង្កោម នៃហេតុការណ៍ដែលបានផ្សាភ្ជាប់ជាមួយនឹងការផ្តល់ថ្នាំបង្ការ។ ចង្កោមទាំងនេះជាធម្មតាត្រូវបានរួមផ្សំជាមួយ នឹង ការផ្តល់សេវានៅមណ្ឌលសុខភាពឬដបមួយនៃវ៉ាក់សាំងដែលត្រូវបានរៀបចំមិនបានសមរម្យឬក៏ធ្វើឱ្យឆ្លងរោគ ។ កំហុសបច្ចេកទេសរបស់កម្មវិធីផ្តល់ថ្នាំបង្ការក៏អាចប៉ះពាល់ដល់វ៉ាក់សាំងជាច្រើន ឧទាហរណ៍៖ ការកកវ៉ាក់សាំងអំឡុងពេលដឹកជញ្ជូន នាំឱ្យមានការកើនឡើងប្រតិកម្មនៅកន្លែងចាក់ ។

## តារាងទី២ ៖ ប្រតិកម្មទាក់ទងនឹងកំហុសការផ្តល់ថ្នាំបង្ការ

| ប្រភេទការអនុវត្តន៍ខុសឆ្គង | ហេតុការណ៍ដែលកើតមាន |
|---|---|
| **ការចាក់វ៉ាក់សាំងដោយមិនបានសម្លាប់មេរោគ** (Non-sterile injection):<br>• ការប្រើសឺរាំង ម្ជុលដែលប្រើហើយ<br>• ប្រើសឺរាំង ម្ជុលដែលមិនបានសម្លាប់មេរោគ<br>• វ៉ាក់សាំង ឬ ទឹកលាយដែលមានឆ្លងរោគ<br>• ប្រើវ៉ាក់សាំងដែលលាយរួចហើយទុកប្រើនៅទិវាបន្តបន្ទាប់ | **ការឆ្លងរោគ:**<br>ករខ្ទុះនៅកន្លែងចាក់(អាប់សែ)រលាកកោសិកា ឆ្លងជម្ងឺអេដស៍ រលាកថ្លើមប្រភេទ បេ និង សេ, toxic shock syndrome |
| **ការរៀបចំវ៉ាក់សាំងមិនបានត្រឹមត្រូវ** (Vaccine prepared incorrectly):<br>• លាយវ៉ាក់សាំងជាមួយទឹកលាយមកពីប្រភពផ្សេងគ្នា<br>• ប្រើទឹកលាយសម្រាប់ថ្នាំជំនួសទឹកលាយសម្រាប់វ៉ាក់សាំង | **ប្រតិកម្មកន្លែងចាក់:**<br>អាប់សែដោយក្រឡុកល្បាយវ៉ាក់សាំងមិនស្មើ បែបផែននៃឱសថ ដូចជាថ្នាំសម្រួលសសៃអាំងស៊ុយលីន |
| **ចាក់វ៉ាក់សាំងខុសបច្ចេកទេស** (Vaccine injected in wrong site):<br>• ចាក់សើរស្បែកបែរជាចាក់ក្រោមស្បែក (BCG)<br>• ចាក់រាក់ពេក ចំពោះវ៉ាក់សាំង (TT និង DPT-HepB)<br>• ចាក់កំប៉េះគូទ | **ប្រតិកម្មកន្លែងចាក់:**<br>• អាប់សែកន្លែងចាក់<br>• ចាក់ប៉ះសសៃប្រសាទ |
| **ការដឹកជញ្ជូនវ៉ាក់សាំង/ការទុកដាក់មិនត្រឹមត្រូវធ្វើឱ្យវ៉ាក់សាំងកក** (Vaccine transported/stored incorrectly frozen vaccine) | បង្កើនប្រតិកម្មកន្លែងចាក់ដោយសារវ៉ាក់សាំងកក (ដោយសារវ៉ាក់សាំង គ្មានប្រសិទ្ធភាព) |
| **មិនយកចិត្តទុកដាក់នៅនឹងបម្រាម** (Contraindication Ignored) | ប្រតិកម្មវ៉ាក់សាំងធ្ងន់ធ្ងរ |

### ៣. ប្រតិកម្មដែលមានការទាក់ទងទៅនឹងការភ័យខ្លាច (Immunization anxiety related events)

ប្រតិកម្មទាំងនេះមិនត្រូវបានទាក់ទងទៅនឹងការចាក់វ៉ាក់សាំងនោះទេប៉ុន្តែដើម្បីចាក់ថ្នាំបង្ការបុគ្គលមួយចំនួនប្រហែលជាខ្លាចមូលធ្វើឱ្យមានប្រតិកម្មបែបនេះ ។ ប្រតិកម្មនេះមិនទាក់ទងទៅនឹងធាតុផ្សំនៃវ៉ាក់សាំងទេ ។ ការដួលសន្លប់នេះគឺជារឿងធម្មតា ប៉ុន្តែជាធម្មតាប៉ះពាល់តែកុមារដែលមានអាយុលើសប្រាំឆ្នាំ។ការដួលសន្លប់មិនតម្រូវឱ្យមានការគ្រប់គ្រងណាមួយលើសពីការដាក់អ្នកជម្ងឺឱ្យសម្រាក។ទោះជាយ៉ាងណាអ្នកដែលសន្លប់អាចកើតមានឡើងជាច្រើននាទីបន្ទាប់ពីចាក់ថ្នាំបង្ការនោះ។ហើយជាញឹកញាប់វាច្រឡំជាមួយ Anaphylaxis ( ដែលកម្រណាស់ ) Hyperventilation ជាលទ្ធផលនៃការបារម្ភអំពីការចាក់ថ្នាំបង្ការតែមានរោគសញ្ញាជាក់លាក់ (ឈឺក្បាល វិលមុខ ញាក់នៅជុំវិញមាត់និងដៃ) ។

ក្មេងមានប្រតិកម្មផ្សេងៗគ្នាដែលអាចមានក្អួតជាធម្មតាដោយសារការបារម្ភទូទៅ ។ ការថប់ដង្ហើមអាចកើតឡើងដែរ និង បញ្ចប់នៅក្នុងរយៈពេលខ្លី មានស្មារតីឡើងវិញពេលដែលដង្ហើមដកធម្មតាវិញ។ កុមារក៏អាចនឹងស្រែកដើម្បីទប់ស្កាត់ការចាក់ថ្នាំបង្ការ ឬ រត់គេចក្នុងស្ថានភាពបែបនេះអាចធ្វើឱ្យមានការស្លន់ស្លោប្រសិនបើមានកុមារណាមួយដួលសន្លប់ឬមានប្រតិកម្មផ្សេងទៀត។

### ៤.ហេតុការណ៍ជាន់ដាន( Coincidental events )

ហេតុការណ៍ជាន់ដានអាចកើតមានគាប់ជួនពេលជាមួយការចាក់ថ្នាំបង្ការដោយគេសន្និដ្ឋានថាបណ្តាលមកពីចាក់វ៉ាក់សាំងគឺមិនប្រាកដទេ ។ ប៉ុន្តែហេតុការណ៍ជាន់ដានអាចកើតដោយចៃដន្យក្រោយពេលផ្តល់ថ្នាំបង្ការហេតុការណ៍ទាំងនេះមិនអាចចៀសរួចពេលដែលការផ្តល់វ៉ាក់សាំងមានចំនួនច្រើនដូសជាពិសេសក្នុងពេលអនុវត្តយុទ្ធនាការការផ្តល់វ៉ាក់សាំងតាមប្រតិទិនពេលទារកទើបនឹងកើតទោះបីមានការឆ្លងរោគ និង មានជម្ងឺផ្សេងៗក៏ដោយព្រមទាំងរួមបញ្ចូលទាំងជម្ងឺពីកំណើតឬជម្ងឺសរសៃប្រសាទ ។ ដូច្នេះហើយការផ្តល់ថ្នាំបង្ការដល់ទារក/កុមារទាំងនោះនឹងអាច បណ្តាលឱ្យមានហេតុការណ៍ជាន់ដានច្រើនកើតឡើងរួមទាំងករណីស្លាប់ផងដែរ។មានតែការអង្កេតវាយតម្លៃឱ្យបានគ្រប់ជ្រុងជ្រោយនិងកំណត់មូលហេតុឱ្យបានច្បាស់លាស់ទេដែលនឹងបង្ហាញថាការស្លាប់ជារឿងចៃដន្យមិនបានទាក់ទងទៅនឹងថ្នាំបង្ការឬការចាក់ថ្នាំបង្ការ។៕

## ការឆ្លើយតបទៅនឹងបញ្ហាដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ Responding to AEFI

វាជាការសំខាន់ណាស់ដែលនៅតាមថ្នាក់នីមួយៗផ្តល់សេវា(ស្រុកប្រតិបត្តិមន្ទីរសុខាភិបាលខេត្តនិងកម្មវិធីជាតិ) បានបង្កើតក្រុមការងារមួយ "**ឆ្លើយតបជំនាប់រហ័ស**" ដើម្បីដោះស្រាយបញ្ហានៃហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការដែលបានរាយការណ៍ ។ ក្រុមនេះនឹងផ្តោតចម្បង ទៅលើការគាំទ្រការអង្កេតវិធានការកែប្រែសកម្មភាពឆ្លើតបទៅនឹងការព្រួយបារម្ភរបស់សហគមន៍និងការប្រាស្រ័យទាក់ទង។ជៀសវាងកុំឱ្យមានសេចក្តីថ្លែងការណ៍មុន អំពីមូលហេតុនៃហេតុការណ៍មុន ពេលការអង្កេតត្រូវបានបញ្ចប់។ប្រសិនបើមូលហេតុត្រូវបានកំណត់ថាបណ្តាលមកពីកំហុស

បច្ចេកទេសដែលទាក់ទងនឹងការចាក់ថ្នាំបង្ការវាជាការសំខាន់ណាស់មិនមែនដើម្បីដាក់ការស្តីបន្ទោសទៅលើបុគ្គលិកនោះទេប៉ុន្តែត្រូវផ្តោតលើបញ្ហាដែលទាក់ទងទៅនឹងប្រព័ន្ធដែលបណ្តាលឱ្យមានហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការនេះនិងជំហានបន្ទាប់ត្រូវកែបញ្ហានិងពង្រឹងប្រព័ន្ធ។អ្វីដែល សំខាន់ក្រុមឆ្លើយតបយ៉ាងឆាប់រហ័សនេះការពារអ្នកផ្តល់សេវាអ្នកថែទាំសុខភាពពីកំហឹងរបស់សាធារណៈជនណាមួយដែលមានសក្តានុពលឬសកម្មភាពមិនបានធានាតាមផ្លូវច្បាប់ ។ ក្នុងការទំនាក់ទំនងជាមួយសហគមន៍គឺមានប្រយោជន៍ក្នុងការអភិវឌ្ឍន៍ទំនាក់ទំនងជាមួយសាធារណៈ(ឪពុកម្តាយ អ្នកដឹកនាំសហគមន៍)និងជុំវិញបុគ្គលិកសុខាភិបាលដែលព័ត៌មានអាចត្រូវបានផ្សព្វផ្សាយយ៉ាងឆាប់រហ័ស ។ ការរក្សាបាននូវការទំនាក់ទំនងជាមួយសហគមន៍គឺមានសារៈសំខាន់តាមរយៈ ការអង្កេត។

## ១.ការទំនាក់ទំនងជាមួយប្រព័ន្ធព័ត៌មាន(Communicating with the media)

ប្រព័ន្ធព័ត៌មាន(កាសែត វិទ្យុនិងទូរទស្សន៍)ដើរតួសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មានទៅមហាជន ។ មុនធ្វើការផ្សព្វផ្សាយត្រូវរៀបចំនូវព័ត៌មានណាដែលមហាជនមានការចំណាប់អារម្មណ៍លើការងារផ្តល់ថ្នាំបង្ការ ។ មហាជនអាចចោទសួរទៅប្រព័ន្ធផ្សព្វផ្សាយអំពីសារៈសំខាន់នៃការចាក់ថ្នាំបង្ការ ការទំនាក់ទំនងនឹងវិជ្ជាជីវៈបុគ្គលិកសុខាភិបាលត្រូវលើកបញ្ហាផលរំខានក្រោយពេលទទួលថ្នាំបង្ការផង។ការផ្សព្វផ្សាយព័ត៌មានត្រូវរៀបចំយ៉ាងណាត្រូវចាក់ផ្សាយយ៉ាងដូចម្តេចម្រាប់ឱ្យមតិសាធារណជនចាប់អារម្មណ៍ដូចជាការផ្តល់ថ្នាំបង្ការប្រកបដោយសុវត្ថិភាពឬរ៉ាក់សាំងមានសុវត្ថិភាពត្រូវជ្រើសរើសមនុស្សដែលត្រូវទៅទំនាក់ទំនងជាមួយប្រព័ន្ធព័ត៌មានដើម្បីកុំឱ្យមានបាតុភាពប៉ះទង្គិចដោយសារគន្លឹះដែលមកពីប្រភពផ្សេងគ្នា ។ ក្នុងប្រទេសកម្ពុជាឯកឧត្តមរដ្ឋមន្ត្រី ឬ ឯកឧត្តមរដ្ឋលេខាធិការនៃក្រសួងសុខាភិបាលជាអ្នកឆ្លើយតបនិងប្រព័ន្ធព័ត៌មាន។

## ១.១.ការរៀបចំសន្និសីទសារព័ត៌មាន (holding a media conference)

**ការផ្សព្វផ្សាយព័ត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយទាំងអស់** មានប្រយោជន៍ដើម្បីឆ្លើយតបទៅនឹងចំណាប់អារម្មណ៍របស់មហាជនសន្និសិទសារព័ត៌មានផ្តល់ដល់អ្នកយកព័ត៌មានចូលយកព័ត៌មានពីហេតុការណ៍ពិត ។ ការផ្សព្វផ្សាយព័ត៌មានមួយបានផ្តល់នូវព័ត៌មានទាំងអស់ក្នុងឱកាសទទួលបានព័ត៌មានលម្អិតនិងដើម្បីបញ្ជាក់ពីការព្រួយបារម្ភរបស់ពួកគេ។ជាធម្មតាការផ្សព្វផ្សាយព័ត៌មានមានផលប្រយោជន៍ល្អណាស់ប៉ុន្តែនៅពេលដែលបរិយាកាសពាក្យចចាមអារាមមិនល្អរីកសាយវាមានសក្តានុពលខ្លាំងណាស់វាអាចធ្វើឱ្យខូចប្រយោជន៍ធំដល់កម្មវិធី ។ ដូចនេះត្រូវរៀបចំសន្និសិទភ្លាមដើម្បីផ្តល់ព័ត៌មានកែតម្រូវទៅនឹងពាក្យចចាមអារាមឱ្យស្របទៅតាមហេតុការណ៍ពិត និងបង្កើតទំនាក់ទំនងជាមួយអ្នករាយការណ៍ព័ត៌មាន។សន្និសិទត្រូវធ្វើនៅពេលណាមួយដែលមានព័ត៌មានស្តីអំពីហេតុការណ៍លំអិតពេញលេញក្រោយពីការធ្វើអង្កេតនិងបញ្ចប់ការសន្និដ្ឋានទើបអាចធ្វើការផ្សព្វផ្សាយព័ត៌មាន។

## ១.២.សេចក្តីថ្លែងការណ៍ (The press statement needs to include)

ការសរសេររឿងរ៉ាវនៃហេតុការណ៍ (ត្រូវប្រើពាក្យដែលប្រជាជនងាយយល់មិនប្រើពាក្យបច្ចេកទេសដូចសេវាសុខភាពឬការងារផ្តល់ថ្នាំបង្ការ) រៀបចំឱ្យបានសមរម្យនូវបរិបទមានន័យថាញែកឱ្យដាច់ហេតុការណ៍ពិតប្រាកដនិងហេតុការណ៍ជាន់ដាន ដូច្នេះជាទូទៅត្រូវរិតត្បិតការសាយភាយហេតុការណ៍មិនល្អដែលប៉ះពាល់ដល់កម្មវិធីផ្តល់ថ្នាំបង្ការ។

- **តើករណីនៃបញ្ហាដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ ជាបញ្ហាកើតឡើងជាបន្តបន្ទាប់ឬក៏ទេ? វាហាក់ បីដូចជាពុំមានករណីកើតឡើងជាបន្តបន្ទាប់ដែលមានការទាក់ទិនជាមួយការផ្តល់ថ្នាំបង្ការទេ។**
- **ចំណុចសំខាន់ដែលត្រូវដោះស្រាយ ( អាស្រ័យតាមដំណាក់កាលដែលរៀបចំផែនការ សកម្មភាពពេលបញ្ចប់ការអង្កេត)**
- **មូលហេតុនៃហេតុការណ៍ (ពេលដែលបានបញ្ជាក់សមហេតុផលពិតប្រាកដ)**
- **កែតម្រូវសកម្មភាពដែលបានកើតឡើងឬបំរុងនឹងកើតមាន។**

## ២.ទំនាក់ទំនងជាមួយឪពុកម្តាយនិងសហគមន៍ ( Communication with parents and community )

ចំណុចសំខាន់ដែលត្រូវចាប់អារម្មណ៍នៅពេលទំនាក់ទំនងជាមួយឪពុកម្តាយអ្នកទទួលវ៉ាក់សាំងនិងសហគមន៍:

- ស្តាប់ដោយយកចិត្តទុកដាក់ពីឪពុកម្តាយនិងការព្រួយបារម្ភរបស់ពួកគេ។
- ធានានិងគាំទ្រដល់ឪពុកម្តាយឬអ្នកទទួលវ៉ាក់សាំងប៉ុន្តែមិនបានធ្វើការសន្យាទេ។
- ជួយឪពុកម្តាយឬអាណាព្យាបាលសម្រាប់ព្យាបាលនៅមន្ទីរពេទ្យបើចាំបាច់។
- ធ្វើការទំនាក់ទំនងជាមួយមាតាបិតាអាណាព្យាបាលទាក់ទងនឹងស្ថានភាពរបស់អ្នកជំងឺ ។
- រៀបចំឯកសារស្តីពីហេតុការណ៍ដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ សម្រាប់ឪពុក ម្តាយនិង សហគមន៍។
- ផ្តល់ព័ត៌មានពីហេតុការណ៍ដែលអាចកើតមានក្រោយផ្តល់ថ្នាំបង្ការដល់ឪពុកម្តាយនិងរបៀបដោះស្រាយ។
- ប្រាស្រ័យទាក់ទងបន្តជាមួយឪពុកម្តាយនិងសហគមន៍នៅក្នុងអំឡុងពេលការអង្កេតដើម្បីធានាការយល់ដឹងពីផលប្រយោជន៍នៃការចាក់ថ្នាំបង្ការ។
- កុំស្តីបន្ទោសបុគ្គលិកសុខាភិបាលប៉ុន្តែផ្តោតលើការកែតម្រូវនិងគុណភាពនៃប្រព័ន្ធផ្តល់ថ្នាំបង្ការ

## ៣. ការទំនាក់ទំនងជាមួយបុគ្គលិកសុខាភិបាល (Communication with health staf)

ការប្រាស្រ័យទាក់ទងជាមួយបុគ្គលិកសុខាភិបាលទាំងអស់ដែលពាក់ព័ន្ធ (មណ្ឌលសុខភាពស្រុកប្រតិបត្តិមន្ទីរពេទ្យបង្អែកមន្ទីរសុខាភិបាលនិង កម្មវិធីជាតិផ្តល់ថ្នាំបង្ការ) ។

- ធានាដល់ទំនុកចិត្តរបស់បុគ្គលិកនៅលើកម្មវិធីជាតិផ្តល់ថ្នាំបង្ការគុណភាពនៃវ៉ាក់សាំង។
- ធានាបង្កើនចំណេះដឹងសមត្ថភាពជំនាញដល់បុគ្គលិកក្នុងការអនុវត្តសកម្មភាព។

- កុំស្តីបន្ទោសបុគ្គលិកសុខាភិបាលប៉ុន្តែផ្តោតលើការកែតម្រូវនិងគុណភាពនៃប្រព័ន្ធផ្តល់ថ្នាំបង្ការ
- រក្សាភាពទាន់សម័យនៅលើដំណើរការអង្កេតដោយអនុវត្តទៅតាមគោលការណ៍ណែនាំនិងការរកឃើញពិតប្រាកដ។

## ៤. ដំណោះស្រាយបញ្ហាឱ្យចំបញ្ហាដែលកើតឡើង (Fixing the problem)

បើសិនជាមានកំហុសបច្ចេកទេសកើតឡើងនឹងត្រូវបានកែតម្រូវតាមរយៈការត្រួតពិនិត្យសម្ភារបច្ចេកទេសការដឹកជញ្ជូនការទុកដាក់ ។ល។ ហើយធានាថាមិនមានការកើតមានជាថ្មីទៀតទេ ។ បើសិនបញ្ហាទាក់ទងជាមួយវ៉ាក់សាំងអាចនាំទៅដល់ការដកចេញលេខឡូត៍នៃប្រភពរោងចក្រ ឬ ការផ្លាស់ប្តូរការផ្គត់ផ្គង់វ៉ាក់សាំង។

ទោះបីយ៉ាងណាការសម្រេចចិត្តបែបណាមួយគួរតែត្រូវធ្វើឡើងប្រសិនបើការអង្កេតត្រូវបានបញ្ជាក់ថាមានមូលហេតុច្បាស់លាស់ជាមួយថ្នាំវ៉ាក់សាំងដែលបានផ្តល់ឱ្យនិងប្រតិកម្ម ។ ការដកឬការព្យួរដោយគ្មានភស្តុតាងច្បាស់លាស់មិនត្រូវបានលើកទឹកចិត្តឱ្យអនុវត្តទេដែលវាអាចប៉ះពាល់ដល់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ ។ សម្រាប់ហេតុការណ៍ផ្សេងទៀតភារកិច្ចចម្បងគឺការប្រាស្រ័យទាក់ទងដើម្បីជៀសវាងការស្តីបន្ទោសដោយសន្មតមិនពិតណាមួយ។

សម្រាប់ហេតុការជាន់ដានការងារចម្បងគឺការទំនាក់ទំនងឱ្យបានល្អរវាងអ្នកអនុវត្តន៍ការងារនិងសហគមន៍ជៀសវាងការភាន់ច្រលំស្តីបន្ទោសដែលមិនបានកំណត់មូលហេតុឱ្យបានច្បាស់លាស់ ។ តារាងទី៥ចំណុចសំខាន់សម្រាប់ឆ្លើយតប។

### តារាងទី៥៖ឆ្លើយតបទៅសកម្មភាពខាងលើត្រូវអនុវត្តឱ្យបានចប់សព្វគ្រប់

| ប្រភេទនៃហេតុការណ៍ | សកម្មភាពនៃការឆ្លើយតប |
|---|---|
| **ប្រតិកម្មនៃវ៉ាក់សាំង**<br>Vaccine reaction | បើសិនប្រតិកម្មវ៉ាក់សាំងមានអត្រាខ្ពស់ជាងការរំពឹងទុកនៃលក្ខខណ្ឌវ៉ាក់សាំងដែលរោងចក្របានផ្តល់ព័ត៌មានឱ្យត្រូវ ពិគ្រោះជាមួយអង្គការសុខភាពពិភពលោកនិងមូលនិធិសម្រាប់កុមារ នៃ អង្គការសហប្រជាជាតិ ដើម្បីពិនិត្យ<br>• បញ្ឈប់ប្រើឡូតិ៍វ៉ាក់សាំងដែលបង្កឱ្យមានបញ្ហា<br>• ការផ្លាស់ប្តូររោងចក្រឬត្រួតពិនិត្យគុណភាព<br>• ទទួលវ៉ាក់សាំងពីរោងចក្រផ្សេងទៀត |

| | |
|---|---|
| **ប្រតិកម្មដែលមានការទាក់ទងទៅនឹងកំហុសបច្ចេកទេសនៅពេលផ្តល់ថ្នាំបង្ការ**<br>Immunization error related event (Programme error): | ការកែតម្រូវមូលហេតុខុសឆ្គងដែលអាចមាន មួយ ឬ ច្រើនដូចខាងក្រោម ៖<br>• កែលម្អការដឹកជញ្ជូនសម្រាប់ផ្គត់ផ្គង់វ៉ាក់សាំង<br>• កែលម្អរបៀបគ្រប់គ្រងមណ្ឌលសុខភាព<br>• បណ្តុះបណ្តាលបុគ្គលិកមណ្ឌលសុខភាព<br>• បង្កើនការត្រួតពិនិត្យដោយការគាំទ្រអ្វីក៏ដោយត្រូវចាត់វិធានការវាសំខាន់ណាស់ក្នុងការរំលឹកឡើងវិញនៅពេលត្រួតពិនិត្យនៅថ្ងៃក្រោយដើម្បីកំហុសទាំងនោះត្រូវបានកែតម្រូវ។ |
| **ហេតុការណ៍ជាន់ដាន**<br>Coincidental | ការងារជាចម្បងគឺត្រូវមានការទំនាក់ទំនងគ្នាដើម្បីឱ្យប្រាកដថាៈ ប្រជាជនត្រូវបានណែនាំឱ្យយល់ពីហេតុការណ៍ជាន់ដាន។ ការទំនាក់ទំនងនេះមានការលំបាកឱ្យគេជឿជាក់ ហើយទៀមទា ធ្វើឱ្យអស់ពីសមត្ថភាព នៅពេលធ្វើការផ្សព្វផ្សាយឱ្យគេជឿជាក់ថាហេតុការណ៍ដែលកើតឡើងនេះមិនបណ្តាលមកពីការផ្តល់ថ្នាំបង្ការទេ។ ពេលខ្លះអាចមានប្រយោជន៍ណាស់ក្នុងការចូលរួមអង្កេត ដោយអ្នកជំនាញដើម្បី ធានាថាហេតុការណ៍នេះ ពិតប្រាកដ ជាការជាន់ដានមែន។ សក្តានុពលនៃហេតុការណ៍ជាន់ដានធ្វើ ឱ្យប៉ះពាល់ដល់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ តាមរយៈការសន្មត់មិន ពិតប្រាកដគឺមានច្រើនណាស់។ |

| | |
|---|---|
| **ហេតុការណ៍ទាក់ទងនឹងការភ័យខ្លាចការចាក់ថ្នាំបង្ការ**<br>**Immunization anxiety related events** | អាស្រ័យទៅលើធម្មជាតិនៃព្រឹត្តិការណ៍ វិសាលភាពរបស់វាទិសដៅរបស់វា និង ថាតើវាគឺកំពុងបន្តឬមួយយ៉ាងណា ទោះបីជាយ៉ាងការអង្កេតបន្ថែមទៀតដោយអ្នក ជំនាញមួយដែលអាចត្រូវបានត្រូវការជាចាំបាច់បំផុត ។ យ៉ាងណាក៏ដោយ ដូចជាហេតុការណ៍ជាន់ដានដែរការទំនាក់ទំនងគឺជាភារកិច្ចដ៏សំខាន់ដើម្បីធានាថាសាធារណជន យល់ថាហេតុការណ៍នេះ គឺភាគច្រើនដោយសារចិត្តសាស្ត្រហើយឆ្លើយតបទៅនឹងប្រតិកម្មដោយការចាក់វ៉ាក់សាំងជាជាងដោយសារ វ៉ាក់សាំង។ បញ្ហានេះគឺកើតមានជាទូទៅក្នុងចំណោមមនុស្សវ័យជំទង់។ |

# ទំរង់របាយការណ៍ករណីដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិសាសនាព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**
មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក
កម្មវិធីជាតិផ្តល់ថ្នាំបង្ការ

## របាយការណ៍ស្តីពីករណីហេតុការណ៍មិនល្អដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ

មណ្ឌលសុខភាព............ ស្រុកប្រតិបត្តិ............ ខេត្ត/ក្រុង............

ឈ្មោះករណីAEFI............ ភេទ: ប្រុស☐ស្រី☐ អាយុ...... ថ្ងៃខែឆ្នាំកំណើត....../....../......

ឪពុកឈ្មោះ............ ឈ្មោះហៅក្រៅ............ មុខរបរ............ លេខទូរស័ព្ទ............

ម្តាយឈ្មោះ............ ឈ្មោះហៅក្រៅ............ មុខរបរ............ លេខទូរស័ព្ទ............

ក្នុងករណីមិនមានឪពុក-ម្តាយសូមសរសេរឈ្មោះអាណាព្យាបាល

ឈ្មោះអាណាព្យាបាល............ ឈ្មោះហៅក្រៅ............ មុខរបរ............ លេខទូរស័ព្ទ............

អាសយដ្ឋាន:ផ្ទះ N°...... ផ្លូវ...... ក្រុម...... ភូមិ............ ឃុំ............ ស្រុក............ ខេត្ត............

**មុខវ៉ាក់សាំងដែលកុមារ/ស្រ្តីបានទទួលមុនពេលមានហេតុការណ៍មិនល្អ:**

| វ៉ាក់សាំងដែលបានផ្តល់ | របៀបផ្តល់ | កន្លែងផ្តល់ | លេខឡូត៍វ៉ាក់សាំង | ពេងចក្រ | ថ្ងៃខែឆ្នាំផុតកំណត់ប្រើប្រាស់ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |

ថ្ងៃខែឆ្នាំផ្តល់វ៉ាក់សាំង:....../....../...... ម៉ោង............ ព្រឹក☐ល្ងាច☐

ថ្ងៃខែឆ្នាំកើតមានហេតុការណ៍មិនល្អក្រោយផ្តល់វ៉ាក់សាំង:....../....../...... ម៉ោង...... ព្រឹក☐ល្ងាច☐

ទីកន្លែងផ្តល់វ៉ាក់សាំង:ភូមិ............ មណ្ឌលសុខភាព............ មន្ទីរពេទ្យ............

គ្លីនីកឯកជន............ កន្លែងផ្សេងទៀតសូមបញ្ជាក់............

ឈ្មោះអ្នកផ្តល់វ៉ាក់សាំង:១............ ២............ ៣............

**ហេតុការណ៍មិនល្អដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ:**

- ☐ប្រតិកម្មធ្ងន់ធ្ងរនៅកន្លែងចាក់៖ មានរយៈពេលយូរលើស៣ថ្ងៃ☐ រាលដាលដល់សន្លាក់ដែលនៅឆ្ងាយ ☐
- ☐ ប្រកាច់មានគ្រុនក្តៅ ៖ ☐ គ្មានគ្រុនក្តៅ ☐
- ☐ ការគុំខ្ទុះ (abces)
- ☐ ការបង្កពេគរាលដាល Sepsis
- ☐ អាណាហ្វីឡាកស៊ី Anaphylaxis
- ☐គ្រុនក្តៅលើសពី៣៨ អង្សាសេ
- ☐ផ្សេងៗ (សូមរៀបរាប់)............

តើអ្នកជំងឺមានបានទៅសំរាកពេទ្យដែរឬទេ ? បាទ☐ទេ☐

បើបានសំរាកពេទ្យថ្ងៃខែឆ្នាំចូលពេទ្យ....../....../...... ថ្ងៃខែឆ្នាំចេញពីពេទ្យ....../....../......

ឈ្មោះមន្ទីរពេទ្យ............ ឈ្មោះគ្រូពេទ្យព្យាបាល............

**ការវិនិច្ឆ័យអ្នកជំងឺ:**

☐រស់: ប្រសិនបើរស់ បានជាសះស្បើយ☐បានជាសះស្បើយ តែមានពិការភាព☐ មិនបានធូស្រាយទេ☐

☐ស្លាប់: បើសិនស្លាប់ថ្ងៃខែឆ្នាំស្លាប់....../....../......

ថ្ងៃខែឆ្នាំធ្វើរបាយការណ៍....../....../......

**អ្នកធ្វើរបាយការណ៍**

# ជំពូកទី៥៖

# ការណែនាំអំពីរបៀបកត់ត្រា

# ការណែនាំពីរបៀបកត់ត្រា

## ១.ការបំពេញប័ណ្ណលឿង ( ប័ណ្ណសុខភាពកុមារ ) (ឧបសម្ព័ន្ធ ៦-៧-៨)

ការបំពេញប័ណ្ណលឿងគ្រប់ចំណុចមានសារៈសំខាន់ណាស់ពីព្រោះវាជាព័ត៌មានសំរាប់បុគ្គលិកសុខាភិបាលនិងអាណាព្យាបាលរបស់កុមារក្នុងការត្រួតពិនិត្យ តាមដានសុខភាពរបស់កុមារ ។ យើងត្រូវបំពេញតាមលំដាប់លំដោយដូចខាងក្រោមៈ

- **ព័ត៌មានទូទៅ ៖**

- នាមកុមារ ៖ សរសេរឈ្មោះពេញ (នាមត្រកូលនិងនាមកុមារ)
- លេខរៀងកុមារ ៖ត្រូវតែស្របតាមលេខរៀងដែលមាននៅក្នុងបញ្ជីផ្តល់ថ្នាំបង្ការកុមារ
- ភេទកុមារ ៖ ដោយគូស ភេទ ប្រុស ឬ ស្រី អោយស្របទៅតាមភេទរបស់កុមារ។
- ថ្ងៃខែឆ្នាំកំណើត និងទំងន់ពេលកើត ៖ ត្រូវបំពេញថ្ងៃខែឆ្នាំ (...../....../.....)
- ឈ្មោះម្តាយ ៖ ដោយសរសេរឈ្មោះពេញលេញ (នាមត្រកូល និង នាម)និង ឈ្មោះហៅក្រៅ
- ឈ្មោះឪពុក ៖ ដោយសរសេរឈ្មោះពេញលេញ (នាមត្រកូល និង នាម) និង ឈ្មោះហៅក្រៅ
- ឈ្មោះអ្នកថែទាំកុមារ ៖ ដោយសរសេរឈ្មោះពេញលេញ (នាមត្រកូល និង នាម) (បើមាន)
- អាស័យដ្ឋានបច្ចុប្បន្នរបស់គ្រួសារ ៖ ត្រូវបំពេញអោយបានត្រឹមត្រូវ (ផ្ទះលេខ ផ្លូវ ឈ្មោះ ភូមិ, ឃុំ មណ្ឌលសុខភាព ស្រុកប្រតិបត្តិ ស្រុករដ្ឋបាល និង ខេត្ត )

- **វ៉ាក់សាំងដែលបានផ្តល់អោយកុមារ ៖**

- វ៉ាក់សាំង Hep $B_0$, BCG, Polio, DPT-Hep-Hib,PCV,JE និង MR ត្រូវបំពេញ ថ្ងៃខែដែលបានផ្តល់ឲ្យបានច្បាស់ (ថ្ងៃ,ខែ,ឆ្នាំ....../....../.......) ។
- វ៉ាក់សាំងផ្សេងៗ យើងត្រូវបំពេញនៅត្រង់កន្លែងការចាក់ថ្នាំបង្ការជំងឺ ផ្សេងៗ ដោយសរសេរពាក្យឈ្មោះវ៉ាក់សាំង នៅពីមុខ និង ថ្ងៃ ខែ ឆ្នាំ ទទួលវ៉ាក់សាំងខាងក្រោយ ។

ឧទាហរណ៍ ៖

| |
|---|
| ការចាក់ថ្នាំបង្ការជំងឺផ្សេងៗ |
| ……………… |
| ២៥/០៩/០៩............................................................... |
| ................................................................... |

- វ៉ាក់សាំង PCV យើងត្រូវបំពេញតាមលំដាប់លំដោយដូច DPT-HepB Hib ដែរ  រួចសរសេរ ថ្ងៃ ខែ ឆ្នាំ ទទួលវ៉ាក់សាំង ។

ឧទាហរណ៍:

| |
|---|
| ការផ្ដល់ថ្នាំបង្ការជំងឺរលាកសួតនិងរលាកស្រោមខួរក្បាលដោយភ្នៃម៉ូកូក |
| ថ្ងៃចាក់លើកទី១   PCV1   .២៥/០៩/16.......... |
| ថ្ងៃចាក់លើកទី២   PCV2   .២៥/១០/16........... |
| ថ្ងៃចាក់លើកទី៣   PCV3   .២៥/១១/16........... |

## ត្រូវបំពេញជាដាច់ខាតរាល់ពេលផ្ដល់ថ្នាំបង្ការ ៖

- ឈ្មោះ មណ្ឌលសុខភាព
- ឈ្មោះបុគ្គលិកផ្ដល់ថ្នាំបង្ការ
- ហត្ថលេខា របស់បុគ្គលិកផ្ដល់ថ្នាំបង្ការ

## ថ្ងៃណាត់ជួបលើកក្រោយ ៖

- ត្រូវសរសេរ និង បញ្ជាក់ ថ្ងៃ ខែ ឆ្នាំ និង គោលបំណងដែលអាណាព្យាបាលត្រូវយកកុមារមកទទួលថ្នាំបង្ការ លើកបន្ទាប់ឲ្យបានច្បាស់។

## ២. **ការគូសក្នុងរបាយការណ៍ក្បាលម្ចុល៖(របាយការណ៍ប្រចាំខែ)** (ឧបសម្ព័ន្ធ ៩-១០)

***កម្មវិធីបានយកគំរូរបាយការណ៍ថ្មីមួយដែលមានលក្ខណ:ស្រដៀងនិងគំរូរបាយការណ៍ចាស់ដោយគ្រាន់តែបន្ថែម ៖***

- ចំនួនកុមារដែលបានទទួលថ្នាំបង្ការ "JE"ត្រូវចុះនៅត្រង់ជួរបន្ថែមបន្ទាប់ពីជួររបស់ វ៉ាក់សាំងកញ្ជ្រឹល
- ***លទ្ធផលវ៉ាក់សាំង*** "DTP-HepB" ***ទៅជា*** "DTP-HepB-Hib" ***និងមានបន្ថែម លទ្ធផលវ៉ាក់សាំង*** "JE"

## ៣. **ការកត់ត្រាលើបញ្ជីផ្ដល់ថ្នាំបង្ការ ៖** (ឧបសម្ព័ន្ធ ១១)

- ចំណែកឯការកត់ត្រាការផ្ដល់វ៉ាក់សាំង DTP-HepB-Hib នៅលើបញ្ជីផ្ដល់ថ្នាំបង្ការវិញ គឺយើងត្រូវបំពេញដូចធម្មតាដោយគ្រាន់តែសរសេរបន្ថែមថា " Hib " នៅផ្នែកខាងលើ និង ខាងស្ដាំ នៃថ្ងៃ ខែឆ្នាំ ផ្ដល់វ៉ាក់សាំង "DTP-HepB " ប៉ុណ្ណោះ។ ឧទាហរណ៍: ២៥ / ០១ / ២០១០
- ការកត់ត្រាការផ្ដល់វ៉ាក់សាំង JE នៅលើបញ្ជីផ្ដល់ថ្នាំបង្ការ ត្រូវកត់ត្រាថ្ងៃខែឆ្នាំ ផ្ដល់វ៉ាក់សាំង ***"JE"*** នៅត្រង់ជួរបញ្ឈរផ្សេងៗ ។

# ជំពូកទី៦៖

## តាមដាន-វាយតំលៃអត្រាគ្របណ្តប់នៃការផ្តល់ថ្នាំបង្ការ និងការតាមដានស្រាវជ្រាវជំងឺដែលអាចការពារបានដោយវ៉ាក់សាំង

# ការតាមដាន - វាយតំលៃលទ្ធផលអន្តរាគមន៍បន្ទាប់នៃការផ្តល់ថ្នាំបង្ការ

## ១).គោលបំណងនៃការវាយតំលៃគឺដើម្បី ៖

- វាស់ស្ទង់កំរិតជោគជ័យលើការងារផ្តល់ថ្នាំបង្ការនៅក្នុងតំបន់គ្របដណ្តប់របស់មណ្ឌលសុខភាព
- ស្រាវជ្រាវនិងកំណត់មូលហេតុនៃបញ្ហាដែលត្រូវធ្វើការដោះស្រាយ ដើម្បីធ្វើអោយប្រសើរឡើងនូវការអនុវត្តការងារផ្តល់ថ្នាំបង្ការ ។
- ធ្វើការពិនិត្យផែនការកម្មវិធីឡើងវិញផ្អែកលើតម្រូវការជាក់ស្តែង
- ដើម្បីស្វែងរកការគាំទ្រចាំបាច់ពីសហគមន៍ ថ្នាក់លើ និង អង្គការដៃគូ

## ២). ដំណើរការនៃការវាយតំលៃ ៖

១) តើអ្នកណាជាអ្នកទទួលបន្ទុកក្នុងការវាយតំលៃ ?

- ប្រធាន និង បុគ្គលិកទទួលបន្ទុកកម្មវិធីផ្តល់ថ្នាំបង្ការនៅថ្នាក់មណ្ឌលសុខភាព
- អ្នកស្ម័គ្រចិត្តភូមិ តំណាងសហគមន៍ និង អាជ្ញាធរដែនដី
- អ្នកអភិបាល (ថ្នាក់ជាតិ ខេត្ត និង ស្រុកប្រតិបត្តិ)

២) តើពេលណាខ្លះដែលយើងត្រូវធ្វើការវាយតំលៃ ?

- ពេលកំពុងអនុវត្តន៍
- វាយតំលៃជាប្រចាំ (ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ )
- ពេលប្រជុំជាមួយតំណាងសហគមន៍
- ពេលដែលទទួលព័ត៌មានត្រឡប់ពីអ្នកអភិបាលគ្រប់ថ្នាក់

៣) តើឯកសារអ្វីខ្លះដែលថ្នាក់មណ្ឌលសុខភាពត្រូវយកមកធ្វើការតាមដាននិងវាយតំលៃ ?

- ប័ណ្ណសុខភាពកុមារ(ប័ណ្ណលឿង) / ប័ណ្ណតេតាណុល
- បញ្ជីផ្តល់ថ្នាំបង្ការ (ស្ត្រី និង កុមារ)
- គំរូរបាយការណ៍ (របាយការណ៍ក្បាលម្ហូល របាយការណ៍ (ឧបសម្ព័ន្ធ ១២)

- ក្រាហ្វិកតាមដានអត្រាគ្របដណ្តប់
- របាយការណ៍ និង តារាងតាមដានស្រាវជ្រាវជំងឺរបស់កម្មវិធី
- សាលាកបត្រ័ឃ្លាំង របាយការណ៍សម្ភារ វ៉ាក់សាំង តារាងតាមដានសីតុណ្ហភាពទូទឹកកក
- តារាងតាមដានអត្រាខាតបង់វ៉ាក់សាំង
- សៀវភៅក្រាំងមាស (ព័ត៌មានដែលបានកត់ត្រាដោយអ្នកអភិបាល)
- បញ្ជីសំរង់ស្ត្រីមានផ្ទៃពោះនិងទារកកើតថ្មី

## ៣) ជំហាននៃការវាយតំលៃ

១) មុនពេលបើកទិវាផ្តល់ថ្នាំបង្ការ, ពេលកំពុងអនុវត្តទិវា និង ពេលបិទទិវា ៖

១).១. មុនពេលចុះផ្តល់ថ្នាំបង្ការ បុគ្គលិកមណ្ឌលសុខភាពត្រូវៈ

- ធ្វើការតាមដានការផ្តល់ព័ត៌មានស្តីពីសកម្មភាពចុះផ្តល់សេវាមូលដ្ឋាន ដើម្បីប្រាកដថាក្រុមទ្រទ្រង់ សុខភាពភូមិ បានទទួល និង ផ្តល់ព័ត៌មានដល់សហគមន៍ (ប្រជាជនចំណុច ពេលវេលា ទីកន្លែង )
- ប្រាកដថាមានសម្ភារ វ៉ាក់សាំងគ្រប់គ្រាន់សំរាប់សកម្មភាពចុះផ្តល់សេវាមូលដ្ឋាន

១).២.ពេលកំពុងបើកទិវាផ្តល់ថ្នាំបង្ការបុគ្គលិកមណ្ឌលសុខភាពត្រូវៈ

- ធ្វើការផ្ទៀងផ្ទាត់ជាប្រចាំរវាងប័ណ្ណផ្តល់ថ្នាំបង្ការ បញ្ជីផ្តល់ថ្នាំបង្ការ និង របាយការណ៍ក្បាលម្ភុល ដើម្បីប្រាកដថា ការកត់ត្រាបានត្រឹមត្រូវ
- ពិនិត្យជាប្រចាំលើបច្ចេកទេសផ្តល់ថ្នាំបង្ការដល់កុមារ និង ស្ត្រី

១).៣.នៅមុនពេលចប់ទិវាផ្តល់ថ្នាំបង្ការបុគ្គលិកមណ្ឌលសុខភាពគប្បីធ្វើការ ផ្ទៀងផ្ទាត់ចំនួនកុមារ/ស្ត្រីដែលត្រូវផ្តល់ និងបានទទួលក្នុងទិវានិមួយៗ ដើម្បីប្រាកដថាប្រជាជនចំណុចបានមកទទួលថ្នាំបង្ការ គ្រប់ៗគ្នា

២). ការវាយតំលៃលទ្ធផលផ្តល់ថ្នាំបង្ការ ៖

២).១.ផ្ទៀងផ្ទាត់របាយការណ៍ប្រចាំខែ ៖

មុនពេលផ្ញើរបាយការណ៍HC1ទៅស្រុកប្រតិបត្តិបុគ្គលិកមណ្ឌលសុខភាពត្រូវ ៖

- ផ្ទៀងផ្ទាត់ចំនួនក្នុងបញ្ជីរផ្តល់ថ្នាំបង្ការជាមួយនិងរបាយការណ៍ក្បាលម្ភុល
- ផ្ទៀងផ្ទាត់របាយការណ៍ក្បាលម្ភុលជាមួយរបាយការណ៍HC1

២).២. ក្រាហ្វិកតាមដានអត្រាគ្របដណ្តប់វ៉ាក់សាំង ៖

២).២.១.រាល់ពេលដើមឆ្នាំអ្នកត្រូវរៀបចំក្រាហ្វិកចំនួន ៦ សន្លឹកគឺ ៖

- បេសេហ្សេ-រ៉ូវ៉ាក់ -ចាក់គ្រប់ មួយសន្លឹក (ឧបសម្ព័ន្ធ ១៣)ឬ បេសេហ្សេ-រ៉ូវ៉ាក់ -ចាក់គ្រប់-ជេអ៊ី មួយសន្លឹក (ចំពោះ ខេត្តដែលបញ្ចូលវ៉ាក់សាំងជេអ៊ី)(ឧបសម្ព័ន្ធ ១៤)
- ប៉ូលីយ៉ូទី១-ប៉ូលីយ៉ូទី៣ មួយសន្លឹក (ឧបសម្ព័ន្ធ ១៥)

- DTP-HepB-Hib 1- DTP-HepB-Hib 3 និង HepB 0 មួយសន្លឹក (ឧបសម្ព័ន្ធ ១៦) ឬ DTP-HepB-Hib 1-DTP-HepB-Hib 3-ភាពស៊ាំ នឹងជំងឺតេតាណូស ពីកំណើត (PAB) និង មួយសន្លឹក (ចំពោះ ខេត្ត ដែលបញ្ចូល PAB)(ឧបសម្ព័ន្ធ ១៧)
- តេតាណុលទី១-តេតាណុលទី២ និង តេតាណុលទី២+ លើស្ត្រីមាន ផ្ទៃពោះមួយសន្លឹក (ឧបសម្ព័ន្ធ ១៨)

### ២).២.២.ការរៀបចំតារាងក្រាហ្វិក ៖

- ដំបូងត្រូវរកចំនួនប្រជាជនចំណុចប៉ាន់ស្មានប្រចាំឆ្នាំនិងប្រចាំខែក្នុងមណ្ឌលសុខភាពរបស់អ្នក
- សរសេរតួលេខប្រជាជនចំណុចនៅផ្នែកខាងឆ្វេង
- សរសេរនៅជ្រុងឆ្វេងខាងក្រោមតារាង ដោយរាប់ពីក្រោមឡើងលើ ៖
    - នៅខ្សែបន្ទាត់ទទឹងទី១ត្រូវសរសេរតួលេខសំរាប់ ប្រជាជនចំណុច ក្នុងមួយខែ
    - នៅខ្សែបន្ទាត់ទទឹងទី២ត្រូវសរសេរតួលេខសំរាប់ប្រជាជនចំណុច ក្នុង២ខែ
    - នៅខ្សែបន្ទាត់ទទឹងទី៣ត្រូវសរសេរតួលេខ សំរាប់ប្រជាជនចំណុច ក្នុង៣ខែ និងបន្ត
    - សរសេរចំនួនប្រជាជនចំណុចក្នុង៤ខែរហូតដល់១២ខែនៅលើខ្សែបន្ទាត់ទទឹងនីមួយៗ
    - នៅខ្សែបន្ទាត់ទទឹងទី១២ត្រូវសរសេរតួលេខសំរាប់ប្រជាជន ចំណុច ក្នុង ១២ ខែ
- គូសបន្ទាត់ផែនការឆ្នាំតាមមុខវ៉ាក់សាំងនិមួយៗដោយយកផ្នែកខាងស្តាំនៃតារាងជាមាត្រដ្ឋានភាគរយ

### ២).២.៣.បំពេញតារាង ៖

- គូសខ្សែបន្ទាត់តំណាងអោយវ៉ាក់សាំងនិមួយៗខុសៗគ្នា (ខុសពណ៌ឬខុសកំរាស់ស្តើង)
- នៅខាងក្រោមតារាងនេះមានបន្ទាត់ជាច្រើនហើយត្រូវមាន ២ ជួរសំរាប់ វ៉ាក់សាំង និមួយៗ
- ជួរលើសំរាប់វ៉ាក់សាំងនិមួយៗនៅចំនួនក្មេងដែលបានផ្តល់ក្នុងមួយខែ(លទ្ធផលដូសនិមួយៗដែល បានទទួលក្នុងមួយខែ)
- ជួរបន្ទាប់ជាជួរសរុបបន្តបន្ទាប់នៃចំនួនកុមារដែលបានផ្តល់ ។ គឺជាចំនួនដែលបានមកដោយបូកពីខែមុនៗ រហូតមកដល់ខែចុងក្រោយ ។

### ២).២.៤. គូសខ្សែក្រាហ្វិក

- ចុចសំគាល់លើតារាងអោយត្រូវតាមជួរខែនិមួយៗ នូវចំនួនកុមារដែល សរុបបន្តដែលបានទទួលវ៉ាក់សាំងនីមួយៗ ដោយប្រៀបធៀបជាមួយ តួលេខ ដែលដំណាងអោយកុមារចំណុចក្នុងជួរបញ្ឈរ
- អ្នកគូសបន្តភ្ជាប់ពីចំណុចចុងខែមុន ទៅចុងខែមួយបន្ទាប់ទៀត

### ២).២.៥.ការអានតារាងត្រួតពិនិត្យអត្រាគ្របដណ្តប់នៃវ៉ាក់សាំង

ពិនិត្យលទ្ធផលទទួលបានមកទល់ថ្ងៃនេះ ៖

- ផ្នែកខាងឆ្វេងនៃតារាងតំណាងអោយចំនួនជួរសរុបដែលបានផ្តល់អោយកុមារតាំងពីដើមឆ្នាំដល់ចុងខែណាមួយ
- ផ្នែកខាងស្តាំនៃតារាងតំណាងអោយលទ្ធផលទទួលបានជាភាគរយ ។

- ចូរអ្នកធ្វើការប្រៀបធៀបខ្សែក្រាហ្វិករបស់អ្នកជាមួយនឹងបន្ទាត់ផែនការ
- នៅជិតឬពីលើបន្ទាត់ផែនការបានន័យថាកម្មវិធីរបស់អ្នកសំរេចជោគជ័យបានល្អ
- តែបើនៅពីក្រោមឆ្ងាយពីបន្ទាត់ផែនការបានន័យថាអ្នកមិនបានទទួលបានជោគជ័យទ ។ ចូរអ្នកធ្វើការប្រៀបធៀបខ្សែក្រាហ្វិកវ៉ាក់សាំងដើម្បីរកអត្រាបោះបង់
- បេសេហ្សេ - MR- ចាក់គ្រប់-ជេអ៊ី - ប៉ូលីយ៉ូទី១-ប៉ូលីយ៉ូទី៣
- DTP-HepB-Hib1-3 -HepB 0- PAB
- តេតាណុលទី១-តេតាណុលទី២-TT2+ លើស្ត្រីមានផ្ទៃពោះ
- បើខ្សែបន្ទាត់ទាំង២នេះវាស្ថិតនៅជិតគ្នាបានន័យថា អ្នកពុំមានបញ្ហាលើអត្រាបោះបង់ឡើយ ប៉ុន្តែបើខ្សែបន្ទាត់ទាំង២នេះវាស្ថិតឆ្ងាយពីគ្នាពេកបានន័យថា អ្នកមានបញ្ហាលើអត្រាបោះបង់ហើយ ។

## ៤). គណនាអត្រាគ្របដណ្តប់និងអត្រាបោះបង់

ដើម្បីគណនាអត្រាគ្របដណ្តប់អ្នកត្រូវដឹង ៖
- ប្រជាជនសរុបក្នុងតំបន់និមួយៗ
- កុមារអាយុតិចជាងមួយឆ្នាំដែលបានផ្តល់ថ្នាំបង្ការរយៈពេលកន្លងមកចំពោះវ៉ាក់សាំង Hep B, BCG , DTP-HepB-Hib, PCV,IPV , OPV, MR, JE ។
- ចំពោះស្ត្រីមានផ្ទៃពោះដែលបានផ្តល់ថ្នាំបង្ការ រយៈកន្លងមកចំពោះ TT1, TT2, TT3, TT4, TT5
- បន្ថែមពីលើនេះទៀតយើងត្រូវសួររកបញ្ជីសំរង់ទារកកើតថ្មី ដែលមាននៅ តាមភូមិដើម្បីបញ្ជាក់អោយបានច្បាស់ថាគ្រប់ទារកដែលបានកើត មក ថ្មីទាំងអស់បានមកទទួលថ្នាំបង្ការ ហើយរឺនៅ។

### ក ). គណនាអត្រាគ្របដណ្តប់ ៖

សំរាប់វ៉ាក់សាំង បេសេហ្សេ DTP-HepB-Hib, ប៉ូលីយ៉ូ ,MR, ជេអ៊ី និង TT2 ស្ត្រីមានផ្ទៃពោះ ៖

| | | |
|---|---|---|
| អត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំង = | ចំនួនដូសកុមារអាយុក្រោម១ឆ្នាំបានទទួល(....) / ចំនួនកុមារចំណុច | x ១០០ |
| អត្រាគ្របដណ្តប់TT2ស្ត្រីមានផ្ទៃពោះ = | លទ្ធផល TT2 នៃស្ត្រីមានផ្ទៃពោះ(ទី......) / ចំនួនស្ត្រីមានផ្ទៃពោះរំពឹងទុក | x ១០០ |

## ខ). អត្រាបោះបង់ (BCG-Rouvax-JE, DTP-HepB-Hib 1 –3 , TT1-TT2 ……… )

| | | | |
|---|---|---|---|
| អត្រាបោះបង់ BCG - MR = | ចំនួនដូស BCG - MR1 | ចំនួនដូស BCG | x ▯ ▯ ▯ |
| អត្រាបោះបង់ DTP-HepB-Hib1-3 = | ចំនួនដូស DTP-HepB-Hib1- 3 | ចំនួនដូស DTP-HepB-Hib1 | x ▯ ▯ ▯ |
| អត្រាបោះបង់ TT1-TT2 = | ចំនួនដូស TT1-TT2 | ចំនួនដូស TT1 | x ▯ ▯ ▯ |

ឧទាហរណ៍ ៖

នៅមណ្ឌលសុខភាព ( ក) មានកុមារអាយុក្រោមមួយឆ្នាំចំនួន ១២០នាក់ សំរាប់ឆ្នាំ ២០១៥ ហើយនៅខែ កក្កដា លទ្ធផលសរុបនៃការផ្តល់ថ្នាំបង្ការរយៈពេល ៦ខែ គឺវ៉ាក់សាំង BCG ទទួលបាន៥៣នាក់និងវ៉ាក់សាំង MR1 ទទួលបាន៤៥នាក់ ។

- តើអត្រាគ្របដណ្តប់វ៉ាក់សាំង BCG និង MR1 មានប៉ុន្មានភាគរយ ?
- តើអត្រាបោះបង់វ៉ាក់សាំង BCG - MR1មានប៉ុន្មានភាគរយ ?

ចំលើយ ៖

- គណនាអត្រាគ្របដណ្តប់ ៖

វ៉ាក់សាំង BCG = (៥៣ ដូស / ១២០) X ១០០ = ៤៤,១៦ %

វ៉ាក់សាំង MR1 = (៤៥ ដូស / ១២០) X ១០០ = ៣៧,៥០ %

- គណនាអត្រាបោះបង់ ៖

វ៉ាក់សាំង BCG-MR1 = ((៥៣ ដូស-៤៥ ដូស) / ៥៣) X ១០០ = ១៥,០

# ការតាមដានស្រាវជ្រាវជំងឺ
# របស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ

## ១. ទស្សនាទាន

កម្មវិធីជាតិផ្តល់ថ្នាំបង្ការត្រូវការព័ត៌មានស្តីពីករណីសង្ស័យជំងឺរបស់កម្មវិធីជាតិ ដើម្បីវិភាគបញ្ហាទាក់ទងទៅ នឹងអត្រាគ្របដណ្តប់គុណភាពនិងប្រសិទ្ធិភាពវ៉ាក់សាំង និង ដើម្បីរិះរកវិធីទប់ស្កាត់មួយប្រកបដោយប្រសិទ្ធិភាព ។

បណ្តាញសុខាភិបាលទាំងអស់គប្បីយល់ដឹងនិងចាំនូវនិយមន័យករណីសង្ស័យជំងឺរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការដូចរៀបរាប់ជូនខាងក្រោមនេះក្នុងការជួយសំរួលការសាកសួរព័ត៌មានពីសហគមន៍ និង រាយការណ៍តាមប្រព័ន្ធព័តមានរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការដែលមានស្រាប់នូវរាល់ករណីសង្ស័យជំងឺ ដែលបានជួបប្រទះនៅពេល

អនុវត្តការងារ។

- រកអោយឃើញ ការចុះអង្កេត និង ការឆ្លើយតបឆាប់រហ័សនិងទាន់ពេលវេលាទៅនឹងជម្ងឺដែលស្ថិតនៅក្នុងប្រពន្ធ័តាមដានស្រាវជ្រាវជម្ងឺផ្តល់ថ្នាំបង្ការ។
- រកអោយឃើញនៃករណីជម្ងឺដែលអាចការពារបានដោយវ៉ាក់សាំង តាមរយៈប្រពន្ធ័តាមដានស្រាវជ្រាវជម្ងឺរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការអាចជួយអោយកំណត់តំបន់ដែលមានហានិភ័យខ្ពស់នានាផ្តោតទៅលើការអនុវត្តសកម្មភាពផ្តល់ថ្នាំបង្ការ។

ការតាមដានស្រាវជ្រាវករណីជម្ងឺឆ្លងជាក្តាមួយដ៏មានសារៈសំខាន់ សម្រាប់ការបង្ហាញពីភស្តុតាងនៃអវត្តមាននៃការឆ្លងជម្ងឺរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការដើម្បីរក្សាបាននូវស្ថានភាពគ្មានជម្ងឺគ្រុនស្វិតដៃជើងនិងជម្ងឺកញ្ជ្រឹល ព្រមទាំងដើម្បីរក្សាបាននូវវិញ្ញាបនប័ត្រ នៃការលុបបំបាត់ជម្ងឺគ្រុនស្វិតដៃជើង និង ជម្ងឺកញ្ជ្រឹល ។

## ២. និយមន័យជំងឺរបស់កម្មវិធី៖

- **និយមន័យករណីខ្វិនទន់អវៈយវៈ:**

រាល់កុមារអាយុក្រោម១៥ឆ្នាំ កើតជំងឺខ្វិនអវៈយវៈហើយនិងអ្នកជំងឺដទៃដែលមានអាយុផ្សេងពីនេះដែលត្រូវបានសង្ស័យថាជាជំងឺ គ្រុនស្វិតអវៈយវៈ។

- **និយមន័យករណីសង្ស័យជំងឺកញ្ជ្រឹល**

សូមរាយការណ៍រាល់ករណីទាំងឡាយណាដែលមានរោគសញ្ញា ៖ ក្ដៅខ្លួនខ្លាំង និង មានចេញកន្ទួលក្រហម ឬ មនុស្សម្នាក់ណាដែលគ្រូពេទ្យសង្ស័យថាមានឆ្លងជំងឺកញ្ជ្រឹលនិងស្អូច។

- **និយមន័យនៃការផ្ទុះឡើងជំងឺកញ្ជ្រឹល**

មានន័យថា មានករណីជំងឺកញ្ជ្រឹល យ៉ាងតិចចំនួន ១ករណីឡើងទៅ ។

- **និយមន័យករណីជំងឺក្អកមាន់** រាល់ករណីទាំងឡាយណាដែល៖

- ក្អកពី ២ សប្តាហ៍ឡើងទៅ និង ក្អកខ្លាំងហើយជាប់ៗគ្នា
- រកពេលដកដង្ហើមសឹងមិនបាន និង នៅពេលដកដង្ហើមចូល ឮសូរសំឡេងងឺតៗ ដូចដកចង្ការមាន់
- បន្ទាប់ពីក្អក អាចមានក្អួតទៀតផង អាការៈបែបនេះ មានរៀងរាល់ថ្ងៃ

- **សូមរាយការណ៍រាល់ករណីទារកស្លាប់**

មានន័យថា ទារកទាំងឡាយណាដែលកើតរស់ ហើយនៅចន្លោះថ្ងៃកើត ដល់ ថ្ងៃទី២៨ស្លាប់ទៅវិញ ដោយមិនគិតពីមូលហេតុនៃការស្លាប់។

- **និយមន័យករណីតេតាណូសទារក**

រាល់ទារកដែលកើតមកក្នុងកំឡុងពេល ២ ថ្ងៃដំបូង អាចបៅបាន និងស្រែកយំ និងទារកណាដែលថិតនៅក្នុងចន្លោះពី ៣ថ្ងៃ ទៅដល់ ២៨ថ្ងៃ មិនអាចបៅបាន រឹងដងខ្លួន ឬ(កន្ត្រាក់សាច់ដុំ) ឬក៏ទារកណាកើតមករស់ ហើយបានស្លាប់ទៅវិញនៅក្នុងរយៈពេល ២៨ថ្ងៃ។

- **និយមន័យករណីសង្ស័យជំងឺខាន់ស្លាក់**

មនុស្សណាម្នាក់ដែលមានជម្ងឺ ហើយដែលបានកំណត់លក្ខណៈដោយ រលាកបំពង់ក រឺភ្នាសស្អិតដែលនៅជាប់សាច់បំពង់ក រឺរលាកអាមីដាល់ ភ្នាសរំអិលនៃបំពង់ក ឬច្រមុះស្អិតជាប់គ្នា

- **និយមន័យករណីសង្ស័យជំងឺរលាកស្រោមខួរ-ខួរក្បាល**

កុមារមានអាយុ ១៥ ឬតិចជាងនេះដែលចាប់ផ្តើមមានគ្រុនក្តៅភ្លាមៗ (ជាធម្មតាលើសពី ៣៨ អង្សាសេ) ហើយមានរោគសញ្ញាមួយ ឬ លើសពីមួយដែលមានដូចខាងក្រោម៖

១. មានការប្រែប្រួលស្ថានភាពបញ្ញាស្មារតី (ដោយរាប់បញ្ចូលរោគសញ្ញាដូចជា ការច្រលំការវង្វេងស្មារតី សន្លប់ ឬមិនអាចនិយាយបាន)។

២. ចាប់ផ្តើមប្រកាច់ភ្លាមៗ (ដោយមិនរាប់បញ្ចូលការប្រកាច់ធម្មតាដោយសារការឡើងកំដៅ) វង្វេងស្មារតី ឬមានសភាពខ្ជិនទន់ដៃជើង

៣. រឹងក ឬមានសញ្ញារលាកស្រោមខួរផ្សេងទៀត

- **និយមន័យនៃហេតុការណ៍ដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ**

ហេតុការណ៍ដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ(AEFI) គឺជាហេតុការណ៍វេជ្ជសាស្ត្រណាមួយកើតឡើងបន្ទាប់ពីការផ្តល់ថ្នាំបង្ការ ។ តែតាមពិតមូលហេតុភាគច្រើនរបស់វាមិនបណ្តាលមកពីការប្រើប្រាស់វ៉ាក់សាំងទេ ហេតុការណ៍នេះអាចជាសញ្ញាមួយ ដែលកើតឡើងដោយចេតនា ឬ មិនចេតនាណាមួយដែលអាចបញ្ជាក់បានច្បាស់លាស់តាមរយៈមន្ទីរពិសោធន៍ ឬ ក៏ការស្តែងចេញជាជម្ងឺតែម្តង ។

វ៉ាក់សាំងដែលគេប្រើប្រាស់នៅក្នុងកម្មវិធីជាតិផ្តល់ថ្នាំបង្ការគឺមានសុវត្ថិភាពនិងមានប្រសិទ្ធិភាពបំផុត ។ ដូចនេះបញ្ហាកើតមានឡើងក្រោយផ្តល់ថ្នាំបង្ការធ្ងន់ធ្ងរអាចមានដោយកម្របំផុត ។

## ៣. ការរាយការណ៍ជំងឺរបស់កម្មវិធី៖

ក្រុមអ្នកផ្តល់ថ្នាំបង្ការត្រូវសួរពត៍មានជំងឺទាំងនេះពីសហគមន៍នៅពេលចុះអនុវត្តសេវាមូលដ្ឋាន បំពេញដោយអ្នកស្ម័គ្រចិត្ត។

## ៤. ការបំពេញតារាងតារាងតាមដានសកម្មភាពស្រាវជ្រាវរកករណីសង្ស័យជំងឺ និង ប្រតិកម្មក្រោយពេល ផ្តល់វ៉ាក់សាំង (ឧបសម្ព័ន្ធទី ១៩)


ក្រសួងសុខាភិបាល
គណៈកម្មាធិការជាតិកំណត់មូលហេតុនៃបញ្ហាដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ
របាយការណ៍សន្និដ្ឋានដំបូងនៃករណីបញ្ហាដែលកើតមានក្រោយផ្តល់ថ្នាំបង្ការធ្ងន់ធ្ងរ ជាមួយការបំពេញរបាយការណ៍អង្កេត
គណៈកម្មាធិការជាតិកំណត់មូលហេតុនៃបញ្ហាដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ
• គ្រូពេទ្យឯកទេសផ្នែកកុមារ
• គ្រូពេទ្យឯកទេសផ្នែកជាតុស្តី Immunologist,
• Pathologist (clinical and forensic),
• Epidemiologist
• លេខាធិការ ៖ មន្ត្រីនៃកម្មវិធីជាតិផ្តល់ថ្នាំបង្ការ និង នាយកដ្ឋានឱសថចំណីអាហារនិងគ្រឿងសំអាង
ក្រុមអង្កេតថ្នាក់ជាតិសម្រាប់ករណីនៃបញ្ហាដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ
• កម្មវិធីជាតិផ្តល់ថ្នាំបង្ការ
• គ្រូពេទ្យផ្នែកកុមារនៃមន្ទីរពេទ្យកុមារជាតិ
• គ្រូពេទ្យផ្នែកកុមារនៃមន្ទីរពេទ្យខ្មែរសូវៀត
នាយកដ្ឋានឱសថចំណីអាហារនិងគ្រឿងសំអាង
ចែករំលែក
ទិន្នន័យ
កម្មវិធីជាតិផ្តល់ថ្នាំបង្ការ
ផ្ញើ(i) គ្រប់ករណី AEFIទាំងអស់ដែលមានជាទម្រង់(CRF)
(ii) គ្រប់ករណីAEFI ដែលបានចុះអង្កេតនៅថ្នាក់ខេត្ត
(iii)របាយការណ៍ស្រាវជ្រាវផ្ទៃប្រចាំខែដែលមានAEFI
ក្រុមអង្កេតថ្នាក់ខេត្តសម្រាប់ករណីនៃបញ្ហាដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ
• នាយកមន្ទីរសុខាភិបាលខេត្ត ជាប្រធាន
• ប្រធានកម្មវិធីជាតិផ្តល់ថ្នាំបង្ការខេត្ត
• គ្រូពេទ្យផ្នែកកុមារនៃមន្ទីរពេទ្យខេត្តនិងមន្ទីរពេទ្យបង្អែក
• ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ
• ប្រធានកម្មវិធីជាតិផ្តល់ថ្នាំបង្ការស្រុកប្រតិបត្តិ
• ប្រធានមណ្ឌលសុខភាព
• អាជ្ញាធរមូលដ្ឋាន
មន្ទីរសុខាភិបាលខេត្ត
ផ្ញើ (I) របាយការណ៍ករណីAEFIទាំងអស់
(ii) របាយការណ៍ស្រាវជ្រាវផ្ទៃប្រចាំខែដែលមានAEFI
ស្រុកប្រតិបត្តិ
ផ្ញើ (I) គ្រប់ទំរង់របាយការណ៍នៃករណី AEFIទាំងអស់
(ii) របាយការណ៍ប្រចាំខែ
អង្កេតរាល់ករណីបញ្ហាដែលកើតមានក្រោយផ្តល់ថ្នាំបង្ការធ្ងន់ធ្ងរទាំងអស់
មណ្ឌលសុខភាព
មន្ទីរពេទ្យបង្អែក
បញ្ហាដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ នៅសហគមន៍ និង មន្ទីរពេទ្យ

# ជំពូកទី៧៖

# ការចូលរួមអប់រំសុខភាព សហគមន៍

# ការទំនាក់ទំនងចលនាមហាជននិងការតស៊ូមតិ

ការផ្លាស់ប្តូរឥរិយាបថការទំនាក់ទំនងក្នុងសង្គមជាយុទ្ធសាស្ត្រមួយដ៏ទូលំទូលាយនៅថ្នាក់ជាតិរួមជាមួយ នឹងផែនការការងារគឺមានសារៈសំខាន់ក្នុងការបង្កើតការយល់ដឹងនិងការបង្កើតតម្រូវការក្នុងការផ្តល់វ៉ាក់សាំងមាននៅក្នុងកម្មវិធីផ្តល់ថ្នាំបង្ការជាប្រចាំ។ យុទ្ធសាស្ត្រការផ្លាស់ប្តូរឥរិយាបថការទំនាក់ទំនងក្នុងសង្គម នឹងត្រូវបានអនុវត្តនៅថ្នាក់ជាតិខេត្ត ស្រុកប្រតិបត្តិ មណ្ឌលសុខភាព សហគមន៍ និង គ្រួសារ ហើយសារនិងអប់រំត្រូវធ្វើឱ្យមាន ប្រសិទ្ធិភាពសម្រាប់ជនជាតិភាគតិច សាសនាជនជាតិដើមភាគតិច និង ប្រជាជនរស់នៅក្នុងតំបន់មានការលំបាកទៅដល់ និងតំបន់ដែលមានហានិភ័យខ្ពស់។សកម្មភាពនៃយុទ្ធសាស្ត្រការផ្លាស់ប្តូរឥរិយាបថការទំនាក់ទំនងក្នុងសង្គមនឹងត្រូវបានកំណត់ដោយផ្អែកលើទិន្នន័យនិងភស្តុតាង។

## ១ -គោលបំណងនៃយុទ្ធសាស្ត្រទំនាក់ទំនងនិងការផ្លាស់ប្តូរឥរិយាបថ:

គោលបំណងរួមនៃយុទ្ធសាស្ត្រទំនាក់ទំនងក្នុងសង្គម និង ការផ្លាស់ប្តូរឥរិយាបទនឹងបង្កើនការគ្របដណ្តប់ តាមរយៈការបង្កើតការយល់ដឹងនិងតម្រូវការសម្រាប់ផ្តល់វ៉ាក់សាំង ក្នុងចំណោមប្រជាជនគោលដៅពិសេសក្នុងចំណោមមាតាបិតា ឬ អ្នកថែទាំកុមារ។

**គោលបំណងជាក់លាក់រួមមាន:**

- សុំការគាំទ្រពីអ្នកធ្វើគោលនយោបាយសេចក្តីសម្រេចដាក់ឱ្យប្រើប្រាស់វ៉ាក់សាំងនៅទូទាំងប្រទេស។
- លើកទឹកចិត្តឱ្យអ្នកទទួលសេវា (មាតាបិតា អ្នកថែទាំនិង សមាជិកគ្រួសារ)នាំកូនរបស់ខ្លួនទៅទទួល វ៉ាក់សាំងនៅមណ្ឌលសុខភាពដែលនៅជិតបំផុតឬមន្ទីរពេទ្យ។
- ដើម្បីបញ្ជាក់ពីពាក្យចចាមអារ៉ាមនិងព័ត៌មានមិនពិតទាក់ទងទៅនឹងការចាក់ថ្នាំបង្ការនៅក្នុងចំណោមអ្នកទទួលសេវា (មាតាបិតា អ្នកថែទាំនិងសមាជិកគ្រួសារ)
- ពង្រឹងសមត្ថភាពនៃអ្នកផ្តល់សេវា (ឧ.បុគ្គលិកមណ្ឌលសុខភាព) លើជំនាញដែលមានប្រសិទ្ធិភាពក្នុងការទំនាក់ទំនងរវាងបុគ្គលិកនិងអតិថិជនបញ្ហាកើតមានក្រោយផ្តល់ថ្នាំបង្ការ (AEFI) និងការទំនាក់ទំនងប្រឈម នឹងហានិភ័យ។
- ដើម្បីពង្រឹងការគាំទ្រពីសហគមន៍សម្រាប់គ្រប់វ៉ាក់សាំង ដល់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ។

## ២ -ប្រជាជនចំណុច និងក្រុមចូលរួម:

យុទ្ធសាស្ត្រក្នុងការទំនាក់ទំនងការផ្លាស់ប្តូរឥរិយាបទប្រជាជននឹងសង្គមក្រុមគោលដៅត្រូវបានចែកជាបួនប្រភេទសំខាន់:

១) អ្នកធ្វើគោលនយោបាយ

២) អ្នកផ្តល់សេវាកម្ម

៣) អ្នកទទួលសេវានិង

៤) អ្នកមានឥទ្ធិពល

**ក្រុមនៃប្រជាជនប្រភេទខាងក្រោមនេះ៖**

- **អ្នកធ្វើគោលនយោបាយ:**ជ្រើសរើសតំណាង ក្រសួងសុខាភិបាល កម្មវិធីជាតិផ្តល់ថ្នាំបង្ការ ក្រសួងពាក់ព័ន្ធ និងមន្ទីររាជរដ្ឋាភិបាលអង្គការក្រៅរដ្ឋាភិបាល ជាតិអន្តរជាតិ អង្គការវិជ្ជាជីវៈ បណ្ឌិតសភា ផ្នែកឯកជន អង្គការសង្គម ស៊ីវិល និងអង្គការសហគមន៍។
- **អ្នកផ្តល់សេវាកម្ម:**កម្មវិធីជាតិផ្តល់ថ្នាំបង្ការនិងមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាពនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និង ស្រុកប្រតិបត្តិនិងបុគ្គលិកមណ្ឌលសុខភាព។
- **អ្នកទទួលសេវា:**ម្តាយ អ្នកថែទាំជីដូនស្វាមីសមាជិកគ្រួសាររបស់កុមារ 0 ដល់ ១៨ ខែ
- **អ្នកមានឥទ្ធិពល:**ថ្នាក់ជាតិ ប្រព័ន្ធផ្សព្វផ្សាយថ្នាក់មូលដ្ឋាន ជ្រើសរើសអ្នកតំណាង ប្រធានភូមិ ក្រុមទ្រទ្រង់ សុខភាពភូមិ ក្រុមគាំទ្រមាតា ជនបង្គោលឃុំសម្រាប់ស្ត្រីនិងកុមារ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មេដឹកនាំសាសនា មេដឹកនាំជនជាតិ។

## ៣ -សមាសភាគនៃយុទ្ធសាស្ត្រទំនាក់ទំនងនិងការផ្លាស់ប្តូរឥរិយាបទ:

- ការតស៊ូមតិ: ដើម្បីទាក់ទាញអ្នកធ្វើគោលនយោបាយ សេចក្តីសម្រេចចិត្តនៅថ្នាក់ជាតិនិងថ្នាក់មូលដ្ឋានតាមរយៈ ការប្រជុំសិក្ខាសាលាដោយប្រើបទបង្ហាញនិងឯកសាសន្លឹក។ជាការពិតណាស់ពួកគេជួយគាំទ្រដល់សេចក្តីណែនាំ និង ការអនុវត្តន៍ការផ្តល់វ៉ាក់សាំងទូទាំងប្រទេសប្រកបដោយប្រសិទ្ធិភាព។
- ការទំនាក់ទំនងកម្មវិធី:ដើម្បីបង្កើតការយល់ដឹងនិងតម្រូវការក្នុងចំណោមក្រុមមនុស្សជាទូទៅជាពិសេសមាតាបិតា អ្នកថែទាំកុមារតាម រយៈឧបករណ៍ទំនាក់ទំនង ពហុព័ត៌មាននិង បណ្តាញប្រព័ន្ធផ្សព្វផ្សាយ (ប្រសិនបើមានថវិកា)។
- ការចលនាមហាជន:ដើម្បីឱ្យសហគមន៍អ្នកដែលមានឥទ្ធិពលចូលរួមនិងប្រជាជនសហគមន៍តាមរយៈ ការប្រជុំតំរង់ ទិស និងការប្រាស្រ័យទាក់ទងអន្តរបុគ្គលដែលបានប្រើប្រាស់សៀវភៅស្តើង។
- កសាងសមត្ថភាព: ដើម្បីពង្រឹងសមត្ថភាពរបស់ប្រព័ន្ធផ្សព្វផ្សាយ និង បុគ្គលិកសុខាភិបាលតាមរយៈការបណ្តុះបណ្តាលការប្រជុំតំរង់ទិសមានប្រសិទ្ធិភាពលើជំនាញទំនាក់ទំនងអន្តរបុគ្គល អន្តរកម្មរបស់អតិថិជនបញ្ហាកើតមាន ក្រោយផ្តល់ថ្នាំបង្ការ(AEFI) និង ការទំនាក់ទំនងហានិភ័យ។

## ៤ -សារអប់រំសុខភាព និង

ជាធម្មតាមនុស្សត្រូវបានផ្លាស់ប្តូរឥរិយាបទជាច្រើនដំណាក់កាលមុនពេលដែលពួកគេបានផ្លាស់ទម្លាប់របស់ពួកគេ។លើសពីនេះទៅទៀតមនុស្សដែលរស់នៅស្ថានភាពផ្សេងគ្នាបង្កើតបានទស្សនិកជនផ្សេងគ្នា ។ ដូច្នេះពួកគេជាធម្មតាត្រូវការសារផ្សេងគ្នានិងវិធីសាស្រ្តខ្លះខុសគ្នាដើម្បីទទួលបានព័ត៌មាន ថាតើការទំនាក់ទំនងរវាងបុគ្គល និង បុគ្គលអាចចលនាមហាជនបានច្រើនឬប្រព័ន្ធផ្សព្វផ្សាយ។ សារនិងសម្ភារៈទាំងនេះគួរតែត្រូវបានបង្កើត និង សាកល្បងជាមុនក្នុងការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនិងទស្សនិកជនគោលដៅ ។ សម្ភារៈដែលមានស្រាប់ក៏អាចត្រូវបានប្រើរួមគ្នាជាមួយនឹងសម្ភារៈថ្មី ។ ខាងក្រោមនេះជាអប់រំគួរត្រូវបានបង្កើតឡើងសម្រាប់ទស្សនិកជនគោលដៅដែលបានរៀបរាប់ខាងលើ:

- គោលនយោបាយ
- គោលការណ៍ណែនាំក្នុងការអនុវត្តសម្រាប់អ្នកផ្តល់សេវា (ឧទាហរណ៍ៈបុគ្គលិកមណ្ឌលសុខភាព)
- សៀវភៅស្តើងសម្រាប់ក្រុមគោលដៅដែលអ្នកផ្តល់សេវាប្រើ (បុគ្គលិកមណ្ឌលសុខភាព) និងអ្វីដែលមានឥទ្ធិពលក្នុងការផ្សព្វផ្សាយ (ប្រព័ន្ធផ្សព្វផ្សាយ)
- សៀវភៅស្តើងសម្រាប់ក្រុមគោលដៅអ្នកទទួលសេវា (ឧទាហរណ៍ៈម្តាយ អ្នកថែទាំ សមាជិកគ្រួសារ)
- ប័ណ្ណប្រកាសសម្រាប់អ្នកទទួលសេវា (ឧទាហរណ៍ៈ ម្តាយ អ្នកថែទាំ សមាជិកគ្រួសារ) ដែលត្រូវបានបង្ហាញនៅគ្រឹះស្ថានសុខាភិបាល ។
- បដាសម្រាប់អ្នកទទួលសេវាដែលជាក្រុមគោលដៅ (ឧទាហរណ៍ៈ.ម្តាយ អ្នកថែទាំ សមាជិកគ្រួសារ) ដែលត្រូវបានបង្ហាញនៅគ្រឹះស្ថានសុខាភិបាល កន្លែងក្រៅ។
- វិទ្យុសម្រាប់អ្នកទទួលសេវា (ឧទាហរណ៍ៈម្តាយ / អ្នកថែទាំ / សមាជិកគ្រួសារ)

## ៤-១ -សារគន្លឹះដ៏សំខាន់សម្រាប់ក្រុមអ្នកបង្កើតគោលនយោបាយការសម្រេចចិត្ត

- ការចាក់ថ្នាំបង្ការនៅតែមានតម្លៃក្នុងចំណោមអន្តរាគមន៍ជាច្រើនដែលមានប្រសិទ្ធិភាពសម្រាប់សុខភាព។
- ក្រុមផ្តល់ប្រឹក្សាពីអ្នកជំនាញជាយុទ្ធសាស្រ្តលើការងារផ្តល់ថ្នាំបង្ការបានផ្តល់អនុសាសន៍ថាប្រទេសទាំងអស់យ៉ាងហោចណាស់ត្រូវផ្តល់វ៉ាក់សាំង IPV មួយដូស ទៅក្នុងសកម្មភាពផ្តល់ថ្នាំបង្ការជាប្រចាំ នៅមុនដំណាច់ឆ្នាំ ២០១៥ ស្របតាមយុទ្ធសាស្រ្តលុបបំបាត់ជម្ងឺគ្រុនស្វិតដៃជើង។
- ការផ្តល់វ៉ាក់សាំងត្រូវបានផ្តល់អនុសាសន៍ឱ្យប្រើនៅក្នុងកម្មវិធីផ្តល់ថ្នាំបង្ការផ្តល់ឱ្យកុមារនូវអាយុក្រោម២ឆ្នាំ។

## ៤- ២ -សារគន្លឹះដ៏សំខាន់សម្រាប់អ្នកផ្តល់សេវាៈ

- ពាក្យចចាមអារ៉ាមមិនមានភស្តុតាងពិតអំពីសុវត្ថិភាពវ៉ាក់សាំងអាចនឹងបង្កឱ្យប្រជាជនបាត់បង់ទំនុកចិត្តលើកម្មវិធីជាតិផ្តល់ថ្នាំបង្ការនិងការចំណាយក្នុងជីវិត។

- កាលពីមុនមនុស្សរាប់លាននាក់បានស្លាប់ ឬ បាត់បង់សមត្ថភាព ដែលឥឡូវនេះយើងអាចការពារបានដោយសារវ៉ាក់សាំង។ប្រសិនបើយើងមិនបន្តផ្តល់វ៉ាក់សាំងការពារជម្ងឺទាំងនេះទេ វានឹងវិលត្រឡប់មកវិញសម្លាប់ជីវិតមនុស្ស ច្រើនទៀត។
- បានទទួលថ្នាំបង្ការវាមានសុវត្ថិភាពច្រើនជាជាងកើតជម្ងឺ។
- ថ្នាំបង្ការទាំងអស់មានទម្រង់សុវត្ថិភាពមានន័យថា អាចមានប្រតិកម្មតិចតួចជាធម្មតាហើយជាទូទៅស្រាល និង បណ្ដោះអាសន្ន។
- អាចបង្កឱ្យមានប្រតិកម្មវ៉ាក់សាំងប៉ុន្តែភាគច្រើនមានកម្រិតស្រាល និង មិនមានរយៈពេលយូរទេហើយអាចគ្រប់គ្រង ដោយខ្លួនឯងបានវាកម្រមានបញ្ហាធ្ងន់ធ្ងរឬរយៈពេលវែង។
- ការទំនាក់ទំនងមានប្រសិទ្ធិភាពជាមួយមាតាបិតា អ្នកមើលថែទាំអាចកាត់បន្ថយចំនួននៃការបោះបង់។

## ៤- ៣ -សារគន្លឹះដ៏សំខាន់សម្រាប់អ្នកទទួលសេវា:

- ការចាក់ថ្នាំបង្ការជាគន្លឹះដ៏សំខាន់ដើម្បីសម្រេចបានគោលដៅក្នុងការកាត់បន្ថយការស្លាប់កុមារដែលមានអាយុក្រោម៥ឆ្នាំ ដោយសារជម្ងឺដែលអាចការពារបានដោយសារថ្នាំបង្ការ ។
- គ្មានឪពុកម្ដាយណាចង់ឱ្យកូនស្លាប់ដោយសារជម្ងឺដែលគេអាចការពារបានដោយការចាក់វ៉ាក់សាំងទេ។
- ដើម្បីរក្សាកុមារឱ្យមានសុខភាពល្អ ការចាក់ថ្នាំបង្ការបានជួយពន្យារជីវិត និងពេលវេលាដែលបានចំណាយលើសកម្មភាព ថែទាំសុខភាព។ ដូច្នេះការចាក់ថ្នាំបង្ការអាចជួយក្នុងការកាត់បន្ថយភាពក្រីក្រ។
- កុមារដែលបានចាក់ថ្នាំបង្ការគ្រប់មុខវ៉ាក់សាំង និង គ្រប់ដូសគឺពេលចូលសាលារៀន មានសមត្ថភាពយល់ដឹងច្រើន ហើយក្លាយជាសមាជិកនៃសង្គមកាន់តែច្រើន និង ហាក់ដូចជាមិនសូវមានជម្ងឺធ្ងន់ធ្ងរ។
- កាលពីមុនមនុស្សរាប់លាននាក់បានស្លាប់ ឬ ត្រូវពិការភាពពីជម្ងឺដែលឥឡូវនេះយើងអាចការពារបានដោយសាវ៉ាក់សាំង។ប្រសិនបើយើងមិនបន្តការចាក់វ៉ាក់សាំងជម្ងឺទាំងនេះនឹងវិលត្រឡប់មកវិញ និង ឆក់យកជីវិតមនុស្សជាច្រើនទៀត។
- ថ្នាំបង្ការទាំងអស់មានសុវត្ថិភាពមានន័យថាគេបានរំពឹងទុកថា នឹងមានប្រតិកម្មតិចតួចប៉ុន្តែទាំងនេះជាធម្មតាស្រាល និងណ្ដោះអាសន្ន។
- វ៉ាក់សាំងអាចធ្វើអោយមានប្រតិកម្មប៉ុន្តែភាគច្រើនស្រាល ហើយវាបាត់ដោយខ្លួនឯង និង មិនមានរយៈពេលយូរ ឬបញ្ហាធ្ងន់ធ្ងរ។

## ៤-៤ -សារគន្លឹះដ៏សំខាន់សម្រាប់គោលដៅ

- ការចាក់ថ្នាំបង្ការជាគន្លឹះដ៏សំខាន់ដើម្បីសម្រេចបានគោលដៅក្នុងការកាត់បន្ថយការស្លាប់កុមារដែលមានអាយុក្រោម៥ឆ្នាំ ដោយសារជម្ងឺដែលអាចការពារបានដោយសារថ្នាំបង្ការ ។
- គ្មានឪពុកម្តាយណាចង់ឱ្យកូនស្លាប់ដោយសារជម្ងឺដែលអាចការពារបានដោយការចាក់វ៉ាក់សាំងទេ។
- ដើម្បីរក្សាកុមារឱ្យមានសុខភាពល្អការចាក់ថ្នាំបង្ការបានជួយពន្យារជីវិតនិងមិនផលាចំណាយលើសកម្មភាព ថែទាំសុខភាព។ ដូច្នេះការចាក់ថ្នាំបង្ការអាចជួយក្នុងការកាត់បន្ថយភាពក្រីក្រ។
- កុមារដែលបានចាក់ថ្នាំបង្ការគ្រប់មុខវ៉ាក់សាំង និង គ្រប់ដូសគឺពេលចូលសាលារៀន មានសមត្ថភាពយល់ដឹង ច្រើនហើយក្លាយជាសមាជិកនៃសង្គមកាន់តែច្រើននិងហាក់ដូចជាមិនសូវមានជម្ងឺធ្ងន់ធ្ងរ។
- កាលពីមុនមនុស្សរាប់លាននាក់បានស្លាប់ ឬ ត្រូវពិការភាពពីជម្ងឺ ដែលឥឡូវនេះយើងអាចការពារបានដោយសារ វ៉ាក់សាំង ។ ប្រសិនបើយើងមិនបន្តការចាក់វ៉ាក់សាំងជម្ងឺទាំងនេះនឹងវិលត្រឡប់មកវិញ និង ឆក់យកជីវិតមនុស្ស ជាច្រើនទៀត។
- ថ្នាំបង្ការទាំងអស់មានសុវត្ថិភាព មានន័យថាគេបានរំពឹងទុកថា នឹងមានប្រតិកម្មតិចតួច ប៉ុន្តែទាំងនេះជាធម្មតា ស្រាលនិងណ្តោះអាសន្ន។
- វ៉ាក់សាំងអាចធ្វើអោយមានប្រតិកម្មប៉ុន្តែភាគច្រើនស្រាល ហើយវាបាត់ដោយខ្លួនឯង និង មិនមានរយៈពេលយូរ ឬបញ្ហាធ្ងន់ធ្ងរ

៥-ខាងក្រោមនេះគឺជាវេទិកាកិច្ចប្រជុំដែលមានស្រាប់ដែលត្រូវបានរៀបចំឡើងនៅក្នុងស្ថាប័នរដ្ឋបាល និង ស្ថាប័នសុខាភិបាល:



កក្តាសំខាន់បំផុតការទំនាក់ទំនងអន្តរបុគ្គលដែលត្រូវអនុវត្តដោយអ្នកផ្តល់ថ្នាំបង្ការជាពិសេសពេលបើកទិវាផ្តល់ថ្នាំបង្ការនៅតាមសហគមន៍ និង នៅពេលបើទិវាផ្តល់ថ្នាំបង្ការនៅមណ្ឌលសុខភាពគឺពេលចាប់ផ្តើមផ្តល់វ៉ាក់សាំង លើកដំបូង ។ ការវាយតម្លៃការផ្តល់វ៉ាក់សាំងការពារជម្ងឺកញ្រ្ជឹលដូសទី២បានបង្ហាញថាមានកង្វះខាតក្នុងការទំនាក់ទំនងអន្តរបុគ្គល រវាងអ្នកផ្តល់សេវានិងអ្នកទទួលសេវា ។

## ឧបសម្ព័ន្ធ ៖